ជំពូក ៥

ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

Potential Environmental Impacts and Mitigation Measures

Draft

ជំពូកទី ៥

ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

៥.១ សេចក្តីផ្តើម (Indroduction)

ការសិក្សានេះយោងតាមអនុក្រឹត្យស្តីអំពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលចុះហត្ថលេខាដោយ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ចូលជាធរមាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ គំរោងវិនិយោគសាងសង់វារីអគ្គិសនីជាយអារែង របស់ក្រុមហ៊ុន China Southern Power Grid Co., Ltd . បានចុះធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) ចាប់ពីថ្ងៃទី ០៥ ខែវិច្ឆិកា ដល់ ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៨។

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គម (IESIA) នេះគឺជាការអង្កេតសិក្សាស្រាវជ្រាវដើម្បីរក និងកំណត់ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះត្រូវរកវិធានការកាត់បន្ថយឱ្យដល់កំរិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្ត, មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត, មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរកសិកម្មខេត្ត, មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត, អាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់, ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ក្រុមការងារ SAWAC បានប្រើប្រាស់ក្រដាស់ Checklist ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកំរិត តិច មធ្យម និងខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កំរិតអប្បបរមា ។

៥.២ វិធីសាស្ត្រ (Methodology)

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) នេះគឺជាការអង្កេត សិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាជាមួយសហគមន៍/ប្រជាជនមូលដ្ឋាន អង្គការនានា និងស្ថាប័នជាប់ទាក់ទងនឹងគំរោងគ្រប់ជាន់ថ្នាក់ លើទីតាំងគំរោង សមាសភាពគំរោង ការងារសាងសង់គំរោង និងកិច្ចដំណើរការរបស់វា ដើម្បីស្វែងរក និងកំណត់ ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការកាត់បន្ថយ និងធ្វើផែនការគ្រប់គ្រងបរិស្ថាន នៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័ន ជំនាញពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្តកោះកុង , មន្ទីរធនធានទឹក និងឧតុនិយមខេត្តកោះកុង , មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកោះកុង , មន្ទីរទេសចរណ៍ខេត្តកោះកុង , ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកោះកុង , អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ , ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន , ក្រសួង

ឧស្សាហកម្ម រ៉ែ និងថាមពល , ក្រសួងធនធានទឹក និងឧតុនិយម , ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ក្រុមការងារ SAWAC បានប្រើប្រាស់តារាង Checklist សម្រាប់គំរោងវារីអគ្គិសនី (គោលការណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍន៍អាស៊ី) ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកិរិត មធ្យម និងខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កិរិតអប្បបរមា ។

តារាង Checklist **សម្រាប់គំរោងវារីអគ្គិសនី :**

ក. ធីតាំងគំរោង: *តើតំបន់គំរោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដែរទេ ?*	**មាន**	**គ្មាន**	**កត់សំគាល់**
• ទីតាំងមរតកវប្បធម៌		✓	
• តំបន់ការពារ/អភិរក្ស	✓		ភ្នំក្រវាញភាគកណ្តាលខាងត្បូង និងពាមក្រសោប
• តំបន់ដីសើម	✓		ត្រពាំងបបុស្សតូច បបុស្សធំ ជាជំរកក្រពើភ្នំ
• កោងកាង		✓	
• មាត់ពាម (តំបន់ទឹកភ្លៀវ)		✓	
• តំបន់ទ្រនាប់នៃតំបន់ការពារ/អភិរក្ស	✓		ភ្នំក្រវាញភាគកណ្តាលខាងត្បូង និងពាមក្រសោប
• តំបន់ពិសេសសំរាប់ការពារ/អភិរក្សជីវចំរុះ	✓		ភ្នំក្រវាញភាគកណ្តាលខាងត្បូង និងពាមក្រសោប
ខ. ផលប៉ះពាល់បរិស្ថានសំខាន់ៗ *តើគំរោងនឹងបង្កឱ្យ.....*			
• បាត់បង់សម្បត្តិអេកូឡូស៊ីដ៏មានតំលៃដោយសារការលិចលង់តំបន់កសិកម្ម/ព្រៃឈើ, ជំរកសត្វព្រៃ, ខ្ទាន់ដល់ត្រីពង/បង្កកំនើតនិងឧបសគ្គដល់ផ្លូវបំលាស់ទីរបស់ត្រីដែរទេ?	✓		លិចលង់តំបន់ព្រៃឈើ ជំរកសត្វព្រៃ ដីកសិកម្ម និង ដីលំនៅដ្ឋានក្នុងអាងទឹក ផ្នែកខាងលើទំនប់ (SiteA)
• បាត់បង់វត្ថុបុរាណ , រូបសំណាកប្រវត្តិសាស្ត្រ រូបសំណាកវប្បធម៌ ដែរទេ?		✓	
• ការផ្លាស់ទី ឬការតាំងលំនៅឡើងវិញរបស់ប្រជាជនដោយឥតចេតនាដែរទេ?	✓	●	៣៨៩គ្រួសារ មានដីនៅក្នុងតំបន់អាង និងក្នុងនោះមានតែ ១៨៩ គ្រួសារប៉ុណ្ណោះដែលត្រូវជន្លៀសចេញ
• ការរំខាន/ឧបសគ្គដល់ក្រុមកុលសម្ព័ន្ធ/ប្រជាជនអន្តោគ្រាម ដែរទេ?	✓		ខ្មែរជង់មួយចំនួនតូចរស់នៅក្នុងតំបន់អាង
• ការថយចុះបរិស្ថានចេញពីកំនើនការកាន់កាប់ដីព្រៃឈើដែរទេ?	✓		ការកើនឡើងនៃអ្នកចំណូលស្រុកថ្មី ធ្វើចំការដំណាំ រកអនុផលព្រៃឈើ ការតាំងលំនៅដ្ឋាន ។ល។
• ទំនាស់លើសិទ្ធិផ្តត់ផ្តង់ទឹកនិងទំនាស់នានាទាក់ទិននឹងសង្គមដែរទេ?		✓	
• តើមានការថយចុះទិន្នផលត្រី និងការបន្តពូជរបស់ត្រី ដែរឬទេ? ក្រោយពីមានការសាងសង់វារីអគ្គិសនីនោះ ។	✓		អាចមានផលប៉ះពាល់ដល់ចរាចរត្រី ក្នុងការបន្តពូជរបស់ប្រភេទត្រីមួយចំនួន ដែលរស់នៅតំបន់ស្ទឹងជាយអារែង

			ដូចជា ត្រីនាគ ត្រីខ្មៅ និងប្រភេទកម្រផ្សេងទៀត ជាពិសេសសត្វក្រពើភ្នំ ។
• ដំណើរវិវត្តសាយនៃវារីជាតិឥតប្រយោជន៍ក្នុងអាងនិងនៅខ្សែទឹកខាងក្រោមធ្វើឱ្យថយចុះដែរឬទេ?	✓		អាចនឹងមានវារីជាតិឥតប្រយោជន៍ (ពើក, ចកជាដើម) ក្នុងអាងស្តុកទឹកនៅប៉ុន្មានឆ្នាំបន្តបន្ទាប់ទៀត ។
• តើមានជំរាបទឹកចេញពីកន្លែងផ្សេងៗទៀតដែរឬទេ ? ក្រោយពីមានការសាងសងវារីអគ្គីសនីនោះ ។	✓		អាចមានជំរាបតាមជ្រលងភ្នំឬអាចមាននៅតាមកន្លែងខ្ះ នៃស្រទាប់ដីរបស់អាងស្តុក ។
• ការស៊ីច្រោះដីបាតស្ទឹង នៅខាងក្រោមទំនប់ដែរទេ ?	✓		អាចនឹងមាន ព្រោះតំបន់ស្ទឹងជាយអាវែង មានល្បាយដីខ្សាច់ច្រើនជាងថ្ម។
• កំណើនឧប្បត្តិហេតុនៃជំងឺកើតពីទឹក ឬជំងឺទាក់ទងនឹងទឹកដែរទេ ?	✓		ដោយសារការរលួយនៃ រុក្ខជាតិក្នុងអាងទឹកបង្កើនជំរកសត្វមូសនិងអាចកើតមានសត្វល្អិតចង្រៃមួយចំនួនទៀត
• ការបាត់បង់អុកស៊ីសែនក្នុងទឹក ដោយសារការពុករលួយយ៉ាងច្រើននៃរុក្ខជាតិ ធ្វើឱ្យត្រីងាប់ ការរីកដាល Algae បង្កឱ្យមាន រុក្ខជាតិទឹក (Hydrophyte) ដែរទេ ?	✓		អាចនឹងកើតមានបាតុភូតនេះក្នុងអាងស្តុកទឹក(ពើក, ចកជាដើម) នៅប៉ុន្មាន ឆ្នាំបន្តទៀត ហើយវាក៏អាចកើតមានរឿងរហូតនៅតាម តំបន់នៃអាង ។
• មានការថយចុះគុណភាពទឹកក្នុងអាង ដែរទេ ?	✓		ជាទូទៅអាចនឹងមានក្នុងអាងស្តុកទឹកនៅប៉ុន្មានឆ្នាំដំបូង ។
• មានការផ្លាស់ប្តូរធនធានជលផលដែរឬទេ ? បើសិនមានការប្រែប្រួលចរន្តទឹកនៅផ្នែកខាងក្រោមអាងនៅពេលមានការកើនឡើងនៃកំរិតកំពស់ទឹកនៅផ្នែកខាងលើអាង ព្រមទាំងមានការថយចុះគុណភាពទឹកនោះ ។	✓		នឹងធ្វើឱ្យទិន្នផលត្រីថយចុះនៅដំណាក់កាលសាងសង់ដំបូង និងអាចរឿងរហូត ។
• បាត់បង់ប្រភេទត្រីបំលាស់ទីដោយសារការរារាំងបង្ហាក់នៃទំនប់ទាំងពីរដែរទេ ?			យោងតាមបណ្តាំគំរោងពុំឃើញមានកន្លែងឱ្យត្រីឆ្លងកាត់ពីខ្សែទឹកក្រោមទៅខ្សែទឹកខាងលើឡើយដែលជាហេតុធ្វើឱ្យមានការផ្លាស់ប្តូរចរាចររបស់ត្រីដោយសារការសាងសង់ទំនប់វារីអគ្គីសនី ។
• ការរងកករដីនៅក្នុងអាង និងការបាត់បង់សមត្ថភាពស្តុកទឹក ដែរទេ ?	✓		វាមានការប៉ះពាល់បន្តិចបន្តួចដែរ តែវាមិនជាបញ្ហាចោទទៅដោយសារទឹកនៅក្នុងអាងមានផ្ទៃធំ ហើយនៅជុំវិញអាងមានតំរបព្រៃឈើដែលសំរាប់ការពារការហូរច្រោះ ។
• ការផ្លាស់ប្តូរសីតុណ្ហភាពទឹក នៅពេលកើតមានចរន្តទឹកវិលវល់កក្នុងអាង ដែរឬទេ?	✓		ធ្វើឱ្យគុណភាពទឹកមានលក្ខណៈខុសគ្នាទៅតាមស្រទាប់ទឹក ។ កន្លែងខ្លះអាចមានល្បាប់ក្នុងចរន្តទឹកភាពរលាយអុកស៊ីសែនទាប និងកំរិតជាតិដែក និងម៉ង់កាណែសខ្ពស់
• បន្ថយទំនាបលិចទឹកសំរាប់កសិកម្ម ដែរឬទេ ?	✓		ផ្នែកខាងក្រោមទំនប់មានការថយចុះទំនាបលិចទឹកដោយសារប្រព័ន្ធប្រឡាយសង់ថ្មីដើម្បីយកទឹកដំណើរការទូបីជលិតភ្លើងអគ្គិសនី ។
• តើការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋដែលរងការប៉ះពាល់ដោយសារគំរោងធ្វើឱ្យបាត់បង់ធនធានធម្មជាតិដែរទេ ?	✓		អាចនឹងមាន ដោយត្រូវការការរានដីថ្មី ចំនួន ២៣៤៧ ហិកតា ។

៥.៣ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ
Negative Environmental Impacts and Mitigation Measures

គំរោងវារីអគ្គិសនីជាយអារំរែងមានទីតាំងនៅក្នុងតំបន់អភិរក្សភ្នំក្រវាញកណ្តាល ខាងត្បូង និង ពាមក្រសោប ដែលនៅទីនោះគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោងជាច្រើន ហើយដែលជាកន្លែងរស់នៅរបស់បក្សី (ទាព្រៃស្លាបសចឡជើងល្មៀតកម្រ) ថនិកសត្វ (ស្វាក្រវ៉ាត់ ទោចម្កុដ ទោចថ្ពាល់លឿង ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច សំពោចកលឿង ភេរក្បាលសំប៉ែត ឆ្កាដាវ ខ្លាលឿងមាស ខ្លាភ្លីថ្នកែវ ខ្លាពពក ខ្លារខិន ខ្លាដំបង ដំរី ឈ្លូសយក្ស ខ្ទីង កែស និងពង្រូល) និងឧរង្គសត្វ (ក្រពើត្រី/ក្រពើភ្នំ និងត្រកួត) ដែលជាប្រភេទសត្វកំពុងទទួលរងនូវការគំរាមកំហែងទូទាំងពិភពលោកស្ថិតនៅក្នុងឧបសម្ពន្ធ័ I នៃអនុសញ្ញា CITES។ មានបក្សីប្រមាណ ១១៣ ប្រភេទ ថនិកសត្វ ៥៣ ប្រភេទ លូន ៣១ ប្រភេទ និងមច្ឆជាតិ ៤៣ ប្រភេទ ត្រូវបានរកឃើញនៅក្នុងតំបន់គំរោងនេះ។ ម្យ៉ាងវិញទៀតខ្សែទឹកខាងក្រោមនៃគំរោងជាយអារំរែងនេះ ជាតំបន់រមណីយដ្ឋានទេសចរណ៍ក្បាលឆាយជាច្រើន និងតំបន់មាត់ពាម (តំបន់ទឹកភ្លៀវ) នៃព្រែកត្រពាំងរូង និងចុងបញ្ចប់ គឺតំបន់ឆ្នេរក្នុងខេត្តកោះកុង ដែលនៅទីនោះសំបូរទៅដោយស្មៅសមុទ្រ ផ្កាថ្ម មច្ឆជាតិ ព្រៃលិចទឹក និងកោងកាង។

យោងតាមឯកសាររចនាបថ្ងៃគំរោង និងទីតាំងភូមិសាស្ត្រតំបន់នេះឃើញថា : ទីតាំងគំរោងនឹងមានការប៉ះពាល់ដល់តំបន់អភិរក្សភ្នំក្រវាញកណ្តាល ក្រវាញខាងត្បូង និងឧទ្យានជាតិពាមក្រសោប (តិចតួច) ហើយផលប៉ះពាល់អវិជ្ជមានដែលនឹងកកើតចេញ ពីសកម្មភាពគំរោងតាមដំណាក់កាលនិមួយៗ មានពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ។

៥.៣.១ ដំណាក់កាលរចនាគំរោង (Project Design)

ក្នុងដំណាក់កាលនេះគំរោងពុំមានសកម្មភាព ដែលបង្កឱ្យមានផលប៉ះពាល់ធំដុំឡើយ។ ដំណាក់កាលរចនាគំរោងគឺ មានអ្នកជំនាញការតាមផ្នែកបច្ចេកទេស ធ្វើការសិក្សាស្រាវជ្រាវទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួន ដើម្បីរចនាបថ្ងៃគំរោងតាមសមាសភាពនីមួយៗ។ ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗដល់ធនធានបរិស្ថាន និងសង្គមដំបូង រួមមានដូចតទៅ :

៥.៣.១.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះធនធានអេកូឡូស៊ី និង វិធានការកាត់បន្ថយ

- **ការហូរច្រោះ និងគុណភាពដី**

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលនេះការហូរច្រោះដីពុំមានទេ ដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និងពង្រាបដីដើម្បីសិក្សាឡើយ។ ក៏ប៉ុន្តែអាចមានផលប៉ះពាល់ខ្លះៗដល់គុណភាពដីបណ្តាលមកពីការហៀរ ឬកំពុបប្រេង និងការចោះកាកសំណល់ផ្សេងៗ ដោយបុគ្គលិក-កម្មកររបស់គំរោងក្នុងពេលសិក្សានោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន នឹងរៀបចំការផ្គុំកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អ មិនលេចហូរប្រេងមកលើដីក្នុងតំបន់គំរោង និងរក្សាទុកកាកសំណល់ប្រេងឱ្យបានត្រឹមត្រូវ។

រីឯកាកសំណល់រឹងចេញពីកន្លែងស្នាក់នៅត្រូវមានធុងសំរាមកន្លែងទុកដាក់សំរាម និង បំផ្លាញចោលនៅទីតាំងដែលមានសុវត្ថិភាពល្អ ។ ក្រុមហ៊ុននឹងចាត់វិធានការឱ្យបុគ្គលិកមានការទទួលខុសត្រូវរៀងខ្លួនលើសំណល់នៃទីតាំងរបស់ខ្លួន ។

- **ការបំពុលទឹក**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅខណៈនៃការសិក្សានេះដែរ ប្រភពទឹកនៃស្ទឹងជាយអារែងអាចនឹងមានផលប៉ះពាល់ខ្លះដោយសារសំណល់នៃឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ហើយការស្នាក់នៅរបស់បុគ្គលិក-កម្មកររបស់គំរោងនេះដែរ ក៏ជាកន្លែងបង្កើតកាកសំណល់រឹង-រាវ ចេញពីផ្ទះបាយ និងបង្គន់ចូលទៅក្នុងស្ទឹងផងដែរ ។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងអប់រំកម្មករក្នុងការទុកដាក់សំណល់ផ្សេងៗឱ្យបានសមស្រប ដូចជាការជីកកប់ ការញែកសំណល់ដែលអាចប្រើឡើងវិញបានចេញ និងជ្រើសរើសទីតាំងឱ្យឆ្ងាយពីប្រភពទឹកដើម្បីទុកដាក់សំណល់ ការពារកុំឱ្យមានការហូរចូលទៅក្នុងប្រភពទឹកនៅពេលមានភ្លៀង និងតាមរយៈខ្យល់បក់ ។

ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យដោយជីករណ្តៅដាក់លូដើម្បីស្តុកលាមកមានជំរៅពី ២.៥ ទៅ ៣.៥ម៉ែត្រ ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញគឺមិនបង្ហូរឬ ចាក់ចូលទៅក្នុងស្ទឹងជាយអារែងទេ គឺជីករណ្តៅជំរៅ១-២ ម៉ែត្រ ទំហំ៤-៦ម៉ែត្រការ៉េ ដើម្បីធ្វើឱ្យកាកសំណល់នោះក្លាយជាជីកំប៉ុស៍បានថែមទាំងមានធុងសំរាប់ទុកដាក់សំរាម និងកន្លែងកប់ ឬដុតសំរាមចោលដោយសុវត្ថិភាព។

ក្រុមហ៊ុននឹងធ្វើការណែនាំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សំរាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង ។

- **សំឡេង រំញ័រ និងការរំញួយ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះអាចបង្កឱ្យមានការរំខានដល់សត្វព្រៃដោយសារក្រុមហ៊ុនមានការខួងដីសំរាប់សិក្សាអំពីគ្រឹះតាមចំណុចដៅជាច្រើននៃទីតាំងទំនប់ SiteA និង SiteB និងអគារចាមពល (Powerhouse) សំរាប់ដាក់តួបីន ហើយសកម្មភាពនៃការខួងដីនេះត្រូវការកម្មករជាច្រើននាក់ បង្កឱ្យមានសំឡេងអ៊ូអរ រួមទាំងសន្ទឹកសំឡេងម៉ាស៊ីន និងរំញ័រ ។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងប្រើម៉ាស៊ីនខួងដី ដែលមានកិរិតរំញួយ និងសំឡេងតិច ដើម្បីកាត់បន្ថយសំឡេង និងរំញ័រដែលរំខានដល់សត្វព្រៃ ។ ហើយការងារនឹងមិនធ្វើការពេលយប់ទេ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃ ។ ក្រុមហ៊ុននឹងអប់រំកម្មកររបស់គំរោងមិនឱ្យមានការស្រែក ឬជជែកគ្នាខ្លាំងៗ ដើរចេញឆ្ងាយទីតាំងការព្រោះវារំខានដល់សត្វព្រៃ។

ម្យ៉ាងទៀត ក្រុមហ៊ុនមិននឹងលើតក្រុមសិក្សាញឹកញាប់ទេ ពោលគឺក្រុមហ៊ុននឹងកោះទីតាំងទៅតាមតំបន់សំខាន់ៗដែលកំណត់ក្នុងការសិក្សា ធ្វើយ៉ាងនេះធ្វើឱ្យកាត់បន្ថយការប៉ះពាល់ដល់ការរំខានដល់សត្វព្រៃ ។

- **តំបន់អភិរក្សភ្នំក្រវាញ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់គ្រោងរចនានេះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៃតំបន់អភិរក្សនេះ ដោយសារសកម្មភាពសិក្សាគំរោងមានសំឡេងពីគ្រឿងចក្រ ភាពខ្សែវែខ្លារ នៃក្រុមបុគ្គលិក-កម្មករ ការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម នឹងបង្កឱ្យមានផលប៉ះពាល់ដល់ស្ថានប្រព័ន្ធ និងអេកូឡូស៊ីផងដែរ ។ល។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និង រំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្ដើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ហើយធ្វើការអប់រំដល់កម្មករគំរោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់គំរោងដើម្បីចាប់ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ព្រមទាំងដាក់វិន័យយ៉ាងតឹងរឹងដល់ពួកគេ ដែលប្រព្រឹត្តិខុសទៅនឹងបំរាមនេះ ។

រីឯស្បៀង និងម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬហូបម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ ក្រុមហ៊ុន នឹងនាំស្បៀងពីកោះកុងដើម្បីផ្គត់ផ្គង់ដល់កម្មកររនៅតំបន់គំរោង ។

ជាងនេះទៅទៀតក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិក-កម្មករគំរោងឱ្យយល់ពីច្បាប់នៃការគ្រប់គ្រងថែរក្សាធនធាន និងសត្វព្រៃនៅក្នុងតំបន់ការពារ ។

- **ធនធានព្រៃឈើ និងសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដោយសារសកម្មភាពសិក្សាគំរោង អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដូចជា ការកាប់កូនឈើធ្វើស្ពាន និងរានព្រៃធ្វើផ្លូវ ហើយនឹងអាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និង ក្បែរខាងតំបន់គំរោង។ ចំពោះឧបករណ៍សំភារៈសិក្សាស្រាវជ្រាវសកម្មភាពខួងដីមានសំឡេង និងរំញ័រខ្លាំងអាចនឹងធ្វើឱ្យប៉ះពាល់ដល់ធនធានសត្វព្រៃ និងជំរកសត្វព្រៃ ជាពិសេសប៉ះពាល់ដល់របៀងសត្វដីរ ដែលធ្លាប់ធ្វើដំណើរក្បែរខាងតំបន់គំរោង (តាមរបាយការណ៍របស់ប្រជាពលរដ្ឋ) ។

ដំណាក់កាលនេះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៃតំបន់គំរោងផងដែរ ដោយសារសកម្មភាពនៃក្រុមបុគ្គលិក-កម្មករ ដូចជាការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករ ក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម ។ល។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងសុំការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សក្នុងតំបន់គំរោងដើម្បីកាប់ឆ្ការព្រៃឈើធ្វើផ្លូវ និងប្រើប្រាស់ឈើសំរាប់សាងសង់ស្ពានឆ្លងកាត់ ។ ធ្វើការអប់រំដល់កម្មករគំរោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់គំរោងដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃ សំរាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ហើយដាក់វិន័យយ៉ាងតឹងរឹងដល់ពួកគេដែលប្រព្រឹត្តិខុសទៅនឹងបំរាមនេះ ។ រីឯស្បៀង និងម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬហូបម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ ក្រុមហ៊ុន នឹងនាំស្បៀងពីកោះកុងដើម្បីផ្គត់ផ្គង់ដល់កម្មកររនៅតំបន់គំរោង ។

ក្រុមការងាររបស់គំរោងនឹងបោះជំរុំការងារនៅនឹងកន្លែងជ្រៀសវាងការដឹកសំភារៈការងារចុះឡើង បង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ។ ការងារនឹងធ្វើនៅពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។

- **ជីវសាស្ត្រសត្វព្រៃ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលរចនាគំរោងនេះ អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃដោយសារសកម្មភាពសិក្សាគំរោងក្រុមហ៊ុនមានការខូងដីសំរាប់សិក្សា គ្រឹះតាមចំណុចដៅជាច្រើននៃទីតាំងទំនប់ SiteA និង SiteB និងទីតាំងអគារថាមពល (Powerhouse) ដែលត្រូវការកម្មករជាច្រើននាក់ក្នុងការងារ បង្កឱ្យមានសំឡេងអ៊ូអរ រួមទាំងសន្ទឹកសំឡេងម៉ាស៊ីន និងរំញ័របង្កឱ្យមានការរំខានដល់សត្វព្រៃ នៅខណៈនោះដែរក្រុមហ៊ុនត្រូវការកាប់ឆ្ការព្រៃដើម្បីធ្វើផ្លូវចូលទៅទីតាំងសិក្សា ។ ដោយសារសកម្មភាពសិក្សាគំរោងមានសំឡេងពីគ្រឿងចក្រ ភាពខ្សែវខ្វារនៃក្រុមបុគ្គលិក-កម្មករ ការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករ ក៏នឹងមានផលប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃដែរ។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងបោះជំរុំការងារនៅនឹងកន្លែង ជ្រៀសវាងការដឹកសំភារៈការងារចុះឡើងបង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។ ក្រុមហ៊ុន នឹងធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃ ។

ក្រុមហ៊ុននឹងសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ជួយណែនាំដល់បុគ្គលិក-កម្មករគំរោងឱ្យមានការយល់ដឹងអំពីច្បាប់និងបំរាមក្នុងការការពារ និងថែរក្សាសត្វព្រៃ ហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេ ដែលប្រព្រឹត្តិខុសទៅនឹងបំរាម។ រីឯម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណា ដែលពាក់ព័ន្ធសត្វព្រៃនោះ ។ ក្រុមហ៊ុននឹងផ្គត់ផ្គង់ស្បៀងទៅតំបន់គំរោងពីកោះកុង។

- **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

នៅដំណាក់ការនៃការគ្រោងរចនា វាអាចប៉ះពាល់បន្តិចបន្តួចដល់ជីវសាស្ត្រដែលរស់នៅក្នុងទឹក ឬមច្ឆជាតិ ដោយសារការបំពុលទឹកមកពីសំណល់រឹង-រាវនៃការស្នាក់នៅរបស់បុគ្គលិក- កម្មករ ។

គំរោងសាងសង់ទំនប់វារីអគ្គីសនីនេះពុំមានរចនាបួងំគំរោងសំរាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី និងដំរកក្រពើភ្នំ នៅពេលដែលគំរោងទាំងមូល នឹងសាងសង់ និងដំណើរការ ។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងអប់រំកម្មករក្នុងការទុកដាក់សំណល់ផ្សេងៗឱ្យបានសមស្រប ដូចជាការជីកកប់ ការញែកសំណល់ដែលអាចប្រើឡើងវិញបានចេញ និងជ្រើសរើសទីតាំងឱ្យឆ្ងាយពីប្រភពទឹកដើម្បីទុកដាក់សំណល់ ការពារកុំឱ្យមានការហូរចូលទៅក្នុងប្រភពទឹកនៅពេលមានភ្លៀង និងតាមរយៈខ្យល់បក់ ។

ក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសំរាប់ឱ្យត្រីឆ្លងកាត់ដោយធ្វើអាងត្រី និងសង់ស្ថានីយ៏ សំរាប់បង្កាត់ពូជត្រី ។ យោងតាមបទពិសោធន៏របស់ក្រុមហ៊ុនចិនបានឱ្យដឹងថា មានតែ ៤០ ស្ថានីយ៏វារីអគ្គិសនីប៉ុណ្ណោះ ក្នុងចំណោមស្ថានីយ៏ វារីអគ្គិសនីរាប់ពាន់ ដែលមានសំណង់សំរាប់ត្រីឆ្លងកាត់ ហើយលទ្ធផលក្នុងការប្រើប្រាស់សំណង់នេះផងដែរ ដូចជាមិនសូវ

ទទួល បានផលល្អទេ។ ដូច្នេះហើយក្រុមហ៊ុនក៏ជ្រើសយកវិធីដូចបានរាយរាប់ខាងលើមកជំនួសវិញ។ (**<u>សំគាល់ៈ</u>** ចំពោះតំលៃនៃសំណង់សម្រាប់ត្រីឆ្លងកាត់បានមានតំលៃរាប់លានដុល្លា ដែលធ្វើឱ្យតំលៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ។ ដោយនៅខាងក្រោមទំនប់ប្រហែល ១.៥ គ.ម. មានល្បាក់ទឹកធ្លាក់ធម្មជាតិមួយកន្លែងដែលមានកំពស់ពី ៥ម. ទៅ ៦ម. ដូច្នេះមិនចាំបាច់សងសំណង់សម្រាប់តីឆ្លងកាត់ត្រីទេ យោងតាមបទពិសោធន៍ ក្នុងប្រទេសចិន។

៥.៣.១.២ ហេតុប៉ះពាល់អវិជ្ជមានមំខោះបរិស្ថានសង្គម និង វិធានការកាត់បន្ថយ

- **ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋានឡើងវិញ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលគ្រោងរចនានេះវាបានបង្កឱ្យប្រជាពលរដ្ឋមានការរំជើបរំជួលចិត្ត មានសតិអារម្មណ៍ខ្លាចបាត់បង់ដីស្រែចំការ និងលំនៅដ្ឋានដោយសារការសាងសង់វារីអគ្គិសនីនេះ ។ អាចមានអ្នកចំណូលថ្មីមកតាំងទីលំនៅតំបន់គំរោងបន្ថែម ដើម្បីកែងចំណេញ ដោយសារការអភិវឌ្ឍន៍នេះ។

ប្រជាពលរដ្ឋអាចមានគំនិតកាប់ឆ្ការដីព្រៃមកកាន់កាប់បន្ថែមដើម្បីទាមទារសំណង ដែលជាមូលហេតុបង្កឱ្យមានការបំផ្លាញព្រៃឈើដោយខុសច្បាប់ និងអាចមានជំលោះផ្សេងៗមកពីការកាន់កាប់ដី។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ ដូចជា អាជ្ញាធរមូលដ្ឋាន មន្ទីរ និងក្រសួងពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពន្យល់ដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ។

ក្រុមហ៊ុននឹងសិក្សារៀបចំធ្វើផែនការផ្តែកការតាំងលំនៅថ្មី ជូនប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ និងជូនដំណឹងដល់សារធារណៈជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុនអំពីគោលបំណងជាក់ស្តែងរបស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍គំរោងនេះនៅពេលអនាគត ។

ជាងនេះទៅទៀតក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ការកាន់កាប់ដីព្រៃបន្ថែម ការកាន់កាប់ដីសាធារណៈរបស់រដ្ឋធ្វើជាកម្មសិទ្ធិផ្តាល់ខ្លួន។

- **ទំនាស់ នៃសិទ្ធិប្រើប្រាស់ដី នៃតំបន់គំរោង**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

នៅពេលទទួលពត៌មានស្តីពីការសាងសង់ទំនប់វារីអគ្គីសនីនេះ ប្រជាជនចាប់ផ្តើមគិតអំពីដី និងការកាន់កាប់ដីរបស់ខ្លួនដែលនឹងត្រូវប៉ះពាល់ នេះហើយជាមូលហេតុនៃជំលោះ ។ ម្យ៉ាងទៀត អាចមានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋក្នុងគោលបំណងចង់ទាមទារផលប្រយោជន៍មិនសមហេតុផល និងបន្ថែមតួលេខដីធ្លីស្រែចំការហើយធ្វើការទាមទារពីក្រុមហ៊ុន ។ ជាងនេះទៅទៀតប្រជាពលរដ្ឋអាចមានគំនិតកាប់ឆ្ការដីព្រៃមកកាន់កាប់បន្ថែម ការកាន់កាប់ដីសាធារណៈរបស់រដ្ឋធ្វើជាកម្មសិទ្ធិខ្លួន ដើម្បីទាមទារសំពោងដែលជាមូលហេតុបង្កឱ្យមានការបំផ្លាញព្រៃឈើដោយខុសច្បាប់ និងអាចមានជំលោះផ្សេងៗមកពីការកាន់កាប់ដី។

Draft

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវអង្កេតដីកម្មសិទ្ធជាក់ស្តែងក្នុងភូមិ-ឃុំតំបន់គំរោង។ ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនឹងត្រូវធ្វើ ដើម្បីទប់ស្កាត់ក្នុងការបំផុសចលនាប្រជាពលរដ្ឋពីជនឆ្លៀត ឱកាសដើម្បីទាមទារដីធ្លី និងសំណងផ្សេងៗ ដែលមិនសមហេតុផល និងមិនយោងទៅតាមច្បាប់។

- **ទំនាស់នៃសិទ្ធិប្រើប្រាស់ទឹកស្ទឹងជាយអារែង**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលនេះ អាចនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅខ្សែទឹកខាងក្រោម ព្រោះមានការបារម្ភខ្លាចពុំមានទឹកប្រើប្រាស់ដូចពីមុន ហើយខ្លាចក្រុមហ៊ុនមិនឱ្យប្រើប្រាស់ទឹកនៅក្រោយពេលសាងសង់វារីអគ្គិសនីរួច។ ម្យ៉ាងទៀតប្រជាជនមានការបារម្ភអំពីការប្រែប្រួលគុណភាពទឹកនៅពេលសាងសង់ និងពេលដំណើរការរបស់គំរោង។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាប្លង់គំរោងដែលអាចធានាការបោះទឹកមកខ្សែទឹកខាងក្រោមឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅរដូវប្រាំងសំរាប់តំរូវការប្រើប្រាស់របស់ប្រជាពលរដ្ឋរស់នៅតាមដងស្ទឹងជាយអារែង និងរក្សាអេកូឡូស៊ីរបស់ស្ទឹងនេះផង។

រីឯបញ្ហាបំពុលទឹក ក្រុមហ៊ុននឹងធ្វើការគ្រោងរចនានូវប្រព័ន្ធការពារកុំឱ្យបំពុលទឹកនៅខាងក្រោមទំនប់ ។ ក្រុមហ៊ុននឹងលាងអាងតែរដូវវស្សា និងកំណត់ពេលវេលាជាក់លាក់ឱ្យប្រជាជនបានដឹងមុនពេលបើកទឹកលាង (នៅក្រោយពេលបិទទំនប់)។

- **ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះអាចមានការខូចខាតផ្លូវបណ្តាលមកពីការដឹកជញ្ជូនធ្ងន់ៗលើផ្លូវសាធារណៈ ដែលអាចមានការប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋ-កម្មករ ឬ ធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគំរោង ដោយសារស្ថានភាពផ្លូវដឹកជញ្ជូនទ្រុឌទ្រោមតូចចង្អៀតមានចំណោទខ្លាំងឆ្លងកាត់ជ្រោះដែលមានផ្ទាំងថ្ម និងភក់ ។ល។ ម្យ៉ាងវិញទៀតការដឹកជញ្ជូនអាចមានគ្រោះថ្នាក់ដោយអ្នកបើកបររថយន្តដឹកគ្រឿងចក្រមិនស្គាល់ផ្លូវច្បាស់។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងរកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គំរោង។ ក្នុងនោះក្រុមហ៊ុននឹងធ្វើការត្រួសត្រាយផ្លូវព្រមទាំងធ្វើស្ពានបណ្តោះអាសន្ន ។ ក្រុមហ៊ុន នឹងប្រើរថយន្តដែលមានសុវត្ថិភាព គុណភាពល្អ និងកំណត់ទំងន់ក្នុងការដឹកជញ្ជូន ដើម្បីការសិក្សាគំរោងនេះ។

Draft

- **សុខភាពសាធារណៈ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពបុគ្គលិកកម្មកររបស់ក្រុមហ៊ុនដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្ទុំ ។ល។ កម្មករអាចនឹងនាំជំងឺចម្លងមកប្រជាពលរដ្ឋនៅតំបន់គំរោងដូចជា ជំងឺកាមរោគ អេដស៍ ធ្លើម និងជំងឺផ្សេងៗមួយចំនួនទៀត ។

ម្យ៉ាងទៀតអាចមានការប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋ-កម្មករ ឬ ធ្វើឱ្យស្ទះការងារសិក្សាបួង់រចនាគំរោងដោយសារស្ថានភាពផ្លូវដីកជញ្ជូនទ្រុឌទ្រោមតូចចង្អៀត ។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិកកម្មករដើម្បីរក្សាក្រមសីលធមិក្នុងការរស់នៅរបស់ខ្លួន ។ ហើយក្រុមហ៊ុននឹងត្រៀមថ្នាំបង្ការដើម្បីការពារ និងព្យាបាលជំងឺឱ្យបានគ្រប់គ្រាន់ ។

ជាងនេះទៅទៀតក្រុមហ៊ុននឹងដាក់បំរាមមិនឱ្យបុគ្គលិកកម្មករចាកចេញទៅក្នុងភូមិ ឬចេញក្រៅតំបន់គំរោងដោយគ្មានការអនុញ្ញាតិពីអ្នកគ្រប់គ្រងឡើយ ។ ក្រុមហ៊ុននឹងប្រើរថយន្តដែលមានទំហំសមស្រប នឹងស្ថានភាពផ្លូវដើម្បីជៀសវាងការគ្រោះថ្នាក់ផ្សេងៗ ។

- **ហានិភ័យ (Risk)**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលនៃការសិក្សានេះអាចនឹងមានគ្រោះថ្នាក់ដោយសារអ្នកសិក្សាមិនដែលស្គាល់ភូមិសាស្ត្រច្បាស់ ដូចជាមានគ្រាប់មីនបង្កប់ក្នុងដី នៅតំបន់អូរសោម ស្រុកវាលវែង ខេត្តពោធិសាត់ ។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការដោះស្រាយអំពីគ្រាប់មីននេះ ។ ហើយក្រុមហ៊ុន នឹងជូលអ្នកស្គាល់ភូមិសាស្ត្រច្បាស់នៅក្នុងតំបន់ឱ្យនាំផ្លូវក្នុងពេលធ្វើការសិក្សា ។

៥.៣.២ ដំណាក់កាលសាងសង់គំរោង (Project Construction)

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់ ៥៤ ខែ (យោងតាមរបាយការណ៍របស់ក្រុមហ៊ុន) ហើយនឹងមានសកម្មភាពសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងជាច្រើន ដូចជា ការឈូសឆាយដី ការសាងសង់ផ្លូវចូលក្នុងការដ្ឋាន ការសាងសង់ទំនប់-ប្រឡាយ អគារផលិតថាមពលអគ្គិសនីសំរាប់ដាក់ទូប៊ីនចំនួន២គ្រឿង អគារការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ។ល។ ព្រមទាំងមានការសាងសង់បង្គោល និង ខ្សែនាំភ្លើងពីអគារផលិតថាមពលទៅអនុស្ថានីយ៍អូរសោម ខេត្តពោធិសាត់ ។ សកម្មភាពការងារទាំងនេះ នឹងអាចបង្កឱ្យមានការប៉ះពាល់អវិជ្ជមានសំខាន់ៗ មួយចំនួនមានដូចតទៅ :

៥.៣.២.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះធនធានរូបសាស្ត្រ និង វិធានការកាត់បន្ថយ

- **សណ្ឋានដី និងឋានលេខា** (Morphology and Topography)

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់នៃការសាងសង់គំរោងនេះអាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោងដោយសារសកម្មភាពឈូសឆាយសំរាប់ចាក់គ្រឹះទំនប់ ឈូសឆាយផ្លូវពីទំនប់ទៅអគារថាមពល ការឈូសឆាយសាងសង់គ្រឹះអគារថាមពលផលិតភ្លើង ការជីកប្រឡាយនាំទឹកទៅអគារថាមពល ការយកដី ការយកថ្ម ពង្រាបដីស្រទាប់លើដែលមានតំរបព្រៃដើម្បីសាងសង់ផ្លូវថ្នល់ ស្ពាន ទំនប់ ប្រឡាយ ការសាងសង់កន្លែងតាំងទីលំនៅថ្មីសំរាប់ផ្លាស់ប្តូរលំនៅដ្ឋានរបស់អ្នកប៉ះពាល់ក្នុងអាងការសាងសង់ កន្លែងយកថ្ម កន្លែងយកដី កន្លែងសាងសង់អគារទីស្នាក់ការ និងផ្ទះបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ។ល។

➢ **វិធានការកាត់បន្ថយ**

បន្ទាប់ពីបញ្ចប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ អគារថាមពល ទំនប់ ប្រឡាយ ការងារដី រួចក្រុមហ៊ុនធ្វើការជួសជុលទីតាំងយកថ្ម កន្លែងយកដី កន្លែងចាក់ដីសំណល់ចោល និងកន្លែងការងារដីផ្សេងទៀត ព្រមទាំងថែទាំ ដាំដើមឈើប្រភេទរុក្ខជាតិស្រទាប់ក្រោមឡើងវិញដើម្បីការពារការហូរច្រោះដី ។

ម្យ៉ាងវិញទៀតក្រុមហ៊ុននឹងធ្វើការសាងសង់នៅរដូវប្រាំង ដើម្បីទប់ស្កាត់ការហូរច្រោះដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា ។ ជាងនេះទៅទៀតក្រុមហ៊ុននឹងមានផែនការថែទាំដើមឈើ និងដាំបន្ថែមដែលជារបាំងនៃការហូរច្រោះ ។

- **ការហូរច្រោះ និងគុណភាពដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់នេះអាចនឹងមានការហូរច្រោះដីដោយសារការឈូសឆាយដី តំរបព្រៃឈើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ព្រោះថា តំបន់នេះជាតំបន់ខ្ពង់រាប មានភ្នំជុំវិញ ដីល្បាយខ្សាច់ នឹងងាយមានការហូរច្រោះជាពិសេសនៅរដូវវស្សា ។ អាចនឹងបង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់ ។ មួយវិញទៀតនោះការចាក់ចោលដីសំណល់ចេញពីការដ្ឋាននៅតំបន់ខ្ពស់វាអាចធ្វើបាត់បង់ជីវជាតិរបស់ដីស្រទាប់លើតំបន់ក្បែរនោះ បណ្តាលមកពីការហូរច្រោះដីសំណល់នេះទៅគ្របពីលើដីតំបន់ជុំវិញនោះទៀតផង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស ។ ក្រុមហ៊ុននឹងរក្សាព្រៃឈើដែលមានស្រាប់នៅតាមមាត់អូរ/ស្ទឹងក្នុងទទឹង១៥០មពីអ័ក្សអូរ (គិតសងខាងសរុប៣០០ម) នៅកន្លែងផ្លាស់ប្តូរលំនៅដ្ឋានថ្មីរបស់អ្នកប៉ះពាល់ក្នុងអាង ។ ក្រុមហ៊ុននឹងធ្វើការសហការជាមួយអាជ្ញាធរដែនដីដើម្បីទប់ស្កាត់ការកាប់ព្រៃនៅតាមមាត់អូរ/ស្ទឹងដែលជាជំរកជីវៈចំរុះជាច្រើនប្រភេទ ។ នៅតាមតំបន់ជំរាលភ្នំ ឬមាត់ទំនប់ដែលគ្មានតំរបព្រៃ ក្រុមហ៊ុននឹងដាំបន្ថែម ដើម្បីការពារសំណើកដី ដែលបណ្តាលមកពីខ្យល់បក់ និងទឹកភ្លៀង ។

ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដី ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី និងដាំកំរាលរុក្ខជាតិស្មៅ ឬកូនឈើតាមជំរាលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោងដើម្បីជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ឈូសអាចដី នឹងធ្វើឡើងនៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក ។

- **ប្រព័ន្ធជលសាស្ត្រ** (Hydrologycal System)

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលនេះ អាចនឹងប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងជាយអារែង ដោយសារការទប់ទំនប់កាត់ស្ទឹងជាយអារែងដើម្បីធ្វើទំនប់ទឹកដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធទឹកផ្សេងទៀតដែលបែកចេញពីស្ទឹង នៅក្រោមទំនប់ ។ គុណភាពទឹកក៏អាចនឹងប៉ះពាល់ផងដែរ ដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុល ជាហេតុបង្កឱ្យប្រជាពលរដ្ឋ ដែលរស់នៅខាងក្រោមមិនអាចប្រើទឹកនេះបាន។

កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅ ផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃគំរោង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬ គ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ អាចបង្កឱ្យទឹកស្ទឹងជាយអារែងបាត់បង់គុណភាពដែរ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងជាយអារែងមានការថយចុះ និងឈានទៅដល់ការបំពុល។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ ។ ក្នុងពេលសាងសង់ ក្រុមហ៊ុននឹងធ្វើការកាត់បន្ថយភាពល្អក់ខ្លាំង ដោយសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់នេះឱ្យបានត្រឹមត្រូវ ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាសាងសង់នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋាននៃការងារដីផ្សេងៗ ដែលអាចហូរចូលស្ទឹង ។ អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការពារការកំពុប/ហៀរប្រេងឥន្ធនៈ ប្រេងរំអិលទៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង។ ក្រុមហ៊ុននឹងឈូសឆាយដី ពង្រាបដីសំរាប់ការសាងសង់ដោយធ្វើទៅតាមលក្ខណៈទំរង់/ប្រភេទដី ដើម្បីទប់ស្កាត់ ឬបន្ថយការហូរច្រោះដីដោយសារសកម្មភាពសាងសង់របស់គំរោង។

ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដី ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី ។ ដាំកំរាលរុក្ខជាតិស្មៅ ឬកូនឈើតាមជំរៀលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោងដើម្បីជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ឈូសឆាយដី នឹងធ្វើឡើង នៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក ។

ក្រុមហ៊ុននឹងសាងសង់បន្ទប់ទឹក និងបង្គន់ឱ្យបានគ្រាន់ទៅតាមចំនួនកម្មករ បុគ្គលិកគំរោង ដោយមានអាងសិបទឹកត្រឹមត្រូវ ហើយឆ្ងាយពីប្រភពទឹកឱ្យបានយ៉ាងតិច១00 ម។

- **ការរញ្ជួយដី** (Seismology)

  - **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងព្រះសង្ឃ ផ្លូវចេញចូលសំណង់ សុវត្ថិភាពកម្មករ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគំរោង ដោយសារមានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារឈូសឆាយពង្រាបដី ការកាយដីធ្វើប្រឡាយ ការស្ថាបនាផ្លូវ ការដឹកសំភារៈសំណង់/កម្មករ ការលាយបេតុង ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ។ ល។

ការប្រើប្រាស់គ្រឿងផ្ទុះក៏អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដែលចូលព្រៃដើម្បីរកអនុផលព្រៃឈើដែរ ។

➢ **ទិដ្ឋានការគាត់បន្តុយ**

ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់ រួចដាក់ផ្ទាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។

ការប្រើប្រាស់គ្រឿងផ្ទុះ គឺក្រុមហ៊ុននឹងកំណត់កិរិតរញួយ និងកំលាំងបំផ្ទុះឱ្យតូច ដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬសំណង់ផ្ទះប្រជាជន ឬ ផ្លូវដែលនៅក្បែរតំបន់បំផ្ទុះឡើយ។

ផ្តល់ពត៌មានផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ ។ ការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល(ម៉ោង ៤:00-៥:00) ។

- **ការបំពុលខ្យល់**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់នេះ អាចនឹងបំពុលខ្យល់ដោយសារផ្សែង និងធូលីដីបំភាយចេញពី ការដឹកសំភារៈសំណង់ រថយន្តម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារឈូសឆាយពង្រាបដី កាយដី/ជីកដីធ្វើប្រឡាយ/ការជីកឬខួងធ្វើទូនេល ការស្ថាបនាផ្លូវ ការបំផ្ទុះថ្មធ្វើគ្រឹះទំនប់ ការដុតព្រៃឈើដើម្បីសំអាតការដ្ឋានសំរាប់ការងារសាងសង់របស់គំរោង និងភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែស។

➢ **ទិដ្ឋានការគាត់បន្តុយ**

ក្រុមហ៊ុននឹងប្រើគ្រឿងយន្ត ឬគ្រឿងចក្រណាដែលមានផ្សែងតិចក្នុងពេលសាងសង់នេះ ហើយនៅពេលសាងសង់នេះផងដែរក្រុមហ៊ុននឹងបាញ់ទឹកដើម្បីការពារធូលីដីហុយដើម្បីកាត់បន្តុយការបំពុលខ្យល់។

ចំពោះព្រៃឈើវិញក្រុមហ៊ុនមិនដុតទាំងអស់នោះទេ គឺក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីដាក់ឱ្យក្រុមហ៊ុនកែច្នៃឈើដេញថ្លៃដើម្បីប្រើឈើទាំងនោះឱ្យអស់លទ្ធភាព ធ្វើយ៉ាងនេះអាចចំណេញប្រាក់ផង និងកាត់បន្តុយការបំពុលបរិយាកាសផង។

- ចំពោះការបំពុលខ្យល់ដោយសារធាតុផ្ទុះ ក្រុមហ៊ុននឹងជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង។
  ក្រុមហ៊ុននឹងត្រៀមឧបករណ៍ពន្លត់អគ្គីភ័យ និងមានកន្លែងបូម ទឹកគ្រប់គ្រាន់នៅពេលមានអគ្គីភ័យ ។

- **ការបំពុលទឹក**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការបំពុលគុណភាពទឹកអាចនឹងមាននៅនឹងស្ទឹងជាយអារែងដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង ការងារជីកឬខួងធ្វើទូនេល និងការងារបំផ្ទុះថ្មនៅក្បែរប្រភពទឹក។

អាចនឹងមានការប៉ះពាល់គុណភាពទឹកស្ទឹងដោយសារកាកសំណល់រឹង-រាវមកពីផ្ទះបាយ សំភារៈសំណង់ដោយបុគ្គលិក-កម្មករ ការហូរច្រោះដីដោយសារការឈូសឆាយគំរបព្រៃធ្វើហេដ្ឋារចនាសម្ព័ន្ធគំរោង ការបំភាយធូលីដីពីការដឹកជញ្ជូន និងការងារដីផ្សេងៗដើម្បីសាងសង់។ លើសពីនេះទៀតផងដែរព្រោះអាចនឹងមានការបំពុលដល់ទឹកស្ទឹង បើកុងសកម្មភាពសាងសង់ហេដ្ឋា

រចនាសម្ព័ន្ធរបស់គំរោងនេះមិនមានការគ្រប់គ្រងបានល្អនូវប្រេងឥន្ធនៈ សារធាតុគីមី សំណល់សំភារៈសំណង់ សំណល់រឹង-រាវគ្រប់ប្រភេទចេញ ឬធ្លាយពីគ្រឿងចក្រ រថយន្តទៅក្នុង ឬក្បែរតំបន់ប្រភពទឹក។

នាពេលសាងសង់ក្រុមហ៊ុនមានបុគ្គលិក-កម្មករមានចំនួនអតិបរមាប្រហែល ១២០០នាក់ បានប្រើប្រាស់ទឹកស្ទឹងជាយអារែងក្នុងរូបភាព ដូចជា ការបន្ទោរបង់ ការងូត ការបោកសំលៀកបំពាក់ ការលាងឧបករណ៍ផ្សេងៗ បន្ទាប់ពីការងារប្រចាំថ្ងៃអាចនឹងបង្កឱ្យ មានការបំពុលទឹកផងដែរ។

ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាល ធ្វើឱ្យមានការហូរច្រោះចូលទៅក្នុងប្រភពទឹកនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់ទៅលើប្រភពទឹកនៅរដូវប្រាំងក៏បានធ្វើមានការបំពុលទឹកដែរ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនមានផែនការធ្វើការឈូសឆាយទ្រង់ទ្រាយធំនៅរដូវប្រាំងមិនធ្វើនៅរដូវវស្សាទេ និងធ្វើរបាំងការពារកកកុរដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ជាពិសេសនោះក្រុមហ៊ុននឹងធ្វើការអប់រំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ បន្ទប់ទឹកឱ្យគ្រប់គ្រាន់ព្រមទាំង រៀបចំឧបករណ៍ប្រមូលសំណល់រឹងយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពឆ្ងាយពីប្រភពទឹក។

ក្នុងនោះក៏មានការសាងសង់អាងប្រព្រឹត្តិកម្មសំអាតទឹកក្រខ្ចក់ (អាងសិបទឹកទំនើប) ដែលបង្ហូរចេញពីការិយាល័យ ផ្ទះបុគ្គលិកដែលស្នាក់នៅសំរាប់ប្រើក្នុងពេលសាងសងរហូតដល់ធ្វើប្រតិបត្តិការ និងថែទាំគំរោង។

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ តាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។ ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គំរោង។

បន្ថែមពីលើនោះក្រុមហ៊ុននឹងដាំព្រៃឈើឡើងវិញតាមកន្លែងចាក់ចោលដីស្មុយ កន្លែងយកដី និងថ្ម ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។

- **ការបំពុលដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

— ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងមានការបំពុលដី ដោយសារការកំពុបនៃប្រេងឥន្ធនៈ ការកំពុបនៃសារធាតុគីមី ការចោលសំណល់រឹង-រាវគ្រប់ប្រភេទដែលចេញឬធ្លាយពីគ្រឿងចក្ររថយន្ត សំណល់សំភារៈសំណង់ ។ល។ រួមទាំងកាកសំណល់ចេញពីផ្ទះបាយផងដែរ ក្នុងពេលដំណើរការគំរោងនេះ។

នៅក្នុងដំណាក់សាងសង់នេះបានបង្កឱ្យមានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរ ដោយសារការចាក់ដីស្មុយដែលដឹកចេញពីតំបន់គំរោង។

អាចនឹងមានការបំពុលដីដោយសារការគ្រប់គ្រងនូវសារធាតុផ្ទុះមិនបានល្អធ្វើឱ្យធ្លាក់ទៅលើដីនៅពេលរៀបចំធ្វើការបំផ្ទុះដើម្បីធ្វើការសាងសង់ទំនប់។ ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាល ធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណើក ដោយសារខ្យល់នៅរដូវប្រាំងក៏បានធ្វើដីបាត់បង់គុណភាពដែរ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពុប ឬជ្រាបចូលដី ។ គ្រប់គ្រងកាកសំណល់រឹង-រាវ គ្រប់ប្រភេទឱ្យបានត្រឹមត្រូវ ដូចជា ចាត់វិធានការយ៉ាងតឹងរឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី ។

សំណល់រឹង-រាវចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅក្នុងពេលធ្វើការសាងសង់ ប្រតិបត្តិ និងថែទាំគំរោង មិនត្រូវបង្ហូរចេញទៅលើដីដោយមិនទាន់ធ្វើប្រព្រឹត្តិកម្មនោះទេ ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មដើម្បីសំណល់រាវទាំងនេះ ហើយប្រុងប្រយត័កុំឱ្យមានការបំពុលដី និងប្រភពទឹក ហើយស្វែងរកទីតាំងសមស្របសំរាប់ទុកដាក់សំណល់រឹង ។

ក្រុមហ៊ុននឹងដាំព្រៃឈើឡើងវិញតាមកន្លែងចាក់ចោលដីស្មុយ ជាជំរើសមួយល្អដែលក្រុមហ៊ុននឹងអនុវត្តនៅកន្លែងយកដី យកថ្ម ចាក់ដីស្មុយ ដើម្បីការពារការហូរច្រោះ ដែលអាចធ្វើឱ្យមានការបំពុលដីនៅក្បែរនោះ ។

- **សំលេង និងរំញ័រ**

➢ **ហេតុប៉ះពាល់អត្ថិភូមាន**

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និង ពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំង គំរោងដោយសារ មានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ។ ល។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំលេងតិច ។

ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់រួចដាក់ផ្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់ ។

ក្រុមហ៊ុននឹងកំណត់ក៏រិតរញ្ជួយនិងកំលាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬ សំណង់ផ្ទះប្រជាជន ឬ ផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ ។

ក្រុមហ៊ុននឹងផ្តល់ពត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន នូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ ។

ចំពោះការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅចន្លោះម៉ោង ៤:00 ទៅ ៥:00ល្ងាច ពីព្រោះនៅវេលានេះប្រជាពលរដ្ឋបានិសំរាកពីការងារនៅឯស្រែចំការ និងតាមព្រៃហើយ ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះដើម្បីកាត់បន្ថយការរំខានដល់ប្រជាពលរដ្ឋនិងសត្វព្រៃក្នុងតំបន់ គំរោងនេះ ។

៥.៣.២.២ ហេតុប៉ះពាល់អវិជ្ជមានចំពោះឧទ្ធានអេកូឡូស៊ី និង វិធានការកាត់បន្ថយ

- **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

➢ ហេតុប៉ះពាល់អត្ថិភូមាន

នៅពេលសាងសង់ទំនប់អាចប៉ះពាល់ដល់ផ្លូវចេញចូល និងធារទឹកសំរាប់ការរស់របស់មច្ឆាជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្នកាត់ស្ទឹងជាយអារែង ដើម្បីសាងសង់ទំនប់វារីអគ្គីសនីនេះ ។ ជាងនេះទៅទៀតវាក៏

បង្កឱ្យមច្ចជាតិ និងជីវសាស្ត្រនៅក្នុងទឹកអាចងាប់បានដែរ ដោយសារការធ្វើឱ្យល្អក់ទឹកបណ្តាលមកពីសកម្មភាពសាងសង់តំរោង និងបំពុលទឹកដោយសារការបោះកាកសំណល់រឹង-រាវចេញពីការសាងសង់ ចូលទៅក្នុងស្ទឹង។

ពិតណាស់ស្ទឹងជាយអារំងមានប្រភេទត្រីនាគរស់នៅតាមខ្សែទឹកខាងក្រោមនៃទំនប់ Site A និងនៅខ្សែទឹកខាងលើនៃអគារចាមពលនឹងត្រូវរងគ្រោះដោយសារកង្វះទឹក និងការបំពុលទឹកពីការដ្ឋានសាងសង់បើមិនមានការយកចិត្តទុកដាក់ទេនោះ។

➢ **វិធានការគាត់បន្តុយ**

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដែលមានសណ្ឋានដូចផ្លូវទឹកចាស់ (មិនចោទ) ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរនៃជីវសាស្ត្រក្នុងទឹកពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋានដើម្បីផ្តល់ទឹកឱ្យគ្រប់គ្រាន់ដល់ផ្នែកខាងក្រោម។ អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការការពារកំពុបប្រែងឥន្ធនៈ ប្រែងរំអិលនៅលើដី និងក្នុងទឹកក្នុងតំបន់តំរោង ។

ក្រុមហ៊ុននឹងគ្រប់គ្រង ការពារសំណល់រឹង-រាវគ្រប់ប្រភេទ ដោយរៀបចំប្រមូលសំណល់រឹង និងសំរាម ដុតបំផ្លាញចោលនៅទីតាំងដែលមានសុវត្ថិភាព ។ ក្រុមហ៊ុននឹងណែនាំអប់រំដល់បុគ្គលិក- កម្មករអំពីការបោះបង់កាកសំណល់រឹង-សំណល់រាវជាពិសេសការកំពុបប្រែង ឥន្ធនៈ ប្រែងរំអិលនៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់តំរោង។

ក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសំរាប់ឱ្យត្រីឆ្លងកាត់ដោយធ្វើអាងត្រី និងសង់ស្ថានីយ៍សំរាប់ បង្កាត់ពូជត្រី។ យោងតាមបទពិសោធន៍របស់ក្រុមហ៊ុនចិនបានឱ្យដឹងថាមានតែ ៤០ ស្ថានីយ៍វារីអគ្គិសនីប៉ុណ្ណោះក្នុងចំណោមស្ថានីយ៍វារីអគ្គិសនីរាប់ពាន់ដែលមានសំណង់សំរាប់ត្រីឆ្លង់កាត់ ហើយលទ្ធផលក្នុងការប្រើប្រាស់សំណង់នេះផងដែរ ដូចជាមិនសូវទទួលបានផលល្អទេ។ ដូច្នេះហើយក្រុមហ៊ុនក៏ជ្រើសយកវិធីដូចបានរាយរាប់ខាងលើមកជំនួសវិញ។ រីឯបញ្ហាប៉ះពាល់ដល់ទីជំរកសត្វក្រពើភ្នំវិញ ក្រុមហ៊ុន នឹងសហការជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទីជំរកថ្មីសំរាប់សត្វក្រពើភ្នំ និងកូនក្រពើអាចរស់ នៅ និងបន្តពូជបានមុននឹងបំពេញទឹកក្នុងអាង។

- **ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងប៉ះពាល់ដល់ផ្ទៃដីសរុប ១២.៣២៥.៣៧ហ.ត ក្នុងនោះមានព្រៃស្រោង ៣.០៦៧ ហ.ត (៥៩ប្រភេទ) ៣ក់កណ្តាលស្រោង ៣.៧៩០ ហ.ត (៤៣ប្រភេទ) ព្រៃល្បោះ ៣៧ ហ.ត (២៦ ប្រភេទ) ព្រៃគុម្ពោធ ១០ ហ.ត ព្រៃដុះឡើងវិញ ១.១៣៣.៣៧ ហ.ត (៤១ប្រភេទ) និងព្រៃល្បាយឫស្សី ៤ ហ.ត (១៩ប្រភេទ)។

ព្រៃឈើទាំងនេះជាជំរកសត្វព្រៃក្នុងតំបន់ជាច្រើនប្រភេទដូចមានចែងក្នុងជំពូក ៤ ចំណុច ៤.២.៥.៣ នេះដែលជាការព្រួយបារម្ភ និងសោកស្តាយរបស់ប្រជាជន និងរាជរដ្ឋាភិបាលចំពោះសម្បត្តិធនធានធម្មជាតិរបស់កម្ពុជា ។

➢ **វិធានការគាត់បន្តុយ**

ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញ នៅក្នុងបង់រចនាតំរោងលំអិតឡើយ។ ធ្វើការប្រឹក្សាជាមួយអង្គការអភិរក្សអន្តរជាតិ (CI) និងអង្គការនានាដែលពាក់ព័ន្ធ រកទីតាំងសមស្របក្នុងតំបន់ស្បែរព្រៃដែលបាត់បង់ ដោយសារសកម្មភាពតំរោង សំរាប់ដាំឈើទុកជាជំរកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះ ។ ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួង បរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលនឹងកើតមានឡើងជាយថាហេតុ លើព្រៃពេលីដែលនៅជាប់នឹងតំបន់តំរោងក្នុងដំណាក់កាលនៃការសាងសង់នេះ។

ក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីបង់ពន្ធជូនរដ្ឋតាមច្បាប់ព្រៃឈើ ។

ក្រុមហ៊ុននឹងទុកព្រៃតាមដងអូរ ១៥០ម ចេញពីអ័ក្សអូរ (សរុប៣០០ម) នៅតំបន់តាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ ហើយទុករបៀងសត្វ ៣០០ម ភ្ជាប់ពីភ្នំទៅព្រៃការពារនៅក្បែរនោះ (មើលផែនទីលេខ៤) ។ នៅកន្លែងការពារព្រៃតាមដងអូរ និងរបៀងសត្វព្រៃនេះ ក្រុមហ៊ុននឹងសហការជាមួយអង្គការ CI បោះព្រំប្រទល់ និង ដាក់ផ្ទាកសញ្ញាព្រៃការពារ ដើម្បីឱ្យប្រជាពលរដ្ឋងាយមើលឃើញ ។

- **ជីវសាស្ត្រសត្វព្រៃ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

តំបន់គំរោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្ស ដូចជា ថនិកសត្វចំនួន ៥៣ប្រភេទ បក្សី១១៣ប្រភេទ ឧរង្គសត្វ ៣១ប្រភេទ មច្ឆជាតិ ៤៣ប្រភេទ ដូចមានចែងក្នុងជំពូក៤ ចំណុច ៤.២.៦ ។ សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ វារីអគ្គិសនី នេះអាចមានការបាត់បង់ ឬថយចុះនូវសត្វព្រៃមួយចំនួន ដូចជា ពង្រួល ដំរី ឈ្លូស ប្រីស កាំប្រម៉ា ក្រពើ ពពួកពស់ ជ្រូកព្រៃ ជាដើម ដោយសារបាត់ទីជំរក ឬផ្តាច់ផ្លូវទំនាក់ទំនងរបស់វា ។

អាចនឹងនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗចេញពីម៉ាស៊ីន គ្រឿងយន្តពេលកាប់ឆ្ការគំរបព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសំភារៈសាងសង់ និងសំឡេងរបស់បុគ្គលិក-កម្មករគំរោង ។ ក្នុងនោះការជ្រើសរើសនូវបុគ្គលិក-កម្មកររាប់រយនាក់ចូលមកធ្វើការនៅតំបន់នេះសំរាប់ការសាងសង់គំរោង នឹងអាចមានសកម្មភាពបរបាញ់ ឬចាប់សត្វព្រៃពីសំណាក់បុគ្គលិក-កម្មករគំរោងទាំងនោះ ។ <u>សំគាល់</u>: នៅផ្នែកមួយនៃតំបន់តាំងទីលំនៅថ្មីមានរបៀងសត្វដីរដែលពួកវាធ្លាប់ចេញចូលរកស៊ីតំបន់នោះ ការយកតំបន់នេះធ្វើកន្លែងតាំងទីលំនៅថ្មីរបស់ប្រជាជនដែលប៉ះពាល់ក្នុងអាងក៏អាចមានការប៉ះពាល់ដល់ដីរដែរ ក៏ប៉ុន្តែតាមការបញ្ជាក់ពី CI គឺសត្វដីរអាចផ្លាស់ប្តូរទៅតំបន់ជាប់នេះ ពីព្រោះវាជាតំបន់ការពារអភិរក្សភ្នំក្រវាញ ។ ទោះជាយ៉ាងនេះក្តីអាចមានការទំនាស់រវាងមនុស្ស និងដីរដោយសារប្រជាជនអាចដាំដំណាំ ឬធ្វើការប្រមាញ់ដីរ រីឯដីរអាចចូលស៊ីដំណាំរបស់ប្រជាជនវិញ ។

  - **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសំរាប់ការការពារបរិស្ថាន ដូចជា ការធ្វើទីជំរកសត្វក្រពើ បង្កើនការទប់ស្កាត់ ការពារ និងថែរក្សាសត្វព្រៃ ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រដើម្បី កុំឱ្យមានការរំខាន ឬ ផ្ញើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ជិតគំរោង។ ចំពោះសំឡេងរំញ័រវិញក្រុមហ៊ុននឹងកំណត់ការិតរញួយ ព្រមទាំងកំលាំងបំផ្ទុះ ហើយប្រើប្រាស់ម៉ាស៊ីន ដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនោះ ។

ក្រុមហ៊ុននឹងសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ជួយណែនាំ អប់រំដល់បុគ្គលិក-កម្មករគំរោងឱ្យមានការយល់ដឹងអំពីច្បាប់ និងបំរាមក្នុងការការពារ ការថែរក្សាសត្វព្រៃ ហើយដាក់វិន័យយ៉ាងតឹងរឹងដល់ពួកគេដែលប្រព្រឹត្តខុសទៅនឹងបំរាម ។ រីឯម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ ក្រុមហ៊ុននឹងផ្តត់ផ្គង់ស្បៀងទៅតំបន់គំរោងពីកោះកុង ។

ក្រុមហ៊ុននឹងទុកព្រៃតាមដងអូរ ១៥០ម ចេញពីអ័ក្សអូរ (សរុប៣០០ម) នៅតំបន់តាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ ហើយទុករបៀងសត្វ ៣០០ម ភ្ជាប់ពីភ្នំទៅព្រៃការពារនៅក្បែរនោះ (មើលផែនទីលេខ៤) ។ នៅកន្លែងការពារព្រៃតាមដងអូរ និងរបៀងសត្វព្រៃនេះ ក្រុមហ៊ុននឹងសហការជាមួយអង្គការ CI បោះព្រំប្រទល់ និង ដាក់ផ្ទាំកសញ្ញាព្រៃការពារ ដើម្បីឱ្យប្រជាពលរដ្ឋងាយមើលឃើញ ។

ក្រុមហ៊ុននឹងផ្តល់មូលនិធិការពារបរិស្ថានឱ្យបានគ្រប់គ្រាន់ ហើយធ្វើការសហការជាមួយ CI ដើម្បីពង្រឹងបន្ថែមកងកំលាំងអនុរក្ស (Ranger) ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ ។

- **តំបន់អភិរក្សភ្នំក្រវាញកណ្តាល ក្រវាញខាងត្បូង និង ពាមក្រសោប**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងមានការប៉ះពាល់ដល់តំបន់អភិរក្សធនធានធម្មជាតិ ភ្នំក្រវាញកណ្តាលចំនួន ៣.៩៤៨ ហ.ត (ប៉ះក្នុងអាង និងខ្សែចម្ងង ៥៦ហ.ត) ក្រវាញខាងត្បូង ចំនួន ១៨៦ហ.ត (ប៉ះខ្សែចម្ងង) និងពាមក្រសោបចំនួន ០.៦ហ.ត (ប៉ះខ្សែចម្ងង) ដោយសារគំរោងសាងសង់ទំនប់វារីអគ្គីសនីស្ថិតនៅក្នុងទឹកដីនៃតំបន់អភិរក្សនេះ ដែលនឹងបង្កឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នេះ ។

ការបំពុលបរិស្ថាននឹងអាចមាននៅក្នុងតំបន់អភិរក្ស និងការពារធនធានធម្មជាតិទាំងនេះ ដូចជា ការបំពុលខ្យល់ បំពុលទឹក ដោយសារសំណល់បញ្ចេញចោលពីកន្លែងសាងសង់ និង ចេញពីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ កន្លែងស្តុកគ្រឿងនិងសំភារៈសំណង់ និងពីគ្រឿងចក្រ ។

អាចមានការទន្ទ្រានចូលក្នុងព្រៃនៃតំបន់ទាំងនេះពីសំណាកក្រុមកម្មករក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វធ្វើម្ហូប ឬធ្វើអាជីវកម្ម។ ជាងនោះទៅទៀតអាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃ ដីតំបន់អភិរក្សទាំងនេះ ពីសំណាក់ជនឆ្លៀតឱកាសដោយសារគំរោងធ្វើផ្លូវនៃតន្លងខ្សែចម្ងង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគំរោង ។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសំរាប់ការ ការពារបរិស្ថាន ដូចជា ការធ្វើទីជំរកសត្វក្រពើ បង្កើនការទប់ស្កាត់ ការពារ និង ថែរក្សាសត្វព្រៃ ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្តើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ។ ដូច្នោះក្រុមហ៊ុននឹងកំណត់ការិតរញួយ កំលាំងបំផុះ និងប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង រំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ។

ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យសំរាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់គំរោង ។ ក្រុមហ៊ុននឹងដាក់វិធានការក្នុងការរៀបចំការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវមានសុវត្ថិភាព ជាពិសេសមិនឱ្យបំពុលបរិស្ថានក្នុងនិងក្បែរតំបន់អភិរក្សទាំងនោះ ។

ក្រុមហ៊ុននឹងធ្វើការអប់រំ និងដាក់វិន័យដល់កម្មករគំរោងរូបណា ដែលធ្វើការទន្ទ្រានព្រៃក្នុងតំបន់អភិរក្សទាំងនោះ ដើម្បីចាប់ ឬបរបាញ់ ចរាចរឈើ និងសត្វព្រៃដោយសហការជាមួយរដ្ឋបាលព្រៃឈើ អ្នកតំណាងពីក្រសួងបរិស្ថាន ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរំលោភកាន់កាប់ដីនៅតំបន់អភិរក្សទាំងនោះ ។ ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំ និងដាក់វិន័យដល់កម្មករគំរោង មិនឱ្យធ្វើការទន្ទ្រានព្រៃដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ហើយសហការជាមួយតំណាងពីក្រសួងបរិស្ថាន ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរំលោភកាន់កាប់ដីព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។

៥.៣.២.៣ ហេតុប៉ះពាល់អវិជ្ជមានចំពោះបរិស្ថានសង្គម/សេដ្ឋកិច្ច និង វិធានការកាត់បន្ថយ

- **ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋាន ឡើងវិញ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋ ដែលរស់នៅខាងលើ និងខាងក្រោមនៃទំនប់ Site A ចំនួន ២.៦២៤ ហ.ត ដែលកាន់កាប់ដោយ ៣៨៩ គ្រួសារ ព្រោះតែការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង។ ជាងនេះទៅទៀត នឹងមានការជំលៀសប្រពលរដ្ឋទៅនៅកន្លែងតាំងទីលំនៅថ្មីចំនួន ១៨៩ គ្រួសារ ត្រូវជា ៨៩៩ នាក់ ដោយសារនៅពេលដំណើរការគំរោងមានការលិចលង់ដីក្នុងអាងចំនួន ៥.៤៧៤ ហ.ត ។

ការតាំងទីលំនៅថ្មីនេះដែរ នឹងមានការកាប់ព្រៃ ឈូសឆាយ ពង្រាបដី ដើម្បីធ្វើផ្ទះ អាចបង្កឱ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិខ្លះដូចជា ព្រៃឈើ និងសត្វព្រៃ។

  - **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងរៀបចំផែនការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង រួមទាំងមានសំណងត្រឹមត្រូវ និងយុត្តិធម៌ ។

ក្រុមហ៊ុននឹងមិនទន្ទ្រានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ដោយសន្តិវិធី (យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង ៣០) ឡើយដូចជា : ដីភូមិ ដីចំការ និងដីសហគមន៍ ។ ក្រុមហ៊ុននឹងរៀបចំកន្លែងតាំងទីលំនៅថ្មីដែលមានទីតាំងនៅក្បែរគំរោងនេះ ហើយមានស្ថានភាពភូមិសាស្ត្រប្រហាក់ប្រហែលកន្លែងដែលគាត់ធ្លាប់រស់នៅ ។ នៅក្នុងកន្លែងតាំងលំនៅថ្មីនេះក្រុមហ៊ុននឹងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទឱ្យបានប្រសើរ ជាងកន្លែងដែលគាត់ធ្លាប់រស់នៅ។

ដើម្បីឱ្យប្រជពលរដ្ឋដែលតាំងទីលំនៅថ្មី និងប្រជាពលរដ្ឋរស់នៅក្បែរតំបន់គំរោងមានការរស់នៅថ្លៃថ្នូរ និងងាយស្រួលក្រុមហ៊ុននឹងធ្វើការផ្គត់ផ្គង់អគ្គិសនីជូនតំបន់នោះ និងភូមិនៅជុំវិញទីតាំងគំរោង ដោយមានតំលៃសមស្រប។

ចំពោះដីធ្លីរបស់ប្រជាពលរដ្ឋវិញ ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តទៅតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាល និងសម្របសម្រួលនូវទំនាស់ដីធ្លីទាំងឡាយណា ដែលកើតមានដោយសារសកម្មភាពសាងសង់គំរោងនេះ ។ ការជ្រើសរើទីតាំងថ្មីនេះ នឹងត្រូវសហការជាមួយរដ្ឋាបាលព្រៃឈើ អាជ្ញាធរដែនដី មន្ទីដែនដីនគរូបនីយកំម្ម និងមន្ទីបរិស្ថានដើម្បីរកទីតាំងណាដែលសមស្រប។

បន្ថែមពីលើនេះទៀតក្រុមហ៊ុននឹងឱ្យអាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោង ដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង។

- **ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន**

➢ **ហេតុប៉ះពាល់អតិថិជូមាន**

អាចនឹងមានផលប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយសារក្រុមហ៊ុនដំលៀសប្រជាពលរដ្ឋទៅនៅទីកន្លែងតាំងលំនៅថ្មី ដែលមិនទាន់បានអភិវឌ្ឍន៍សមស្របតាមផែនការនៃការតាំងលំនៅដ្ឋានថ្មី ។ ប្រជាពលរដ្ឋនៅក្នុងតំបន់នេះនឹងមានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួនផងដែរ នៅពេលមានការតវ៉ាអំពីសិទ្ធិរស់នៅ និងកិច្ចសន្យាដែលបានចែងក្នុងផែនការនៃការតាំងលំនៅដ្ឋានឡើងវិញនេះ ។ រីឯមុខរបរ និងការងារវិញត្រូវបានបាត់បង់ដោយសារគ្មានដីធ្វើស្រែចំការ និងចំណាយពេលតែរៀបចំផ្ទះសម្បែងនៅទីតាំងថ្មី។

➢ **វិធានការគាត់បន្តួយ**

ក្រុមហ៊ុននឹងសហការជាមួយអង្គការពាក់ព័ន្ធនានាដូចជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ន ក្រសួងពាក់ព័ន្ធ ដែលតំណាងឱ្យរាជរដ្ឋាភិបាលធ្វើការដោះស្រាយ និងគោរពតាមផែនការតាំងទីលំនៅដ្ឋានថ្មីឡើងវិញ។

ក្រុមហ៊ុននឹងឱ្យអាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោងដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង ។ ហើយក្រុមហ៊ុននឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដី ផ្សព្វផ្សាយ អំពីគោលបំណង និងគោលការណ៍ផ្តល់សំណង នៃការប៉ះពាល់ដោយសារគំរោងនេះ។

- **ប្រពៃណី វប្បធម៌ និង សាសនា**

➢ **ហេតុប៉ះពាល់អតិថិជូមាន**

អាចនឹងមានការប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងសាសនារបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ដោយសារក្រុមហ៊ុនយកបុគលិក-កម្មកររបស់ខ្លួនដែលមកពីតំបន់ឆ្ងាយខុសៗគ្នា ។

អាចនឹងមានការប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយរបស់ប្រជាពលរដ្ឋ ដូចជា ព្រៃអ្នកតា ឬទីទួល ព្រៃកប់ខ្មោច រូបសំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ល។ ដោយសារក្រុមហ៊ុនធ្វើការក្បាប់ឆ្ការដីព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។

អាចមានការប៉ះពាល់ដល់ប្រពៃណីវប្បធម៌របស់បុគ្គលិកកម្មករគំរោង ដែលមានប្រពៃណី វប្បធម៌ និងភាសាខុសគ្នា ដោយសារក្រុមហ៊ុនមានកម្មករចិន និងខ្មែរធ្វើការនៅពេលសាងសង់នេះ អាចកើតមានទំនាស់រវាងជនជាតិទាំងពីរនេះ ។

➢ **វិធានការគាត់បន្តួយ**

ក្រុមហ៊ុននឹងសិក្សាស្វែងយល់អំពីទំនៀមទំលាប់ ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ដោយធ្វើការផ្សព្វផ្សាយ ហើយនឹងអប់រំណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួន អំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់ ដោយមិនធ្វើការបំពាន និងល្មើសឡើយ ។

ជាពិសេសក្រុមហ៊ុននឹងសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតកន្លែងសក្ការៈបូជាទាំងឡាយនោះឡើងវិញ ដូចដែលមានកន្លងមកនៅភូមិរបស់គាត់ ។

ក្រុមហ៊ុននឹងសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ដើម្បីរកដំណោះស្រាយឱ្យបានសមស្រប នៅពេលមានទំនាស់រវាងជនជាតិទាំងពីរនេះកើតមានឡើង ។

- **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

➢ **ហេតុប៉ះពាល់អតិថិជន**

អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកស្ទឹង ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង និងគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អ ធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដី ដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកប្រជាពលរដ្ឋក្នុងតំបន់។

បរិមាណធារទឹករបស់ស្ទឹងជាយអារែងអាចនឹងប៉ះពាល់ ដោយសារការទប់ទំនប់កាត់ស្ទឹងជាយអារែងដើម្បីធ្វើអាងតំកល់ទឹកដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធទឹកផ្សេងទៀតដែលបែកចេញពីស្ទឹងនៅក្រោមទំនប់។ គុណភាពទឹកក៏អាចនឹងប៉ះពាល់ផងដែរ ដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុលជាហេតុបង្កឱ្យប្រជាពលរដ្ឋដែលរស់នៅខាងក្រោមមិនអាចប្រើទឹកនេះបាន។

កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃគំរោង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ អាចបង្កឱ្យទឹកស្ទឹងជាយអារែងបាត់បង់គុណភាពដែរ ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងជាយអារែងមានការថយចុះ និងឈានទៅដល់ការបំពុល។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វែរការដ្ឋានដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ ហើយនឹងសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់ ដើម្បីធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ទឹកខ្លាំង ។

ក្រុមហ៊ុននឹងសាងសង់ នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋាននៃការងារដីផ្សេងៗ ដែលអាចហូរចូលស្ទឹង ។ អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការពារការកំពុប/ហៀរប្រេងឥន្ធនៈ ប្រេងរំអិលទៅលើដីដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង។ ក្រុមហ៊ុននឹងឈូសឆាយដី ពង្រាបដី សំរាប់ការសាងសង់ដោយធ្វើទៅតាមលក្ខណៈទំរង់/ប្រភេទដី ដើម្បីទប់ស្កាត់ ឬបន្ថយការហូរច្រោះដីដោយសារសកម្មភាពសាងសង់របស់គំរោង។

ក្រុមហ៊ុននឹងសាងសង់បន្ទប់ទឹក និងបង្គន់អនាម័យឱ្យគ្រប់គ្រាន់ទៅតាមចំនួនមនុស្ស ដោយមានអាងសិបទឹកត្រឹមត្រូវ ហើយឆ្ងាយពីប្រភពទឹកចំងាយ ១០០ម យ៉ាងតិច ។

ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដី ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី ។ ដាំកំរាលរុក្ខជាតិស្មៅ ឬកូនឈើតាមជំរាលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោងដើម្បីជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ឈូសឆាយដី នឹងធ្វើឡើង នៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក។

- **រមណីយដ្ឋាន/ទីកន្លែងកំសាន្ត (ចរាចរ)**

➢ **ហេតុប៉ះពាល់អតិថិជន**

ការមកលេងកំសាន្តរបស់ភ្ញៀវទេសចរ ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងជួបបញ្ហាគ្រោះថ្នាក់ចរាចរតាមដងផ្លូវ ដ៏តូចចង្អៀត ផ្លូវកោង ជង្ហុក និងមានចំណោត និងទូលជាច្រើនកន្លែង នៅពេលមានរថយន្ត ឬគ្រឿងយន្តរបស់ក្រុមហ៊ុន ធ្វើដំណើរ

ចុះឡើង និងធ្វើឱ្យរំខានដល់អ្នកទេសចរណ៍ ដោយសារធូលីដី ការរាំងខ្ទប់ដោយការទប់ទំនប់បណ្តោះអាសន្នតាមផ្លូវទឹក នៃដងស្ទឹងជាយអារែងជាដើម ។

➢ **វិធានការគាត់បន្តុយ**

ក្រុមហ៊ុននឹងដាក់ផ្លាកចរាចរ ផ្លាកប្រុងប្រយ័ត្នគ្រោះថ្នាក់ នៅការដ្ឋានសាងសង់ ដើម្បីឱ្យអ្នកបើកបរ ភ្ញៀវទេសចរណ៍ងាយឃើញ និងមានការប្រុងប្រយ័ត្ន ជាពិសេសនៅផ្លូវតូចចង្អៀត ផ្លូវកោង ។

បញ្ហាធ្វើឱ្យរំខានដល់ភ្ញៀវទេសចរណ៍ដោយសារធូលីដីក្រុមហ៊ុននឹងធ្វើការបាញ់ទឹកតាមផ្លូវដែលភ្ញៀវទេសចរណ៍ធ្វើចរាចរ ហើយថែទាំ និងជួសជុលជាប្រចាំនូវផ្លូវសាធារណៈ ដែលខ្លួនបានប្រើប្រាស់ ។

ក្រុមហ៊ុននឹងមិនទប់ទំនប់បណ្តោះអាសន្នទប់ស្ទឹង ជាយអារែងទាំងស្រុងនោះទេ គឺក្រុមហ៊ុនប្រលោះសំរាប់ឱ្យមានការឆ្លងទូកចេញចូលបាន ជាពិសេសទូកភ្ញៀវទេសចរណ៍ដែលមកកំសាន្តតាមដងស្ទឹងជាយអារែងនេះ (ច្រកនេះក៏អាចធ្វើឱ្យត្រីផ្លាស់ទីទៅមកតាមស្ទឹងជាយអារែងបានទៀតផង) ។

- **ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

សកម្មភាពសាងសង់គំរោង និងការដឹកជញ្ជូនសំភារៈបរិក្ខាគ្រឿងចក្រចេញចូលទីតាំងគំរោង អាចប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ក្នុងតំបន់ ដូចជា ការស្រុតឬ ខូចផ្លូវ ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើច្រូងផ្លូវ ដែលមានចំណោត ទួល និងផ្លូវកោង។

➢ **វិធានការគាត់បន្តុយ**

ក្រុមហ៊ុននឹងធ្វើការកែលំអរផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មី ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង ហើយកន្លែងខ្លះត្រូវពង្រីកផ្លូវអាចឱ្យរថយន្តជៀសគ្នាបាន និងអាចមើលឃើញគ្នាពីចំងាយ ដើម្បីជៀសវាងគ្រោះថ្នាក់ ។

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជារគ្រឿងចក្រនិងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន (មិនលើសចំងន់នាំឱ្យខូចផ្លូវលំរបស់សហគមន៍ ហើយល្បឿនបើកបរមិនឱ្យលើសពី ៣០ គ.ម ក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០គ.មក្នុង១ម៉ោង) និងដើម្បីបញ្ឈៀសគ្រោះថ្នាក់ចរាចរនានា ។

ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ សំរួលចរាចរក្នុងតំបន់ដែលមានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន ដូចជាពង្រីកផ្លូវចាស់ ឬធ្វើផ្លូវវាងព្រមទាំងមានផ្លាកសញ្ញាសំគាល់ ។

ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវលំដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ។

- **សុខភាពសាធារណៈ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់គំរោង អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋក្នុងតំបន់ ដោយសារធូលីដី ធូលីស៊ីម៉ងត៍ ការបំផ្ទុះ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីជាដើម ។ល។

ដោយសារតំបន់ជាយអារែងសំបូរទៅដោយព្រៃភ្នំ ជ្រោះជ្រលងអូរ និងសារធាតុរ៉ែ ដែលអាចនឹងបង្កឱ្យមានជំងឺគ្រុនចាញ់ និង គ្រុនសន្ទុំ ដល់បុគ្គលិក-កម្មកររបស់គំរោង ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋនៅតំបន់គំរោងក៏អាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ពីបុគ្គលិក-កម្មករគំរោង ដែលក្រុមហ៊ុនជ្រើសរើសយកមកពីតំបន់ឆ្ងាយផងដែរ ។

អាចនឹងមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារសមាសភាពនៃជនខិលខូច ឬអ្នកចំណូលថ្មី រកស៊ី ចរាចរនិងប្រើប្រាស់គ្រឿងញៀននៅក្នុងតំបន់គំរោង (ប្រជាជនក្នុងតំបន់ និងបុគ្គលិក-កម្មករគំរោង) ។

ការងារសាងសង់ទំនប់វារីអគ្គីសនី ជាការងាររួមមួយមានទំហំធំ ហើយនិងងាយរងគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង និង បុគ្គលិក-កម្មករគំរោង ដោយសារ មិនចាប់អារម្មណ៍ និងយកចិត្តទុកដាក់អំពីសុវត្ថិភាពការងារ ។

ក្នុងតំបន់គំរោងជាតំបន់ដាច់ស្រយាលពុំសូវមានមនុស្សរស់នៅ ហើយទំលាប់របស់អ្នកស្រុកនិយមប្រើប្រាស់ទឹកស្ទឹង អូរ គឺគ្មានប្រភពទឹកស្អាតសំរាប់បរិភោគទេ ។ ម្យ៉ាងទៀតទីនេះគ្មានទីផ្សារលក់ផលិតផលទឹកស្អាត (ទឹកសុទ្ធ) នោះទេ ដែលជាហេតុធ្វើឱ្យបុគ្គលិក-កម្មករ ងាយទទួលនូវជំងឺរាគរូស និងជំងឺផ្សេងៗ។

<u>សំគាល់</u> : អាចមានការធ្វើបាតុកម្មពីសំណាក់កម្មករបុគ្គលិកគំរោង ដោយសារការធ្វេសប្រហែសរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ។

➢ **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ ដូចជាធ្វើផ្ទាកសញ្ញាសំគាល់ជាភាសាខ្មែរ និងភាសាអង់គ្លេស ដាក់នៅការដ្ឋានសាងសង់ថា "សុវត្ថិភាពការងារជាចំបង និង Safety first" ។

ចំពោះការការពារធូលីដី ក្រុមហ៊ុននឹងផ្តល់ម៉ាស់ការពារធូលីដីដល់បុគ្គលិក-កម្មករគំរោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គំរោងនេះ។

ក្រុមហ៊ុននឹងសាងសង់ជំរុំស្នាក់នៅរបស់បុគលិក-កម្មកររបស់គំរោងឱ្យបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាត មានបង្គន់អនាម័យគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មករ របស់គំរោង ។

ក្រុមហ៊ុននឹងមានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និង ត្រៀមថ្នាំពេទ្យ និងបរិក្ខាគ្រប់គ្រាន់ជាប្រចាំសំរាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គំរោង ហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ ។

បញ្ហាជំងឺកាមរោគក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មកររបស់ខ្លួន ក្នុងការទប់ស្កាត់ជំងឺទាំងនោះ កុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ពាក់ព័ន្ធទៅនឹងការជួញដូរ ចរាចរ ប្រើប្រាស់គ្រឿងញៀន និងមនុស្ស ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការជួញដូរ ចរាចរគ្រឿងញៀន និងមនុស្សឱ្យបានល្អប្រសើរ ។

ក្រុមហ៊ុននឹងបង្កើនការសហការថែមទៀត ជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ។

ក្រុមហ៊ុននឹងគោរពនូវច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តន៍គំរោងនេះ ដើម្បីឱ្យមានភាពរលូនដោយសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធ ។

Draft

- **សោភ័ណ្ឌភាព**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការសាងសង់បង្គោល និងខ្សែនាំភ្លើង ដែលមានកំលាំងភ្លើងខ្ពស់ ហៅថា High Viltage Transmission Line ពីស្ថានីយ៍ផលិតភ្លើងទៅស្ថានីយ៍រងអូរសោម អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងបីដែលតំបន់នេះនឹងក្លាយទៅជាតំបន់ទេសចរណ៍ទេសភាពធម្មជាតិនោះដែរ ដោយសារការរៀបចំបង្គោលខ្សែបណ្តាញភ្លើងមិនរត់តាមជួរល្អ និងកាប់ឆ្ការព្រៃឈើក្នុងតំបន់ទាំងនេះ ។

ការហុយធូលី ដោយសារការឈូសឆាយ ការបំផ្ទុះថ្ម ការដុតព្រៃ សំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ ។

➢ **វិធានការគាត់បន្ថយ**

វិធានការសាងសង់បង្គោល និងខ្សែនាំភ្លើងនេះ ក្រុមហ៊ុននឹងជ្រើសយកទិសតំរង់ឱ្យបានសមស្រប ហើយធ្វើគន្លងខ្សែនាំអគ្គិសនីឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា ដើម្បីបន្ថយការរំខានដល់ការមើលឃើញទេសភាព តាមដងផ្លូវពីសំណាក់អ្នកធ្វើដំណើរឆ្លងកាត់តំបន់នេះ ។

ចំពោះការប៉ះពាល់សោភ័ណ្ឌដោយសារធូលីដី ក្រុមហ៊ុននឹងធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ ដែលខ្លួនកំពុងប្រើប្រាស់សាងសង់គំរោង ។ ម្យ៉ាងទៀត ក្រុមហ៊ុននឹងប្រើប្រាស់សារធាតុផ្ទុះ ដែលមានភាពរំញ័រ និងរញួយតិច ហើយក្រុមហ៊ុនមិនដុតឈើដែលមានប្រយោជន៍នោះទេ គឺក្រុមហ៊ុនប្រើប្រាស់ឈើនោះឱ្យអស់លទ្ធភាព (មែកឈើតូចៗធ្វើធ្យូង និងឈើធំៗសហការជាមួយរដ្ឋបាលព្រៃឈើប្រមូលទុក ដេញថ្លៃបង់ចំណូលជូនរដ្ឋ) ។

- **ហានិភ័យ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងមានជួបហានិភ័យ ដោយសារគ្រោះធម្មជាតិ ដូចជា ការរញួយដី បន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីខ្យល់ព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ ដូចជា ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធ សំខាន់ៗរបស់គំរោង ដែលកំពុងសាងសង់ ការបាត់បង់ឬខូចខាតសំភារៈ និងគ្រឿងចក្រសាងសង់ ជាពិសេស ការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិត ដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។

ការធ្វេសប្រហែសអាចនឹងកើតមានការផ្ទុះសំភារៈគ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង និង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

សភាពការណ៍នយោបាយប្រែប្រួល អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គ ដល់ការងារសាងសង់គំរោង ឬសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងក៏សឹងមាន ។

➢ ទិធានការកាត់បន្ថយ

ក្រុមហ៊ុនបានធ្វើការសិក្សារចនាបួង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់ទំនប់ និង ការបាក់ភ្នំ ក្នុងតំបន់គំរោងវារីអគ្គិសនីជាយអារែងនេះឡើយ ។

ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេវរកម្មក្នុងតំបន់គំរោងឱ្យទាន់ពេលវេលា ។

ក្រុមហ៊ុននឹងធ្វើការជូនដំណឹងរាល់ហេតុការណ៍ ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដី ក្នុងតំបន់គំរោងដល់ប្រជាពលរដ្ឋដែលរស់នៅតាមដងស្ទឹងជាយអារែង និងព្រែកត្រពាំងរូងទាំងអស់ ឱ្យបានជ្រាបហេតុការណ៍ខាងលើទាន់ពេលវេលា តាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យកើតឡើង ។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមានបញ្ហាគ្រោះថ្នាក់ដោយចៃដន្យ ដូចជាការរញ្ជួយដី សង្ត្រាម និង បាតុភូតរុញច្រានមកលើទំនប់ខ្លាំង ។

ក្រុមហ៊ុននឹងរៀបចំបំរុងទុកនូវយានយន្តសង្ត្រោះ សំភារៈ និងថវិកា ដើម្បីធានាការសង្ត្រោះជាបន្ទាន់នូវហេតុការខាងលើនេះ ទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់ ។

៥.៣.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះគឺ ជាដំណាក់កាលមួយមានរយៈពេលវែងជាងគេរហូតដល់៤០ឆ្នាំ យោងតាមកិច្ចសន្យាស្នើសុំរបស់ក្រុមហ៊ុនដាក់ជូនទៅរាជរដ្ឋាភិបាល ។ សកម្មភាពគំរោងក្នុងដំណាក់កាលនេះ អាចនឹងបង្កឱ្យមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដូចតទៅ :

៥.៣.៣.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះធនធានរូបសាស្ត្រ និង វិធានការកាត់បន្ថយ .

- ប្រព័ន្ធជលសាស្ត្រ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលនេះអាចនឹងមានផលប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ នៃស្ទឹងជាយអារែង និងខ្សែទឹកខាងក្រោម ដោយសារការបង្ខាំងទឹកដើម្បីស្តុកទឹកទុកសំរាប់បង្កើនកំលាំងឱ្យបានគ្រប់គ្រាន់សំរាប់អូសទូបឺនភ្លើងកំលាំង ១០៨ មេហាវ៉ាត់ និង ការបញ្ចេញទឹកពីទំនប់ Site A របស់គំរោងមិនគ្រប់គ្រាន់ ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងជាយអារែង ដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពល ។

ជាងនេះទៅទៀត ការតំកល់ទឹកក្នុងអាង ដែលមានជំរៅជ្រៅ ហើយផ្ទៃទឹកធំ នឹងធ្វើឱ្យមានការជ្រាបទឹកចូល ទៅក្នុងដីច្រើន ដែលធ្វើឱ្យកំពស់ទឹកក្រោមដីនៅប៉ែកខាងក្រោមអាងកើនឡើងខ្ពស់ជាងស្ថានភាពដើមរបស់វា អាចនាំឱ្យខូចខាតដល់ដំណាំ ឬរុក្ខជាតិផ្សេងៗ ព្រមទាំងអាចនឹងធ្វើឱ្យមានការប្រែប្រួលរបបជលសាស្ត្ររបស់ព្រែកត្រពាំងរូង ដោយសារ ការបង្ហូរទឹកពីអាងស្តុកទឹកមកខាងក្រោមមិនគ្រប់គ្រាន់ ជាពិសេសនឹងធ្វើឱ្យកំរិតប្រៃ នៃទឹកព្រែកត្រពាំងរូងឡើងខ្ពស់ជាងមុន ដែលអាចធ្វើមានការប៉ះពាល់ដល់អេកូឡូស៊ីរបស់ព្រែកនោះ ។

➢ **ទិដ្ឋានការគាត់បន្តុយ**

ការកាត់បន្ថយផលប៉ះពាល់នៃរបបជលសាស្ត្រនេះ ក្រុមហ៊ុននឹងត្រូវបញ្ចេញទឹកពីអាងស្តុកទឹកមកប៉ែកខាងក្រោមទំនប់ Site A ឱ្យបានតិចបំផុត ១.៥$ម^{3}$/វិនាទី គឺធ្វើយ៉ាងណាដើម្បីរក្សារបបជលសាស្ត្រ និង ប្រព័ន្ធអេកូឡូស៊ីរបស់ស្ទឹងជាយអារែង ដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពល ឱ្យមានការប្រែប្រួលរបបជលសាស្ត្រកិរិតអប្បបរមា។

ចំពោះបញ្ហាជំរាបទឹក ក្រុមហ៊ុននឹងសាងសង់គ្រឹះទំនប់ឱ្យបានល្អ មានកិរិតជំរាបទឹកតិច ហើយនឹងមានការសិក្សាស្រាវជ្រាវ អំពីលក្ខណៈទឹកក្រោមដីជាប្រចាំ។

ជាងនេះទៅទៀត ក្រុមហ៊ុននឹងធ្វើការប្រតិបត្តិការគំរោងយ៉ាងណា ដើម្បីបញ្ចេញទឹកពីអាងស្តុកទឹកឱ្យបានសមស្រប ទាំងរដូវវស្សា និង រដូវប្រាំង ដើម្បីរក្សាប្រព័ន្ធ អេកូឡូស៊ី និងរបបជលសាស្ត្រនៅប៉ែកខាងក្រោមអគារថាមពល ឱ្យមានលំនឹង ជាពិសេស គឺធ្វើយ៉ាងណាឱ្យរក្សាធាទឹកនារដូវប្រាំងនៅស្ទឹងជាយអារែងផ្នែកខាងក្រោមអគារថាមពលប្រហាក់ប្រហែល ឬមានច្រើនជាងបន្តិចបន្តួច ធ្យៀបទៅនឹងពេលមិនទាន់មានការសាងសង់ទំនប់។

- **គុណភាពទឹកលើដី និងក្រោមដី**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង អាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការតំកល់ទឹកក្នុងអាង ដើម្បីអូសទូបីនពា កំលាំងសរុប ១០៨ មេហ្គាវ៉ាត់ ធ្វើឱ្យលិចផ្ទៃដី ៩.៤៧៤ហ.ត ដែលមានព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមស្មុយរលួយ ហើយក្នុងរុក្ខជាតិទាំងនេះមានសារធាតុសរីរាង្គ និងគីមីផ្សេងៗ។

ការលើកទំនប់កំពស់ ៣៦.៦ម. អាចតំកល់ទឹកក្នុងអាងក្នុងកិរិតកំពស់មធ្យមពី ១៥ម-២៥ម នឹងធ្វើឱ្យទឹកមានក្លិនស្អុយ ដោយសារ ការរលាយអុកស៊ីសែនក្នុងទឹកមានកិរិតទាប ។ ម្យ៉ាងទៀត នៅខ្សែទឹកខាងក្រោម នឹងអាចទទួលរងផលប៉ះពាល់នូវប្រភពទឹកស្អុយពីអាងស្តុកទឹក នៅពេលដែលមានការបង្ហូរទឹកមកផ្នែកខាងក្រោម ។

ការរលាយសារធាតុខនិកក្នុងដី ដែលបង្កឱ្យមានការកើនឡើង នៃសារធាតុគីមីទឹកក្រោមដី ដោយសារ ការតំកល់ទឹកក្នុងអាង ហើយនិងការជ្រាបទឹកពីអាងស្តុកទឹកទៅក្រោមដី ដែលមានក្លិនស្អុយ ដោយសារទឹកមានកិរិតអុកស៊ីសែនរលាយទាប នឹងធ្វើឱ្យគុណភាពទឹកក្រោមដីថយចុះ ។

ចំពោះការបំពុលទឹកដោយសារការលាងបាតអាង ដោយ បង្ហូរល្បាប់ភក់ និងខ្សាច់ចេញពីបាតអាងនៅរដូវវស្សា ដែលបង្កឱ្យមានក្លិនស្អុយ និងធ្វើឱ្យទឹកស្ទឹងល្អក់ នឹងធ្វើឱ្យមានការប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹកនៅផ្នែកខាងក្រោម ជាពិសេស ប្រជាពលរដ្ឋ សត្វពាហនៈ សត្វស្លាប និងពពួកសត្វព្រៃ ជុំវិញតំបន់គំរោងនេះ។ ជាងនេះទៅទៀត ការស្តុកទឹកធ្វើជាអាងដ៏ធំនេះ នឹងអាចកើតមានរុក្ខជាតិទឹក ដូចជា ពើក ចក កំប្លោក និងសត្វល្អិតចង្រៃដូចជា មូស ចាក់តោ ដែលបង្កឱ្យមានរំហួតខ្លាំង ការបំពុលគុណភាពទឹកអាង និងការចម្លងជំងឺផ្សេងៗ ដែលកើតចេញពីប្រភពទឹកនេះ ។

➢ **ទិដ្ឋានការគាត់បន្តុយ**

ក្រុមហ៊ុននឹងធ្វើការសំអាតផ្ទៃអាងជាមុនសិន មុននឹងតំកល់ទឹកក្នុងអាង ។ ការសំអាតនេះរួមមាន ការកាប់សំអាតព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមទាំងនោះចេញ ។

ក្រុមហ៊ុននឹងសាងសង់ប្រឡាយចំហរនាំទឹកពីទំនប់ Site A មកអគារថាមពល ដែលមានចំងាយ ៤០៣៧ម។ ការសាងសង់នេះ នឹងធ្វើឱ្យទឹកមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ ហើយធ្វើឱ្យទឹកលែងមានក្លិនស្អុយទៀតផង។

ក្រុមហ៊ុននឹងធ្វើការសិក្សា និងពិនិត្យតាមដានអំពីគុណភាពទឹកក្រោមដីជាប្រចាំ ជៀសវាងកើតមានការបំពុលទឹកដោយរៀបចំសកម្មភាពធ្វើការលាងសំអាតអាងនៅរដូវវស្សា នៅពេលដែលស្ទឹងជាយអារែងមានធារទឹកអតិបរមា ហើយនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជូនដំណឹងអំពីការលាងសំអាតនេះ ឱ្យបានមួយសប្តាហ៍មុនពេលលាងអាងនេះ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារៈ និងអ្នកឯកទេសសំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គំរោង។

ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយក្រសួងធនធានទឹក (ផ្នែកជលសាស្ត្រ) និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ ដោយសារគុណភាពទឹក បើសិនជាមានការបំពុលធ្ងន់ធ្ងរ។

- **ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់ប្រតិបត្តិ និងថែទាំនេះ ក៏អាចនឹងប៉ះពាល់ដល់ជំរកសត្វព្រៃ ដោយសារសកម្មភាពរបស់បុគ្គលិក-កម្មករ ទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃ ធ្វើឱ្យឈើ និង សត្វព្រៃ ទាំងនោះថយចុះឈានទៅរកការបាត់បង់ពូជមួយចំនួន។

ជាមួយគ្នានេះដែរ ការទន្ទ្រានកាន់កាប់ដីនៅក្នុង ឬក្បែរតំបន់គំរោង (ដែលជាតំបន់អភិរក្សព្រៃឈើ និងជំរកសត្វ នៃតំបន់អភិរក្សភ្នំក្រវាញ) ពីសំណាក់បុគ្គលិក-កម្មករ និងជនឆ្លៀតឱកាសនិយមមកពីខាងក្រៅ នឹងធ្វើឱ្យបាត់បង់សម្បត្តិធនធានធម្មជាតិនៅតំបន់នោះ ហើយអាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារ បុគ្គលិក-កម្មករ គំរោងផងដែរ។

ចំពោះការតំកល់ទឹកក្នុងអាង អាចនឹងធ្វើឱ្យខូចខាតជំរកក្រពើ ដូចជា នៅត្រពាំងបបុស្សធំ និងបបុស្សតូច ព្រមទាំងជំរកសត្វព្រៃ និងបក្សីផ្សេងៗទៀត ដែលធ្លាប់រស់នៅក្នុងតំបន់អាងស្តុកទឹកនេះ។

  - **វិធានការគាត់បន្ថយ**

ក្រុមហ៊ុននឹងមានវិធានការហាមឃាត់ដល់បុគ្គលិក-កម្មកររបស់គំរោងមិនឱ្យទន្ទ្រានកាន់កាប់ដី ឬរុករានព្រៃ និងបំផ្លាញជំរកសត្វព្រៃ នៅក្នុង និងក្បែរខាងតំបន់គំរោងនោះ ហើយនឹងធ្វើការអប់រំដល់បុគ្គលិក-កម្មករ របស់គំរោង មិនឱ្យទន្ទ្រាន ចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃុំ ដែលអាចបង្កការឆេះព្រៃឈើ ព្រមទាំងដាក់ពិន័យយ៉ាងតឹងរ៉ឹងដល់បុគ្គលិក-កម្មករណាដែលប្រព្រឹត្តិល្មើសនឹងការហាមឃាត់ខាងលើនេះ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ អង្គការ CI និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងជាយថាហេតុនៅក្នុងតំបន់គំរោង ហើយនិងត្រៀមបំពាក់នូវឧបករណ៍សំភារៈសំរាប់ពន្លត់អគ្គីភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលផ្តល់សញ្ញា ពេលមានអគ្គីភ័យកើតមានឡើង ។

ដើម្បីធ្វើឱ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ក្រុមហ៊ុននឹងត្រៀមមូលនិធិគ្រប់គ្រាន់ ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញ នៅតំបន់ដែលគ្មានឈើដុះក្បែរ និងធ្វើជំរកក្រពើនៅកន្លែងថ្មី) ។

- **ជីវសាស្ត្រសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការបាត់បង់ជំរកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹកទំហំ ៩៨៧៤ហ.ត នៃគំរោងសាងសង់វារីអគ្គិសនីនេះ នឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួន នៅក្នុងតំបន់អភិរក្សធនធានធម្មជាតិភ្នំក្រវ៉ាញ ហើយការតំកល់ទឹកក្នុងអាងដែលមានផ្ទៃទឹកដ៏ធំធេងនេះ មិនអាចឱ្យសត្វព្រៃមួយចំនួនធំឆ្លងកាត់បាន ជាពិសេសការធ្វើចរាចររបស់ដំរី នៅតំបន់គំរោង និងការប្រែប្រួលនៃការធ្វើចរាចរ និង ទីជំរករបស់ត្រីនាគ និងក្រពើភ្នំ ក្នុងការឆ្លងកាត់ទំនប់ស្តុកទឹកនេះ ។

ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វ ពីសំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និង ថែទាំគំរោង ក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពុងធ្វើការអភិរក្ស ដោយអង្គការ CI ។

ក្រោយពីមានការសាងសង់ អាចនឹងមានការអភិវឌ្ឍន៍ផ្សេងៗនៅជុំវិញតំបន់គំរោង នឹងធ្វើឱ្យមានការហូរចូល នៃជនចំណូលថ្មីមកពីតំបន់ផ្សេងៗ ដើម្បីទន្ទ្រានកាន់កាប់ដី និងរស់នៅតំបន់នេះ ដែលជាហេតុធ្វើឱ្យមានការបាត់បង់ធនធានធម្មជាតិ និងមានការប៉ះពាល់ដល់កត្តាជីវសាស្ត្រសត្វព្រៃយ៉ាងធ្ងន់ធ្ងរ ដូចជា ការប្រែប្រួលនៃការបន្តពូជ ការស្វែងរកចំណី និង ការបំលាស់ទីរបស់វាជាដើម ។

➢ **វិធានការកាត់បន្ថយ**

វិធានការដ៏លំបាកនេះ ក្រុមហ៊ុននឹងត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរ និងធ្វើជំរកក្រពើនៅកន្លែងថ្មី) ។ ជាងនេះទៅទៀតក្រុមហ៊ុននឹងហាមឃាត់ដាច់ខាតដល់បុគ្គលិក- កម្មករ របស់ខ្លួនក្នុងការប្រមាញ់សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ហើយនិងធ្វើការអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករគំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

ដើម្បីចូលរួមឱ្យការគ្រប់គ្រងធនធានធម្មជាតិកាន់ល្អប្រសើរ ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ច និង CI ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងអ្នកចំណូលថ្មី ទប់ស្កាត់ការកាន់កាប់រុករានទន្ទ្រានដីថ្មី ពីជនចំណូលថ្មីទាំងនោះ ។

- **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ឆ្លងតាមការចុះសំភាសន៍ និងការធ្វើបង្ហាញនូវរូបភាពត្រីជាច្រើនប្រភេទដល់ប្រជាពលរដ្ឋដែលមានបទពិសោធន៍ ខាងនេសាទ ដើម្បីឱ្យគាត់គូសបញ្ជាក់ បានឱ្យដឹងថា នៅស្ទឹងជាយអារែងតំបន់គំរោងមានត្រីប្រមាណ ៤៣ប្រភេទ រស់នៅ ក្នុងនោះត្រីនាគ និងក្រពើភ្នំ ជាប្រភេទសត្វកំរ ដែលមានការយកចិត្តទុកដាក់ និងអភិរក្ស ដោយគំរោងអភិរក្សធនធានធម្មជាតិ ភ្នំក្រវ៉ាញ កណ្តាលរបស់អង្គការ CI ។ ដូចនេះការបិទទ្វារទឹកដើម្បីតំកល់ទឹកក្នុងអាងរបស់គំរោងសាងសង់វារីអគ្គិសនីជាយអារែង អាចនឹងប៉ះពាល់ដល់ជីវសាស្ត្ររបស់ត្រីនាគ និងក្រពើភ្នំ និងវារីសត្វមួយចំនួនទៀត ។ កត្តាជីវសាស្ត្រ ដែលនឹងត្រូវប៉ះពាល់សំខាន់របស់ត្រីនាគ និងវារីសត្វមួយចំនួនទៀត គឺការធ្វើចរាចរចុះឡើងឆ្លងកាត់ទំនប់វារីអគ្គិសនី និងជំរកពងកូនរបស់ក្រពើភ្នំ ។

ចំពោះការបង្ហូរទឹកចេញពីអាង (តាមទូប៊ីន) ដែលមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកតិច ធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្ររបស់វារីសត្វដែលរស់នៅក្នុងទឹក ឬមច្ចជាតិ ។ ម្យ៉ាងទៀត ការតំកល់ទឹកក្នុងអាងរបស់គំរោងវារីអគ្គិសនីអាចនឹងកើតមានរុក្ខជាតិទឹក ដូចជា ពើក ចក កំបោក និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ដែលបង្កឱ្យខ្វះអុកស៊ីសែនរលាយក្នុងទឹក ធ្វើឱ្យវារីសត្វថយចុះ ឬ បាត់បង់ ឬកើនឡើងនៃប្រភេទវារីសត្វថ្មីទៀត ដែលមិនធ្លាប់មានក្នុងតំបន់។

រីឯការបំពុលទឹកដោយសំណល់រាវ-រឹង ពីការិយាល័យ ផ្ទះបុគ្គលិក- កម្មករ ដែលស្នាក់នៅ ពីឃ្លាំងស្តុកសំភារៈ និងពីរោងជាង នឹងធ្វើឱ្យមានការប៉ះពាល់ដល់វារីសត្វផងដែរ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងផ្តល់មូលិធិគ្រប់គ្រាន់សំរាប់ការការពារក្រពើភ្នំ (*Crocodylus Siamesse*) និងការធ្វើជំរក/សំបុកនៅកន្លែងថ្មីឡើងវិញដោយមានការសហការជាមួយអង្គការ FFI និង CIដើម្បីធ្វើការងារនេះ។

ដើម្បីដោះស្រាយបញ្ហានៃការបង្ហូរទឹកចេញពីអាង (តាមទូប៊ីន) ដែលមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកតិច ធ្វើឱ្យមានការប៉ះពាល់ដល់កត្តាជីវសាស្ត្រនោះក្រុមហ៊ុននឹងសាងសង់ប្រឡាយចំហរនាំទឹកមកអគារថាមពលដែលមានចំងាយ៤០៣៧ម ដែលធ្វើឱ្យទឹកមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ ហើយធ្វើឱ្យទឹកមានអុកស៊ីសែនឡើងវិញ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ សំភារៈ និងអ្នកឯកទេស សំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គំរោង។

ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវ (អាងសិបទិកទំនើប) សំរាប់សំអាតទឹកក្រខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោង ។

៥.៣.៣.២ ហេតុប៉ះពាល់អវិជ្ជមានចំពោះបរិស្ថានសង្គម និង វិធានការកាត់បន្ថយ

- **ប្រពៃណី វប្បធម៌ និង សាសនា**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះ គំរោងអាចនឹងមានផលប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ផងដែរ ដោយសារក្រុមហ៊ុននាំយកបុគ្គលិក-កម្មករគំរោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស ដែលមានជំនឿ និងទំនៀមទំលាប់ផ្សេងៗគ្នា ធ្វើឱ្យមានការប៉ះពាល់ដល់ពួកគាត់ ដែលមានជំនឿលើអារក្សអ្នកតាព្រៃភ្នំ ដូចជា ពួកគាត់នាំគ្នាបង្កើតជាព្រៃអ្នកតា ដើម្បីធ្វើជាទីកន្លែងសក្ការៈបូជា ។ មិនតែប៉ុណ្ណោះពួកគាត់មានការគោរពសត្វព្រៃមួយចំនួន ដូចជា ការគោរពក្រពើភ្នំជាដើម ។

➢ **ទិដ្ឋភាពគោលបន្ថយ**

ក្រុមហ៊ុននឹងធ្វើការណែនាអប់រំដល់បុគ្គលិក-កម្មកររបស់គំរោង ឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿ របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃភ្នំ ស្ថិតនៅជុំវិញទីតាំងគំរោងវារីអគ្គីសនីជាយអារែងនេះ ។

ក្រុមហ៊ុននឹងដាក់វិន័យដល់បុគ្គលិក-កម្មករណា ដែលបំពានលើទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

ក្រុមហ៊ុននឹងសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយទំនាស់ដែលកើតឡើងជាយថាហេតុឱ្យបានសមស្រប និងយុត្តិធម៌ ។

- **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់នេះ អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ នៅតំបន់ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុក មានគុណភាពមិនល្អ និងមានក្លិនស្អុយ មកពីការរលួយពីរុក្ខជាតិ ដែលិចទឹក និងការខ្វះអុកស៊ីសែនរបស់ទឹក ។

ការគ្រប់គ្រងកាកសំណល់រឹង-រាវ បង្គន់ ដែលចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ឃ្លាំងស្តុកសំភារៈរោងជាងជាដើម អាចធ្វើឱ្យខូចដល់ប្រភពទឹកសំរាប់ផ្គត់ផ្គង់ក្នុងតំបន់គំរោង ។

គំរោងវារីអគ្គីសនីជាយអារែង ស្ថិតនៅខេត្តកោះកុង ដែលជាតំបន់ទេសចរណ៍តំបន់ឆ្នេរ នៃប្រទេសកម្ពុជា អាចនឹងទទួលឥទ្ធិពលនៃការកើនឡើងនៃភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិ ដែលចង់ទៅទស្សនាកំសាន្តនៅតំបន់ទំនប់វារីអគ្គីសនីជាយអារែងនេះ ក្រោយពីមានការសាងសង់រួច ពីព្រោះមានផ្លូវចេញ-ចូលស្រួល។ ការកើនឡើងនៃភ្ញៀវទេសចរណ៍នៅជាយអារែងនេះអាចធ្វើឱ្យកើតមានការបំពុលទឹកស្ទឹងជាយអារែង ដោយសារកាកសំណល់រឹង-រាវរបស់ភ្ញៀវទេសចរណ៍ទាំងនោះ ។

គំរោងនេះ នឹងអាចប៉ះពាល់ដល់ការប្រើប្រាស់ទឹកនៅរដូវប្រាំង របស់អ្នកភូមិព្រៃស្វាយ ដែលសៅនៅប៉ែកខាងក្រោមទំនប់ ក្នុងករណីក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកនៅក្នុងប្រឡាយ ដោយមូលហេតុការពារសុវត្ថិភាពមនុស្ស និងសត្វ ។

➢ **ទិដ្ឋភាពគោលបន្ថយ**

បញ្ហាប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ ដែលរស់នៅប៉ែកខាងក្រោមទំនប់ Site A ក្រុមហ៊ុននឹងមានវិធានការសំអាតព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមជាមុនសិន មុននឹងទប់ទំនប់ ឬទ្វារទឹក ដើម្បីបំពេញទឹកក្នុងអាង។

ការគ្រប់គ្រងកាកសំណល់រាវ ក្រុមហ៊ុននឹងសាងសង់ប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ដល់បុគ្គលិក-កម្មករគំរោង និងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវ (អាងសិបទឹកទំនើប)ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ ក្នុងការធ្វើប្រតិបត្តិនិងថែទាំគំរោង។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យត្រឹមត្រូវតាមបច្ចេកទេស ដោយមានអាងសិបទឹក ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។

ក្រុមហ៊ុននឹងរកប្រភពទឹកថ្មីផ្តល់ជូនប្រជាពលរដ្ឋ ដូចជា ការតបណ្តាញផ្គត់ផ្គង់ ទឹកពីអាង ឬជីកអណ្តូង និងស្រះ ។

- **ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលប្រតិបត្តិ និងថែទាំនេះ អាចនឹងបង្កឱ្យប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍ របស់ប្រជាពលរដ្ឋក្នុងតំបន់ ដូចជាការបិទផ្លូវមិនឱ្យប្រជាពលរដ្ឋ ចេញចូលក្នុងតំបន់ដែលធ្លាប់បានប្រើប្រាស់។

ចំពោះស្ថានភាពផ្លូវតូចចង្អៀត ហើយជួបបញ្ហាកកស្ទះលើដងផ្លូវ និងបញ្ហាមានចំណោតជាច្រើនកន្លែង នឹងបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកទេសចរណ៍ ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គំរោងដែលនឹងមានការកើនឡើង ។

➢ **វិធានការកាត់បន្ថយ**

ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋក្នុងការបិទផ្លូវដែលធ្លាប់ចេញ-ចូលនោះ ក្រុមហ៊ុននឹងដោះស្រាយដោយមិនបិទផ្លូវដែលប្រជាពលរដ្ឋធ្លាប់ចេញ-ចូលនោះទេ ។ ប្រសិនបើក្រុមហ៊ុនចង់បិទផ្លូវណាមួយ ដើម្បីសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ក្រុមហ៊ុននឹងធ្វើផ្លូវវាងជំនួសវិញ។

ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ ចំពោះបញ្ហាផ្លូវ ដូចជា ការដាក់ផ្ងាកសញ្ញាចរាចរ ធ្វើរបាំងការពារត្រង់ផ្លូវកោង និងមានចំណោទជាដើម ។

ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោង និងធ្វើការថែរក្សាផ្លូវលំដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ដើម្បីធានាសុវត្ថិភាព និងសំរួលចរាចរឱ្យបានល្អប្រសើរ។

- **សុខភាពសាធារណៈ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការតំកល់ទឹកក្នុងអាង អាចនឹងកើតមានរុក្ខជាតិទឹកដូចជា ពើក ចក កំបោក សារាយ និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ឬសត្វល្អិត ដែលអាចបង្កជំងឺ និងចម្លងជំងឺទៅសត្វ និងមនុស្សបាន ជាពិសេសជំងឺកើតឡើងពីប្រភពទឹក (Waterborn diseases)។

- តំបន់ជួរភ្នំក្រវាញសំបូរដោយព្រៃឈើ ជ្រលងដងអូរ អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គំរោង ដោយសារតំបន់នេះជាតំបន់ដែលកើតជំងឺគ្រុនចាញ់ និងគ្រុនសន្ទុំ ។ ផ្ទុយទៅវិញប្រជាពលរដ្ឋនៅតំបន់គំរោងក៏អាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ពីបុគ្គលិក-កម្មករគំរោង ដែលក្រុមហ៊ុនជ្រើសរើសយកមកពីតំបន់ឆ្ងាយផងដែរ។

ការបង្ហូរកាកសំណល់រាវ និងការបោះចោលនូវកាកសំណល់រឹងអាចមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារការគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អ។

អាចមានចរាចរជួញដូរគ្រឿងញៀនពីសំណាក់បុគ្គលិកកម្មករគំរោង ធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈនៅតំបន់នោះ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុននឹងធ្វើការពិនិត្យតាមដានគុណភាពទឹកក្នុងអាង និងក្រៅអាងឱ្យទ្បើងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកក្នុងឬក្រៅអាងមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយ ដើម្បីធ្វើការកាត់បន្ថយ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍-សំភារៈ និងអ្នកឯកទេស សំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុករបស់គំរោង។

ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នេះ ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ ។

ជាងនេះទៅទៀតក្រុមហ៊ុនសាងសង់ និងថែទាំអាងប្រព្រឹត្តិកម្មកាកសំណល់រាវសំរាប់សំអាតទឹកក្រខ្វក់ ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានកំរិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧ អនក្រ.បក របស់រាជរដ្ឋាភិបាល ។

ក្រុមហ៊ុននឹងសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ការជួញដូរគ្រឿងញៀននៅក្នុងតំបន់គំរោង ។

- **សោភ័ណ្ឌភាព**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

នៅដំណាក់កាលប្រតិបត្តិ និងថែទាំ អាចនឹងមានការកើនឡើងនូវភ្ញៀវទេសចរណ៍មកកំសាន្ត ចំនួនប្រជាពលរដ្ឋមករស់នៅតំបន់គំរោង ដែលជាហេតុធ្វើឱ្យមានការចោលសំរាមដោយគ្មានសណ្តាប់ធ្នាប់ពីសំណាក់ភ្ញៀវទេសចរណ៍មកកំសាន្ត ប្រជាពលរដ្ឋរួមទាំងបុគ្គលិក-កម្មកររបស់គំរោងផង នឹងធ្វើឱ្យបាត់សោភ័ណ្ឌភាពនៅតំបន់គំរោងនេះ ។

  - **វិធានការកាត់បន្ថយ**

បញ្ហាសោភ័ណ្ឌភាពនេះ ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ រៀបចំការសំអាតអនាម័យនៅតំបន់ជុំវិញគំរោងឱ្យបានល្អប្រសើរ ។

- **ហានិភ័យ**

  - **ហេតុប៉ះពាល់អវិជ្ជមាន**

ហានិភ័យដោយសារគ្រោះធម្មជាតិ ដូចជាការកើតមានការរញ្ជួយដី ឬបន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ អាចនឹងបង្កឱ្យមានមហន្តរាយធំៗ ដូចជាការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។

ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និងសំពាធទឹកក្នុងអាងស្តុកទឹកដែលមានចំណុះ ៥២១លានម៉ែត្រគូប = ៥២១លានតោន ។

ការឆេះព្រៃក្នុងតំបន់គំរោងដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំ ដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ធនធានធម្មជាតិក្នុងតំបន់ និង អាយុជីវិតមនុស្សទៀតផង ។

ការកើតមានសង្គ្រាមឈ្លានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគំរោង ជូនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង ។

Draft

➢ **វិធានការកាត់បន្ថយ**

បញ្ហាហានិភ័យដោយគ្រោះធម្មជាតិ ក្រុមហ៊ុននឹងធ្វើការសិក្សាតាមដានបន្ថែមទៀត នៅក្នុងតំណាក់កាលនេះលើហេតុការណ៍ប្រែប្រួលលើកត្តាធម្មជាតិ និងអត្តសញ្ញាណនានាដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីស្ទឹងជាយអារែងនេះ ។

បញ្ហាដែលកើតឡើងពីការធ្វេសប្រហែសផ្នែកសន្តិសុខ ឬភេរវកម្ម ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសន្តិសុខចំពោះគ្រឿងផ្ទុះនានា អគ្គីភ័យនានា និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោងដល់ប្រជាពលរដ្ឋ ដែលរស់ក្នុង និងក្បែរខាងគំរោងនេះទាំងអស់ ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលា តាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះកើតឡើង ។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាង នៅពេលមានបញ្ហាគ្រោះថ្នាក់ ដោយចៃដន្យដូចជា ការរញ្ជួយដី ឬសង្គ្រាម ហើយនិងរៀបចំបុំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សំភារៈ និងថវិកា ដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។

៥.៣.៤ ដំណាក់កាលបិទគំរោង (Project Closure)

ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុននៃប្រទេសចិននេះ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសំរេចខ្លួនឯង ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ ដែលគួរឱ្យកត់សំគាល់ឡើយ ។

ការប៉ាន់ប្រមាណ និងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ ត្រូវបានដកស្រង់ចេញពីតារាងលេខ ៣៩ ដូចខាងក្រោម :

Draft

កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

តារាងលេខ៣៩ : តារាងកំណត់ទំហំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
ចំណាក់កាលត្រៀមរចនា							
ធនធានរូបសាស្ត្រ							
សណ្ឋានដី និងឋានលេខា	ពុំមានការប៉ះពាល់ដល់ សណ្ឋានដី និងឋានលេខាទេ ដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និងពង្រាបដីដើម្បីសិក្សាឡើយ។		✓				
ការហូរច្រោះ និងគុណភាពដី	- ការហូរច្រោះដីពុំមានទេដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និងពង្រាបដីដើម្បីសិក្សាឡើយ ។ - អាចមានផលប៉ះពាល់ខ្លះៗដល់គុណភាពដីបណ្តាលមកពីការហ្បៀវ ឬកំពុបប្រេង និងការបោះកាកសំណល់ផ្សេងៗដោយបុគ្គលិក-កម្មករ របស់គំរោងក្នុងពេលសិក្សា។	- ក្រុមហ៊ុន នឹងរៀបចំការផ្គុំកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អ មិនលេចហូរប្រេងមកលើដីក្នុងតំបន់គំរោង និងរក្សាទុកកាកសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ - រីឯកាកសំណល់រឹងចេញពីកន្លែងស្នាក់នៅត្រូវមានធុងសំរាមកន្លែងទុកដាក់សំរាម និង បំផ្លាញចោលនៅទីតាំងដែលមានសុវត្ថិភាពល្អ ។ - ក្រុមហ៊ុននឹងចាត់វិធានការឱ្យបុគ្គលិកមានការទទួលខុសត្រូវរៀងខ្លួនលើសំណល់នៃទីតាំងរបស់ខ្លួន ។		✓			
ប្រព័ន្ធជលសាស្ត្រ ទីកលើដី (ប្រឡាយ- អូរ-ស្ទឹង)	ពុំមានការប៉ះពាល់ទៅដល់ប្រព័ន្ធជលសាស្ត្ររបស់ប្រឡាយ អូរ ស្ទឹងនៅក្នុងតំបន់គំរោងនោះទេ ពីព្រោះដំណាក់កាលនេះគ្មានសកម្មភាពសាងសង់ទេ គឺគ្រាន់តែមានការសិក្សាស្រាវជ្រាវ តាមផ្នែកខ្លះៗប៉ុណ្ណោះ។		✓				

ឆន្ទធាតុបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
ការបំពុលទឹក	អាចនឹងមានផលប៉ះពាល់ខ្លះដោយសារសំណល់នៃឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ហើយការស្នាក់នៅរបស់បុគ្គលិក-កម្មកររបស់គំរោងនេះដែរ ក៏ជាកន្លែងបង្កើតកាកសំណល់រឹង-រាវ ចេញពីផ្ទះបាយ និងបង្គន់ចូលទៅក្នុងស្ទឹងផងដែរ។	- ក្រុមហ៊ុននឹងអប់រំកម្មករ ក្នុងការទុកដាក់សំណល់ផ្សេងៗឱ្យបានសមស្រប ដូចជាការជីកកប់ការញែកសំណល់ដែលអាចប្រើឡើងវិញបានចេញ និងជ្រើសរើសទីតាំងឱ្យឆ្ងាយពីប្រភពទឹក ដើម្បីទុកដាក់សំណល់ ការពារកុំឱ្យមានការហូរចូលទៅក្នុងប្រភពទឹកនៅពេលមានភ្លៀង និងតាមរយៈខ្យល់បក់។ - ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅដាក់លូដើម្បីស្តុកលាមកមានជំរៅពី២,៥ ទៅ៣,៥ម៉ែត្រ ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញគឺមិនបង្ហូរឬចាក់ចូលទៅក្នុងស្ទឹងជាយ៉ាងណាទេ គឺជីករណ្តៅជំរៅ១-២ ម៉ែត្រ ទំហំ៤-៦ម^{2} ដើម្បីធ្វើឱ្យកាកសំណល់នោះក្លាយជាជីកំប៉ុស៍បានថែមទាំងមានធុងសំរាប់ទុកដាក់សំរាម និងកន្លែងកប់ ឬដុតសំរាមចោលដោយសុវត្ថិភាព។ - ក្រុមហ៊ុននឹងធ្វើការណែនាំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង។		✓			

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
សំឡេង រំញ័រ និងការរញ្ជួយ	អាចបង្កឱ្យមានការរំខានដល់សត្វព្រៃដោយសារក្រុមហ៊ុនមានការខួងដីសំរាប់សិក្សាអំពីគ្រឹះតាមចំណុច ដៅជាច្រើននៃទីតាំងទំនប់ SiteA និង SiteB និងអគារថាមពល (Powerhouse) សំរាប់ដាក់ទួបឺន ហើយសកម្មភាព នៃការខួងដីនេះត្រូវការកម្មករជាច្រើននាក់ បង្កឱ្យមានសំឡេងអ៊ូអរ រួមទាំងសន្ធីកសំឡេងម៉ាស៊ីន និងរំញ័រ ។	- ក្រុមហ៊ុននឹងប្រើម៉ាស៊ីនខួងដី ដែលមានកំរិតរញ្ជួយ និងសំឡេងតិច ដើម្បីកាត់បន្ថយសំឡេង និងរំញ័រ ដែលរំខានដល់សត្វព្រៃ ។ ហើយការងារនឹងមិនធ្វើការពេលយប់ទេដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃ ។ - ក្រុមហ៊ុននឹងអប់រំកម្មករ របស់គំរោងមិនឱ្យមានការស្រែក ឬជជែកគ្នាខ្លាំងៗ ដើរចេញឆ្ងាយទីតាំងការព្រោះវារំខានដល់សត្វព្រៃ ។ - ក្រុមហ៊ុនមិននចល័តក្រុមសិក្សាញឹកញាប់ទេ ពោលគឺក្រុមហ៊ុននឹងបោះទីតាំងទៅតាមតំបន់សំខាន់ៗ ដែលកំណត់ក្នុងការសិក្សា ធ្វើយ៉ាងនេះ ធ្វើឱ្យកាត់បន្ថយការប៉ះពាល់ដល់ការរំខានដល់សត្វព្រៃ ។		✓			
តំបន់អភិរក្សភ្នំក្រវាញ	អាចនឹងធ្វើឱ្យប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៃតំបន់អភិរក្សនេះ ដោយសារ សកម្មភាពសិក្សាគំរោងមានសំឡេងពីគ្រឿងចក្រ ភាពខ្សៀវខ្វារ នៃក្រុមបុគ្គលិក-កម្មករ ការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្ត ឬការជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម នឹងបង្កឱ្យមានផលប៉ះពាល់ដល់ស្ថានប្រព័ន្ធ និងអេកូឡូស៊ីផងដែរ ។ល ។	- ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្ទើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ហើយធ្វើការអប់រំដល់កម្មករគំរោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់គំរោងដើម្បីចាប់ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ព្រមទាំងដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេ			✓		

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
		ដែលប្រព្រឹត្តិខុសទៅនឹងបំរាមនេះ ។ - រីឯស្បៀង និងម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬហូបម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ក្រុមហ៊ុននឹងនាំស្បៀងពីកោះកុងដើម្បីផ្គត់ផ្គង់ដល់កម្មករនៅតំបន់គំរោង ។ - ជាងនេះទៅទៀតក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិក-កម្មករគំរោងឱ្យយល់ពីច្បាប់នៃការគ្រប់គ្រងថែរក្សាធនធាន និង សត្វព្រៃនៅក្នុងតំបន់ការពារ ។					
ធនធានអេកូឡូស៊ី							
ធនធានព្រៃឈើ និងជំរកសត្វព្រៃ	- អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដូចជា ការកាប់កូនឈើធ្វើស្តាន និងរានព្រៃធ្វើផ្លូវ ហើយនឹងអាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។ ចំពោះឧបករណ៍សំភារៈសិក្សាស្រាវជ្រាវសកម្មភាពខូងដី មានសំឡេង និងរំញ័រខ្លាំងអាចនឹងធ្វើឱ្យប៉ះពាល់ដល់ធនធានសត្វព្រៃ និងជំរកសត្វព្រៃ ជាពិសេសប៉ះពាល់ដល់របៀងសត្វដ៉ីរីដែលធ្លាប់ធ្វើដំណើរក្បែរខាងតំបន់គំរោង (តាមរបាយការណ៍របស់ប្រជាពលរដ្ឋ) ។ - អាចនឹងធ្វើឱ្យប៉ះពាល់ដល់ប្រភេទព្រៃឈើ និងសត្វព្រៃនៃតំបន់គំរោងផងដែរ ដោយសារសកម្មភាពនៃ ក្រុមបុគ្គលិក-កម្មករ ដូចជាការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករ	- ក្រុមហ៊ុននឹងសុំការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សក្នុងតំបន់គំរោងដើម្បីកាប់ឆ្ការព្រៃឈើធ្វើផ្លូវ និងប្រើប្រាស់ឈើសំរាប់សាងសង់ស្តានឆ្លងកាត់ ។ - ធ្វើការអប់រំដល់កម្មករគំរោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់គំរោងដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូបនិងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេដែលប្រព្រឹត្តខុសទៅនឹងបំរាមនេះ ។ រីឯស្បៀង និងម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬហូបម្ហូបអាហារណា ដែលពាក់ព័ន្ធសត្វព្រៃ		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	ក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការជួញដូរសត្វព្រៃសំរាប់ធ្វើម្ហូបនិងកាប់ឈើលក់ឱ្យឈ្មួញជាដើម ។ល។	នោះ។ ក្រុមហ៊ុន នឹងនាំស្បែរាងពីកោះកុងដើម្បីផ្តត់ផ្គង់ដល់កម្មករនៅតំបន់គំរោង ។ - ក្រុមការងាររបស់គំរោងនឹងបោះជំរុំការងារនៅនឹងកន្លែងជ្រៅសរាងការដឹកសំភារៈការងារចុះឡើង បង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។ ការងារនឹងធ្វើនៅពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។					
ជីវសាស្ត្រសត្វព្រៃ	- អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃ ដោយសារសកម្មភាពសិក្សាគំរោងក្រុមហ៊ុនមានការខួងដីសំរាប់សិក្សាគ្រឹះតាមចំណុចដៅជាច្រើន នៃទីតាំងទំនប់ SiteA និង SiteB និងទីតាំងអគារថាមពល (Powerhouse) ដែលត្រូវការកម្មករជាច្រើននាក់ក្នុងការងារ បង្កឱ្យមានសំឡេងអ៊ូអរ រួមទាំងសន្ធឹកសំឡេងម៉ាស៊ីន និងរំញ័របង្កឱ្យមានការរំខានដល់សត្វព្រៃនៅខណៈនោះដែរក្រុមហ៊ុនត្រូវការកាប់ឆ្ការព្រៃដើម្បីធ្វើផ្លូវចូលទៅទីតាំងសិក្សា ។ - ដោយសារសកម្មភាពសិក្សាគំរោង មានសំឡេងពីគ្រឿងចក្រ ភាពខ្សែវែខ្លារនៃក្រុមបុគ្គលិក-កម្មករ ការទម្លាននចូលក្នុងព្រៃពីក្រុមបុគលិក-កម្មករក៏នឹងមានផលប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃដែរ ។	- ក្រុមហ៊ុននឹងបោះជំរុំការងារនៅនឹងកន្លែង ជ្រៅសរាងការដឹកសំភារៈការងារចុះឡើងបង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។ - ក្រុមហ៊ុន នឹងធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃ ។ - ក្រុមហ៊ុននឹងសហការជាមួយជំនាញរដ្ឋបាលព្រៃឈើជួយណែនាំដល់បុគ្គលិក-កម្មករគំរោង ឱ្យមានការយល់ដឹងអំពីច្បាប់ និងបំរាមក្នុងការការពារ និងថែរក្សាសត្វព្រៃ ហើយដាក់វិន័យយ៉ាងតឹងរឹងដល់ពួកគេដែលប្រព្រឹត្តិខុសទៅនឹងបំរាម ។ រីឯម្ហូបអាហារវិញ ក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ - ក្រុមហ៊ុននឹងផ្តត់ផ្គង់ស្បៀងទៅតំបន់គំរោងពីកោះកុង ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
ជីវសាស្ត្រដែលរស់នៅក្នុងទឹក / មច្ចជាតិ	- អាចប៉ះពាល់បន្តិចបន្តួចដល់ជីវសាស្ត្រដែលរស់នៅក្នុងទឹក ឬ មច្ចជាតិ ដោយសារការបំពុលទឹកមកពីសំណល់រឹង-រាវនៃការស្នាក់នៅរបស់បុគ្គលិក- កម្មករ។ - គំរោងសាងសង់ទំនប់វារីអគ្គីសនីនេះពុំមានរចនាបួងំគំរោងសំរាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី និងជំរកក្រពើភ្នំ នៅពេលដែលគំរោងទាំងមូលនឹងសាងសង់ និងដំណើរការ។	- ក្រុមហ៊ុននឹងអប់រំកម្មកររក្នុងការទុកដាក់សំណល់ផ្សេងៗឱ្យបានសមស្រប ដូចជាការជីកកប់ ការញែកសំណល់ដែលអាចប្រើឡើងវិញបានចេញ និងជ្រើសរើសទីតាំងឱ្យឆ្ងាយពីប្រភពទឹកដើម្បីទុកដាក់សំណល់ ការពារកុំឱ្យមានការហូរចូលទៅក្នុងប្រភពទឹកនៅពេលមានភ្លៀង និងតាមរយៈខ្យល់បក់។ - ក្រុមហ៊ុននឹងរៀបចំធ្វើអាងចិញ្ចឹមត្រីនៅក្នុងអាងស្តុកទឹកនៃវារីអគ្គិសនី ហើយនឹងបង្កើនការគ្រប់គ្រង់ជលផល។ ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដល់វារីសាស្ត្រនោះ ពពួកពូជត្រីក្រៅស្រុកមិនត្រូវបានអនុញ្ញាតឱ្យយកចូលតំបន់នេះទេ។ - ក្រុមហ៊ុននឹងរក្សាគុណភាពទឹកនៅក្នុងតំបន់គំរោងដែលផ្តល់លក្ខខណ្ឌល្អ និងជំរកសំរាប់ការរស់នៅរបស់ត្រី។ រីឯបញ្ហាប៉ះពាល់ដល់ទីជំរកសត្វក្រពើភ្នំវិញ (*Crocodylus Siamesse*) ក្រុមហ៊ុន នឹងសហការជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទីជំរកថ្មីសំរាប់សត្វក្រពើភ្នំនិងកូនក្រពើអាចរស់នៅ និងបន្តពូជបាន មុននឹងបំពេញទឹកក្នុងអាង។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ថាន	តិច	មធ្យម	ខ្លាំង	
បរិស្ថានសង្គម / សេដ្ឋកិច្ច							
ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋានឡើងវិញ	- អាចប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋដោយសារខ្លាចបាត់បង់ដីស្រែចំការ និងលំនៅដ្ឋាន ដោយសារការសាងសង់វារីអគ្គិសនីនេះ។ - អាចមានអ្នកចំណូលថ្មីមកតាំងទីលំនៅតំបន់គំរោងបន្ថែមដើម្បីកេងចំណេញដោយសារការអភិវឌ្ឍន៍នេះ។ - ប្រជាពលរដ្ឋអាចមានគំនិតកាប់ឆ្ការដីព្រៃមកកាន់កាប់បន្ថែមដើម្បីទាមទារសំណង ដែលជាមូលហេតុបង្កឱ្យមានការបំផ្លាញព្រៃឈើដោយខុសច្បាប់ និងអាចមានជំលោះផ្សេងៗមកពីការកាន់កាប់ដី។	- ក្រុមហ៊ុននឹងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ ដូចជា អាជ្ញាធរមូលដ្ឋាន មន្ទីរ និងក្រសួងពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពន្យល់ដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងសិក្សារៀបចំធ្វើផែនការផ្តែកការតាំងលំនៅថ្មីជូនប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោង ។ - ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ និងជូនដំណឹងដល់សារធារណៈជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុនអំពីគោលបំណងជាក់ស្តែងរបស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍តំរោងនេះនៅពេលអនាគត ។ - ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ការកាន់កាប់ដីព្រៃបន្ថែមការកាន់កាប់ដីសាធារណៈរបស់រដ្ឋធ្វើជាកម្មសិទ្ធិផ្តាល់ខ្លួន។		✓			
ទំនាស់ នៃសិទ្ធិប្រើប្រាស់ដី នៃតំបន់គំរោង	- នៅពេលទទួលពត៌មានស្តីពីការសាងសង់ទំនប់វារីអគ្គិសនីនេះ ប្រជាជនចាប់ផ្តើមគិតអំពីដី និងការកាន់កាប់ដីរបស់ខ្លួនដែលនឹងត្រូវប៉ះពាល់នេះហើយជាមូលហេតុនៃជំលោះ ។ - អាចមានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋក្នុងគោលបំណងចង់ទាមទារផលប្រយោជន៍មិនសមហេតុផល និង	- ក្រុមហ៊ុននឹងសហការជាមួយអាចរមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវអង្កេតដីកម្មសិទ្ធិជាក់ស្តែងក្នុងភូមិ-ឃុំតំបន់គំរោង។ - ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនឹងត្រូវធ្វើ ដើម្បីទប់ស្កាត់ក្នុងការបំផុសចលនាប្រជាពលរដ្ឋ			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	តិច	មធ្យម	ខ្លាំង	
	- បន្ថែមតួលេខដីធ្លីស្រែចំការហើយធ្វើការទាមទារពីក្រុមហ៊ុន ប្រជាពលរដ្ឋអាចមានគំនិតកាប់ឆ្ការដីព្រៃមកកាន់កាប់បន្ថែម ការកាន់កាប់ដីសាធារណៈរបស់រដ្ឋធ្វើជាកម្មសិទ្ធិខ្លួន ដើម្បីទាមទារសំណងដែលជាមូលហេតុបង្កឱ្យមានការបំផ្លាញព្រៃឈើដោយខុសច្បាប់និងអាចមានជំលោះផ្សេងៗមកពីការកាន់កាប់ដី។	ពីជនឆ្លៀតឱកាសដើម្បីទាមទារដីធ្លី និងសំណងផ្សេងៗ ដែលមិនសមហេតុផល និងមិនយោងទៅតាមច្បាប់។					
ការរស់នៅ និង មុខរបររបស់សហគមន៍មូលដ្ឋាន	ក្នុងដំណាក់កាលនេះពុំមានការប៉ះពាល់អវិជ្ជមានដល់ការរស់នៅ និងមុខរបរសហគមន៍មូលដ្ឋានទេ។ ដំណាក់កាលនេះអាចបង្កើនមុខរបរដល់ប្រជាពលរដ្ឋក្នុងដំបន់គំរោងដោយសារចូលធ្វើជាចុងភៅ ឬកម្មករគំរោង។		✓				
ប្រពៃណី វប្បធម៌ និង សាសនា	មិនមានការប៉ះពាល់ទេ ព្រោះក្រុមហ៊ុនមិនទន្ទ្រានប្រើរំលោភវប្បធម៌ប្រពៃណីអ្នកស្រុកក្នុងតំបន់ទេ ម្យ៉ាងទៀតក្រុមហ៊ុនបានជួល និងបោះជំរុំស្នាក់នៅបណ្តោះអាសន្នដោយឡែក ហើយបុគ្គលិក-កម្មករគំរោងមិនរំខាន នឹងរស់នៅលាយឡំជាមួយប្រជាពលរដ្ឋក្នុងតំបន់គំរោងឡើយ។		✓				
ទំនាស់នៃសិទ្ធិប្រើប្រាស់ទឹកស្ទឹងជាយអារែង	អាចនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅខ្សែទឹកខាងក្រោម ព្រោះមានការបារម្ភខ្លាចពុំមានទឹកប្រើប្រាស់ដូចពីមុនហើយខ្លាចក្រុមហ៊ុនមិនឱ្យប្រើប្រាស់ទឹកនៅក្រោយពេលសាងសង់វារីអគ្គិសនីរួច ។ ម្យ៉ាងទៀត ប្រជាជនមានការបារម្ភអំពីការប្រែប្រួលគុណភាពទឹកនៅពេលសាងសង់ និងពេលដំណើរការរបស់ គំរោង។	- ក្រុមហ៊ុននឹងធ្វើការសិក្សារចនាបួង់គំរោងដែលអាចធានាការបោះទឹកមកខ្សែទឹកខាងក្រោមឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅរដូវប្រាំងសំរាប់តំរូវការប្រើប្រាស់របស់ប្រជាពលរដ្ឋរស់នៅតាមដងស្ទឹងជាយអារែង និងរក្សាអេកូឡូស៊ីរបស់ស្ទឹងនេះផង។ - រីឯបញ្ហាបំពុលទឹកក្រុមហ៊ុននឹងធ្វើការគ្រោងរចនាឆ្នូវប្រព័ន្ធការពារកុំឱ្យបំពុលទឹកនៅខាងក្រោមទំនប់ ។ ក្រុមហ៊ុននឹងលាងអាងតែរដូវវស្សា និងកំណត់ពេលវេលាជាក់លាក់ឱ្យប្រជាជនបានដឹងមុន			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		ពេលបើកទឹកលាង (នៅក្រោយពេលបិទទំនប់)។					
ផ្លូវគមនាគមន៍	អាចមានការខូចខាតផ្លូវបណ្តាលមកពីការដឹកជញ្ជូនធ្ងន់ៗលើផ្លូវសាធារណៈដែលអាចមានការប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋ-កម្មករ ឬ ធ្វើឱ្យស្ទះការងារសិក្សាបង់រចនាគំរោង ដោយសារស្ថានភាពផ្លូវដឹកជញ្ជូនទ្រុឌទ្រោម តូចចង្អៀតមានចំណោទខ្លាំងឆ្លងកាត់ជ្រោះដែលមានផ្ទាំងថ្ម និងភក់។ល។ ម្យ៉ាងវិញទៀតការដឹកជញ្ជូនអាចមានគ្រោះថ្នាក់ដោយអ្នកបើកបររថយន្តដឹកគ្រឿងចក្រមិនស្គាល់ផ្លូវច្បាស់។	- ក្រុមហ៊ុននឹងរកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គំរោង។ - ក្រុមហ៊ុននឹងធ្វើការត្រួសត្រាយផ្លូវព្រមទាំងធ្វើស្ពានបណ្តោះអាសន្ន។ - ក្រុមហ៊ុននឹងប្រើរថយន្តដែលមានសុវត្ថិភាពគុណភាពល្អ និងកំណត់ទំងន់ក្នុងការដឹកជញ្ជូន ដើម្បីការសិក្សាគំរោងនេះ។		✓			
រមណីយដ្ឋាន/ទីកន្លែងកំសាន្ត(ចរាចរ)	គ្មានរមណីយដ្ឋាន/ទីកន្លែងកំសាន្ត ដែលនឹងធ្វើឱ្យប៉ះពាល់នោះឡើយ។		✓				
សុខភាពសាធារណៈ	- អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពបុគ្គលិកកម្មករបស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្ទុំ។ល។ កម្មករអាចនឹងនាំជំងឺចម្លងមកប្រជាពលរដ្ឋនៅតំបន់គំរោងដូចជា ជំងឺកាមរោគ អេដស៍ ផ្តើមនិងជំងឺផ្សេងៗមួយចំនួនទៀត។ - អាចមានការប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋ-កម្មករ ឬ ធ្វើឱ្យស្ទះការងារសិក្សាបង់រចនាគំរោង ដោយសារស្ថានភាពផ្លូវដឹកជញ្ជូនទ្រុឌទ្រោមតូចចង្អៀត។	- ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិកកម្មករដើម្បីរក្សាក្រមសីលធម៌ក្នុងការរស់នៅរបស់ខ្លួន។ ហើយក្រុមហ៊ុននឹងត្រៀមថ្នាំបង្ការដើម្បីការពារ និងព្យាបាលជំងឺឱ្យបានត្រប់គ្រាន់។ - ក្រុមហ៊ុននឹងដាក់បំរាមមិនឱ្យបុគ្គលិកកម្មករចាកចេញទៅក្នុងភូមិឬចេញក្រៅតំបន់គំរោងដោយគ្មានការអនុញ្ញាតពីអ្នកគ្រប់គ្រងឡើយ។ - ក្រុមហ៊ុននឹងប្រើរថយន្តដែលមានទំហំសមស្របនឹងស្ថានភាពផ្លូវដើម្បីជៀសវាងការគ្រោះថ្នាក់ផ្សេងៗ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាន	តិច	មធ្យម	ខ្លាំង	
សោភ័ណ្ឌភាព	ដំណាក់កាលនេះពុំទាន់មានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេពីព្រោះក្រុមហ៊ុនគ្រាន់តែធ្វើការចនាបួង់និងសិក្សានៅតំបន់ផ្ទាល់តិចតួចប៉ុណ្ណោះ ។		✓				
ដំណាក់កាលសាងសង់គំរោង							
ធនធានវប្បធម៌							
សណ្ឋានដី និងឋានលេខា	អាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោងដោយសារសកម្មភាពឈូសឆាយសំរាប់ចាក់គ្រឹះទំនប់ឈូសឆាយផ្លូវពីទំនប់ទៅអាគារថាមពល ការឈូសឆាយសាងសង់គ្រឹះអគារថាមពលផលិតភ្លើង ការជីកប្រឡាយនាំទឹកទៅអគារថាមពល ការយកដី ការយកថ្ម ពង្រាបដីស្រទាប់លើដែលមានគំរបព្រៃដើម្បីសាងសង់ផ្លូវ ថ្ពល់ ស្ពាន ទំនប់ ប្រឡាយ ការសាងសង់កន្លែងតាំងទីលំនៅថ្មីសំរាប់ផ្ទាស់ប្តូរលំនៅដ្ឋានរបស់អ្នកប៉ះពាល់ក្នុងអាង ការសាងសង់កន្លែងយកថ្ម កន្លែងយកដី កន្លែងសាងសង់អគារ ទីស្នាក់ការ និងផ្ទះបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ។ល។	- បន្ទាប់ពីបញ្ចប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគារថាមពល ទំនប់ ប្រឡាយ ការងារដីរួចក្រុមហ៊ុនធ្វើការជួសជុលទីតាំងយកថ្ម កន្លែងយកដី កន្លែងចាក់ដីសូយចោល និងកន្លែងការងារដីផ្សេងទៀត ព្រមទាំងថែទាំដាំដើមឈើ ប្រភេទរុក្ខជាតិស្រទាប់ក្រោមឡើងវិញដើម្បីការពារការហូរច្រោះដី ។ - ក្រុមហ៊ុននឹងធ្វើការសាងសង់នៅរដូវប្រាំងដើម្បីទប់ស្កាត់ការហូរច្រោះដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា ។ - ក្រុមហ៊ុននឹងមានផែនការថែទាំដើមឈើ និង ដាំបន្ថែមដែលជារបាំងនៃការហូរច្រោះ ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានររិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
ការហូរច្រោះ និងគុណភាពដី	- អាចនឹងមានការហូរច្រោះដីដោយសារការឈូសឆាយដីគំរបព្រៃឈើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ព្រោះថាតំបន់នេះជាតំបន់ខ្ពង់រាប មានភ្នំជុំវិញ ដីល្បាយខ្សាច់ នឹងងាយមានការហូរច្រោះ ជាពិសេសនៅរដូវវស្សា ។ - អាចនឹងបង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់ ។ មួយវិញទៀតនោះការចាក់ចោលដីស្មុយចេញពីការដ្ឋាននៅតំបន់ខ្ពស់វាអាចធ្វើបាត់បង់ជីរជាតិរបស់ដីស្រទាប់លើតំបន់ក្បែរនោះ បណ្តាលមកពីការហូរច្រោះដីស្មុយនេះទៅគ្របពីលើដីតំបន់ជុំវិញនោះទៀតផង ។	- ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស ។ ក្រុមហ៊ុននឹងរក្សាព្រៃឈើដែលមានស្រាប់នៅតាមមាត់អូរ/ស្ទឹងក្នុងទទឹង១៥០មពីអ័ក្សអូរ (គិតសងខាងសរុប ៣០០ម) នៅកន្លែងផ្លាស់ប្តូរលំនៅដ្ឋានថ្មីរបស់អ្នកប៉ះពាល់ក្នុងអាង ។ ការសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កត់ការកាប់ព្រៃនៅតាមមាត់អូរ/ស្ទឹង ដែលជាជំរកជីវៈចំរុះជាច្រើនប្រភេទ ។ - នៅតាមតំបន់ជំរាលភ្នំ ឬមាត់ទំនប់ដែលគ្មានគំរបព្រៃ ក្រុមហ៊ុននឹងដាំបន្ថែម ដើម្បីការពារសំណឹកដីដែលបណ្តាលមកពីខ្យល់បក់ និងទឹកភ្លៀង ។ ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី និងដាំកំរាលរុក្ខជាតិស្មៅ ឬកូនឈើតាមជំរាលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោង ដើម្បីជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ ឈូសឆាយដីនឹងធ្វើឡើងនៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក ។		✓			

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានររិធមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
ប្រព័ន្ធជលសាស្ត្រ	- អាចនឹងប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងជាយអារែងដោយសារការទប់ទំនប់កាត់ស្ទឹងជាយអារែងដើម្បីធ្វើទំនប់ទឹកដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីនិងប្រព័ន្ធទឹកផ្សេងទៀតដែលបែកចេញពីស្ទឹងនៅក្រោមទំនប់ - គុណភាពទឹកក៏អាចនឹងប៉ះពាល់ផងដែរដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុល ជាហេតុបង្កឱ្យប្រជាពលរដ្ឋដែលរស់នៅខាងក្រោមមិនអាចប្រើទឹកនេះបាន - កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅ ផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករ នៃគំរោង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬ គ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ អាចបង្កឱ្យទឹកស្ទឹងជាយអារែងបាត់បង់គុណភាពដែរ ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងជាយអារែងមានការថយចុះ និងឈានទៅដល់ការបំពុល ។	- ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ - ក្នុងពេលសាងសង់ ក្រុមហ៊ុននឹងធ្វើការកាត់បន្ថយភាពល្អក់ខ្លាំង ដោយសាងសង់ទំនប់បណ្តោះអាសន្ទព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់នេះឱ្យបានត្រឹមត្រូវ ។ - ក្រុមហ៊ុននឹងកំណត់ពេលវេលាសាងសង់នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋាននៃការងារដីផ្សេងៗ ដែលអាចហូរចូលស្ទឹង ។ - អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការពារការកំពុប/ហៀរប្រេងឥន្ធនៈ ប្រេងរំអិលទៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងឈូសឆាយដី ពង្រាបដី សំរាប់ការសាងសង់ដោយធ្វើទៅតាមលក្ខណៈទំរង់/ប្រភេទដី ដើម្បីទប់ស្កាត់ឬបន្ថយការហូរច្រោះដី ដោយសារសកម្មភាពសាងសង់របស់គំរោង ។ - ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី ។ ដាំកំរាលរុក្ខជាតិស្មៅឬកូនឈើតាមជំរៀលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោង ដើម្បី				✓	

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		ជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ឈូសឆាយដី នឹងធ្វើឡើង នៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក ។ - ក្រុមហ៊ុននឹងសាងសង់បន្ទប់ទឹក និង បង្គន់ឱ្យបានគ្រាន់ទៅតាមចំនួនកម្មករបុគ្គលិកគំរោងដោយមានអាងសិបទឹកត្រឹមត្រូវ ហើយឆ្ងាយពីប្រភពទឹកឱ្យបានយ៉ាងតិច១០០ ម ។					
ការរញ្ជួយដី (seismology)	- អាចនឹងធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងព្រះសង្ឃ ផ្លូវចេញចូលសំណង់ សុវត្ថិភាពកម្មករ និងពពួកសត្វព្រៃដែលមាននៅក្នុង និង ជុំវិញទីតាំងគំរោង ដោយសារមានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារឈូសឆាយពង្រាបដី ការកាយដីធ្វើប្រឡាយ ការស្ថាបនាផ្លូវ ការដឹកសំភារៈសំណង់/កម្មករ ការលាយបេតុង ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ ។ ល ។ - ការប្រើប្រាស់គ្រឿងផ្ទុះក៏អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដែលចូលព្រៃដើម្បីរកអនុផលព្រៃឈើដែរ ។	- ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់ រួចដាក់ផ្ទាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់ ។ - ការប្រើប្រាស់គ្រឿងផ្ទុះ គឺក្រុមហ៊ុននឹងកំណត់ក៏រឹតរញ្ជួយ និងកំលាំងបំផ្ទុះឱ្យតូច ដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬសំណង់ផ្ទះប្រជាជន ឬ ផ្លូវដែលនៅក្បែរតំបន់បំផ្ទុះឡើយ ។ - ផ្តល់ពត៌មានផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		- ការបំផុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង ៤:00-៥:00)។					
ការបំពុលខ្យល់	អាចនឹងបំពុលខ្យល់ដោយសារផ្សែង និងធូលីដីបំភាយចេញពីការដឹកសំភារៈសំណង់ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារឈូសឆាយពង្រាបដី កាយដី/ជីកដីធ្វើប្រឡាយ/ការចោះរន្ធធ្វើទូនេល ការស្ថាបនាផ្ទះ ការបំផុះថ្មធ្វើគ្រឹះទំនប់ ការដុតព្រៃឈើដើម្បីសំអាតការដ្ឋានសំរាប់ការងារសាងសង់របស់គំរោង និងភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែស។	- ក្រុមហ៊ុននឹងប្រើគ្រឿងយន្តឬគ្រឿងចក្រណាដែលមានផ្សែងតិចក្នុងពេលសាងសង់នេះហើយនៅពេលសាងសង់នេះផងដែរក្រុមហ៊ុននឹងបាញ់ទឹកដើម្បីការពារធូលីដីហុយដើម្បីកាត់បន្ថយការបំពុលខ្យល់។ - ចំពោះព្រៃឈើវិញក្រុមហ៊ុនមិនដុតទាំងអស់នោះទេ គឺក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃឈើដើម្បីដាក់ឱ្យក្រុមហ៊ុនកែច្នៃឈើដេញថ្លៃដើម្បីប្រើឈើទាំងនោះឱ្យអស់លទ្ធភាព ធ្វើយ៉ាងនេះអាចចំណេញប្រាក់ផង និងកាត់បន្ថយការបំពុលបរិយាកាសផង។ - ចំពោះការបំពុលខ្យល់ដោយសារធាតុផ្ទុះ ក្រុមហ៊ុននឹងជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង។ - ក្រុមហ៊ុននឹងត្រៀមឧបករណ៍ពន្លត់អគ្គីភ័យនិងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គីភ័យ ។		✓			
ការបំពុលទឹក	- អាចនឹងមាននៅនឹងស្ទឹងជាយអាវែងដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង បណ្តាលមកពីការខូង ឬការងារដីការងារបេតុង ការងារចោះរន្ធធ្វើទូនេល និងការងារបំផុះថ្ម	- ក្រុមហ៊ុនមានផែនការធ្វើការឈូសឆាយទ្រង់ទ្រាយធំនៅរដូវប្រាំងមិនធ្វើនៅរដូវវស្សាទេ និងធ្វើរបាំងការពារកកកុរដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំង			✓		

ឆន្ទធាតុបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	នៅក្បែរប្រភពទឹក។ - អាចនឹងមានការប៉ះពាល់គុណភាពទឹកស្ទឹង ដោយសារកាកសំណល់រឹង-រាវមកពីផ្ទះបាយសំភារៈសំណង់ដោយបុគ្គលិក-កម្មករ ការហូរច្រោះដីដោយសារការឈូសឆាយគំរបព្រៃធ្វើហេដ្ឋារចនាសម្ព័ន្ធគំរោង ការបំភាយធូលីដីពីការដឹកជញ្ជូន និងការងារដីផ្សេងៗដើម្បីសាងសង់។ - អាចនឹងមានការបំពុលដល់ទឹកស្ទឹង បើក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងនេះមិនមានការគ្រប់គ្រងបានល្អនូវប្រេងឥន្ធនៈ សារធាតុគីមី សំណល់សំភារៈសំណង់ សំណល់រឹង-រាវគ្រប់ប្រភេទចេញ ឬ ធ្លាយពីគ្រឿងចក្រ រថយន្តទៅក្នុង ឬក្បែរតំបន់ប្រភពទឹក។ - នាពេលសាងសង់ក្រុមហ៊ុនមានបុគ្គលិក-កម្មករមានចំនួនអតិបរមាប្រហែល ១១០០នាក់ បានប្រើប្រាស់ទឹកស្ទឹងជាយ៉ាងច្រើនក្នុងរូបភាព ដូចជា ការបន្ទោរបង់ ការងូត ការបោកសំលៀកបំពាក់ ការលាងឧបករណ៍ផ្សេងៗ បន្ទាប់ពីការងារប្រចាំថ្ងៃ អាចនឹងបង្កឱ្យ មានការបំពុលទឹកផងដែរ។ - ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាល ធ្វើឱ្យមានការហូរច្រោះចូលទៅក្នុងប្រភពទឹកនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់ទៅលើប្រភពទឹកនៅរដូវប្រាំងក៏បានធ្វើមានការបំពុលទឹកដែរ។	សាងសង់ ជាពិសេសនោះក្រុមហ៊ុននឹងធ្វើការអប់រំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង។ - ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ បន្ទប់ទឹកឱ្យគ្រប់គ្រាន់ព្រមទាំងរៀបចំឧបករណ៍ប្រមូលសំណល់រឹងយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពឆ្ងាយពីប្រភពទឹក។ - ក្នុងនោះក៏មានការសាងសង់អាងប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់ (អាងសិបទឹកទំនើប) ដែលបង្ហូរចេញពីការិយាល័យ ផ្ទះបុគ្គលិកដែលស្នាក់នៅសំរាប់ប្រើក្នុងពេលសាងសង់រហូតដល់ធ្វើប្រតិបត្តិការ និងថែទាំគំរោង។ - ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ តាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។ ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អ មិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គំរោង។					

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាន	តិច	មធ្យម	ខ្លាំង	
		- ក្រុមហ៊ុននឹងដាំព្រៃឈើឡើងវិញតាមកន្លែងចាក់ចោលដីសួយ កន្លែងយកដី និងថ្ម ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។					
ការបំពុលដី	- អាចនឹងមានការបំពុលដី ដោយសារការកំពុបនៃប្រេងឥន្ធនៈ ការកំពុប នៃសារធាតុគីមី ការចោលសំណល់រឹង-រាវគ្រប់ប្រភេទដែលចេញឬធ្លាយពីគ្រឿងចក្រថយន្តសំណល់សំភារៈសំណង់ ។ល។ រួមទាំងកាកសំណល់ចេញពីផ្ទះបាយផងដែរក្នុងពេលដំណើរការគំរោងនេះ។ - អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរ ដោយសារការចាក់ដីសួយដែល ដីកចេញពីតំបន់គំរោង។ - អាចនឹងមានការបំពុលដីដោយសារការគ្រប់គ្រងនូវសារធាតុផ្ទុះមិនបានល្អធ្វើឱ្យធ្លាក់ទៅលើដីនៅពេលរៀបចំធ្វើការបំផ្ទុះដើម្បីធ្វើការសាងសង់ទំនប់។ - ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាល ធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សានិងមានសំណឹក ដោយសារខ្សាច់នៅរដូវប្រាំងក៏បានធ្វើដីបាត់បង់គុណភាពដែរ។	- ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពុប ឬជ្រាបចូលដី ។ គ្រប់គ្រងកាកសំណល់រឹង-រាវ គ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជាចាត់វិធានការយ៉ាងតឹងរឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី ។ - សំណល់រឹង-រាវចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅក្នុងពេលធ្វើការសាងសង់ប្រតិបត្តិ និងថែទាំគំរោង មិនត្រូវបង្ហូរចេញទៅលើដីដោយមិនទាន់ធ្វើប្រព្រឹត្តិកម្មនោះទេ ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មដើម្បីសំណល់រាវទាំងនេះ ហើយប្រុងប្រយ័ត្នកុំឱ្យមានការបំពុលដី និងប្រភពទឹក ហើយស្វែងរកទីតាំងសមស្របសំរាប់ទុកដាក់សំណល់រឹង។ - ក្រុមហ៊ុននឹងដាំព្រៃឈើឡើងវិញតាមកន្លែងចាក់ចោលដីសួយ ជាជំរើសមួយល្អដែលក្រុមហ៊ុននឹងអនុវត្តនៅកន្លែងយកដី យកថ្ម ចាក់ដីសួយ ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុល			✓		

មធ្យោបាយបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ពាន	តិច	មធ្យម	ខ្លាំង	
		ដីនៅក្បែរនោះ។					
សំលេង និង រំញ័រ	អាចនឹងធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និង ពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំង គំរោងដោយសារមានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ។ ល។	- ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំលេងតិច ។ - ក្រុមហ៊ុននឹងកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់រួចដាក់ផ្ទាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគំរោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។ - ក្រុមហ៊ុននឹងកំណត់ភិតរញ្ជួយនិងកំលាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬសំណង់ផ្ទះប្រជាជន ឬផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ។ - ក្រុមហ៊ុននឹងផ្តល់ពត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន នូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគំរោងនិងប្រជាពលរដ្ឋដែលរស់នៅទីនោះ - ចំពោះការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង ៤:00-៥:00ល្ងាច) ។ - ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់ប្រជាពលរដ្ឋ និងសត្វព្រៃក្នុងតំបន់ គំរោងនេះ។			✓		

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
ធនធានអេកូឡូស៊ី							
មច្ឆជាតិ	- អាចប៉ះពាល់ដល់ផ្លូវចេញចូល និងធារទឹកសំរាប់ការរស់របស់មច្ឆាជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្នកាត់ស្ទឹងជាយអារែង ដើម្បីសាងសង់ទំនប់វារីអគ្គីសនីនេះ ។ វាក៏អាចបង្កឱ្យមានការផ្លាស់ប្តូរស្ថានប្រព័ន្ធ និងចរន្តលំហូរទឹកផ្នែកខាងក្រោមទំបន់។ ជាងនេះទៅទៀត ដោយសារសកម្មភាពសាងសង់គំរោងសំណល់ចេញពីបង្គន់របស់បុគ្គលិក ផ្ទះបាយ និង សំណល់រឹង-រាវចេញពីគ្រឿងចក្រចូលទៅក្នុងស្ទឹងអាចផ្តល់ផលអវិជ្ជមានដល់ មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹកអាចបានដែរ ។ - ពិតណាស់ស្ទឹងជាយអារែងមានប្រភេទត្រីនាគរស់នៅតាមខ្សែទឹកខាងក្រោមនៃទំនប់ Site A និងនៅខ្សែទឹកខាងលើនៃអគារថាមពលនឹងត្រូវរងគ្រោះដោយសារកង្វះទឹក និងការបំពុលទឹកពីការដ្ឋានសាងសង់បើមិនមានការយកចិត្តទុកដាក់ទេនោះ ។	- ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋានទំនប់ដែលមានសណ្ឋានដូចផ្លូវទឹកចាស់ (មិនចោទ) ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរ នៃជីវសាស្ត្រក្នុងទឹកពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋានដើម្បីផ្តល់ទឹកឱ្យគ្រប់គ្រាន់ដល់ផ្នែកខាងក្រោម ។ អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការការពារកំពុបប្រែងឥន្ធនៈ ប្រេងរំអិល នៅលើដី និងក្នុងទឹកក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងគ្រប់គ្រង ការពារសំណល់រឹង-រាវគ្រប់ប្រភេទ ដោយរៀបចំប្រមូលសំណល់រឹង និងសំរាមដុតបំផ្លាញចោល នៅទីតាំងដែលមានសុវត្ថិភាព ។ - ក្រុមហ៊ុននឹងណែនាំអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់កាកសំណល់រឹង-សំណល់រាវជាពិសេសការកំពុបប្រែងឥន្ធនៈ ប្រេងរំអិលនៅលើដីដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង។ - ក្រុមហ៊ុននឹងមានវិធានការដើម្បីជំនួសសំណង់សិល្បៈការសំរាប់ឱ្យត្រីឆ្លងកាត់ដោយធ្វើអាងត្រី និងសង់			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		ស្ថានីយ៍សំរាប់ បង្កាត់ពូជត្រី។ យោងតាមបទពិសោធន៍របស់ក្រុមហ៊ុនចិនបានឱ្យដឹងថាមានតែ ៤០ ស្ថានីយ៍វារីអគ្គិសនីប៉ុណ្ណោះក្នុងចំណោមស្ថានីយ៍វារីអគ្គិសនីរាប់ពាន់ ដែលមានសំណង់សំរាប់ត្រីឆ្លងកាត់ហើយលទ្ធផលក្នុងការប្រើប្រាស់សំណង់នេះផងដែរ ដូចជាមិនសូវទទួលបានផលល្អទេ ។ដូច្នេះហើយក្រុមហ៊ុនក៏ជ្រើសយកវិធីដូចបានរាយរាប់ខាងលើមកជំនួសវិញ។ រីឯបញ្ហាប៉ះពាល់ដល់ទីជំរកសត្វក្រពើភ្ជាវិញក្រុមហ៊ុននឹងសហការជាមួយអង្គការនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទីជំរកថ្មីសំរាប់សត្វក្រពើភ្នំ និងកូនក្រពើអាចរស់នៅ និងបន្តពូជបានមុននឹងបំពេញទឹកក្នុងអាង។					
ធនធានព្រៃឈើ និងជំរកសត្វព្រៃ	អាចនឹងប៉ះពាល់ដល់ផ្ទៃដីសរុប ១២.៣២៥.៣៧ហ.ត ក្នុងនោះមានព្រៃស្រោង ៣.០៦៧ ហ.ត (៥៩ប្រភេទ) ពាក់កណ្តាលស្រោង ៣.៧៩០ ហ.ត (៤៣ប្រភេទ) ព្រៃល្បោះ ៣៧ ហ.ត (២៦ ប្រភេទ) ព្រៃគុម្ពោធ ១០ ហ.ត ព្រៃដុះឡើងវិញ ១.១៣៣.៣៧ហ.ត (៤១ប្រភេទ) និងព្រៃល្បាយឫស្សី ៤ហ.ត (១៩ប្រភេទ) ។ ព្រៃឈើទាំងនេះជាជំរកសត្វព្រៃក្នុងតំបន់ជាច្រើនប្រភេទដូចមាន ចែងក្នុងជំពូក៤ ចំណុច ៤.២.៥.៣ នេះដែលជាការព្រួយបារម្ភ និង សោកស្តាយរបស់ប្រជាជន និង	- ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានបង្ហាញនៅក្នុងបង្គរចនាគំរោងលំអិតឡើយ។ - ក្រុមហ៊ុននឹងធ្វើការប្រឹក្សាជាមួយអង្គការអភិរក្សអន្តរជាតិ(CI) និងអង្គការនានាដែលពាក់ព័ន្ធរកទីតាំងសមស្របក្នុងតំបន់ក្បែរព្រៃដែលបាត់បង់ដោយសារសកម្មភាពគំរោងសំរាប់ដាំឈើទុកជាជំរកដល់សត្វព្រៃផងនិងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះ ។			✓		

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានរំរិធមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
	រាជរដ្ឋាភិបាលចំពោះសម្បត្តិ ធនធានធម្មជាតិរបស់កម្ពុជា ។	- ក្រុមហ៊ុននឹងធ្វើការសហការជាមួយរដ្ឋបាលព្រៃ ឈើ និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលនឹងកើតមានឡើងជាយថាហេតុលើព្រៃ ឈើដែលនៅជាប់នឹងតំបន់គំរោងក្នុងដំណាក់កាលនៃការសាងសង់នេះ ។ ក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃ ឈើ ដើម្បីបង់ពន្ធជូនរដ្ឋតាមច្បាប់ព្រៃឈើ ។ - ក្រុមហ៊ុននឹងទុកព្រៃតាមដងអូរ ១៥០ម ចេញពី អ័ក្សអូរ (សរុប៣០០ម) នៅតំបន់តាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ ហើយទុករបៀងសត្ត ៣០០ម ភ្ជាប់ពីភ្នំទៅព្រៃការពារ នៅក្បែរនោះ (មើលផែនទីលេខ៤) ។ នៅកន្លែងការពារព្រៃតាមដងអូរ និង របៀងសត្ត្រព្រៃនេះក្រុមហ៊ុននឹងសហការជាមួយ អង្គការ CI បោះព្រំប្រទល់ និងដាក់ ផ្លាកសញ្ញាព្រៃការពារដើម្បីឱ្យប្រជាពលរដ្ឋងាយមើលឃើញ ។					
ជីវសាស្ត្រសត្វព្រៃ	- តំបន់គំរោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្ស ដូចជា ថនិកសត្ត ចំនួន ៥៣ប្រភេទ បក្សី១១៣ប្រភេទ ឧរុង្គសត្ត ៣១ប្រភេទ មច្ឆជាតិ ៤៣ប្រភេទ ដូចមានចែងក្នុងជំពូក៤ ចំណុច ៤.២.៦ ។ សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារី អគ្គិសនីនេះអាចមានការបាត់បង់ ឬថយចុះនូវសត្វព្រៃមួយ ចំនួន ដូចជា ពង្រូល ដំរី ឈ្លូស ប្រីស កាំប្រម៉ា ក្រពើ ពពួកពស់ ជ្រូកព្រៃជាដើម ដោយសារបាត់ទីជំរក ឬផ្តាច់ផ្លូវ ទំនាក់ទំនងរបស់វា ។ - អាចនឹងនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយ	- ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសំរាប់ការការពារបរិស្ថាន ដូចជា ការធ្វើទីជំរកសត្វក្រពើ បង្កើនការ ទប់ស្កាត់ ការពារ និងថែរក្សាសត្វព្រៃ ។ ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណា ដែលបង្ក សំលេង និងរំញ័រដើម្បីកុំ ឱ្យមានការរំខាន ឬ ផ្អើលសត្ត ព្រៃក្នុងតំបន់គំរោង និងតំបន់ជិតគំរោង ។ ចំពោះសំឡេងរំញ័រវិញក្រុមហ៊ុននឹងកំណត់ក៏រិតរញ្ជួយព្រមទាំងកំលាំងបំផ្ទុះហើយប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្ត			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
	សារមានសំលេងរំខានខ្លាំងៗចេញពីម៉ាស៊ីន គ្រឿងយន្តពេលកាប់ឆ្ការគំរបព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសំភារៈសាងសង់ និងសំឡេងរបស់បុគ្គលិក-កម្មករគំរោង ។ ក្នុងនោះការជ្រើសរើសនូវបុគ្គលិក-កម្មកររាប់រយនាក់ចូលមកធ្វើការនៅតំបន់នេះសំរាប់ការសាងសង់គំរោងនឹងអាចមានសកម្មភាពបរបាញ់ ឬ ចាប់សត្វព្រៃពីសំណាក់បុគ្គលិក-កម្មករគំរោងទាំងនោះ ។	ព្រៃទាំងនោះ ។ - ក្រុមហ៊ុននឹងសហការជាមួយជំនាញរដ្ឋបាលព្រៃឈើជួយណែនាំ អប់រំដល់បុគ្គលិក-កម្មករគំរោងឱ្យមានការយល់ដឹងអំពីច្បាប់ និងបំរាមក្នុងការការពារការថែរក្សាសត្វព្រៃ ហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេដែលប្រព្រឹត្តិខុសទៅនឹងបំរាម ។ រីឯម្ហូបអាហារវិញក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃនោះ ។ ក្រុមហ៊ុននឹងផ្តត់ផ្តង់ស្បៀង ទៅតំបន់គំរោងពីកោះកុង ។ - ក្រុមហ៊ុននឹងទុកព្រៃតាមដងអូរ១៥០មចេញពីអ័ក្សអូរ (សរុប៣០០ម) នៅតំបន់តាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ ហើយទុករបៀងសត្វ ៣០០ម ភ្ជាប់ពីភ្នំទៅព្រៃការពារនៅក្បែរនោះ (មើលផែនទីលេខ ៤) ។ នៅកន្លែងការពារព្រៃតាមដងអូរ និងរបៀងសត្វព្រៃនេះ ក្រុមហ៊ុននឹងសហការជាមួយអង្គការ CI បោះព្រំប្រទល់ និង ដាក់ផ្លាកសញ្ញាព្រៃការពារ ដើម្បីឱ្យប្រជាពលរដ្ឋងាយមើលឃើញ ។ - ក្រុមហ៊ុននឹងផ្តល់មូលនិធិការពារបរិស្ថានឱ្យបានគ្រប់គ្រាន់ ហើយធ្វើការសហការជាមួយ CI ដើម្បីពង្រឹងបន្ថែមកងកំលាំងអនុរក្ស (Ranger) ដើម្បី					

ឥទ្ធពលបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ពាន	តិច	មធ្យម	ខ្លាំង	
		ទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ ។					
តំបន់អភិរក្សភ្នំក្រវាញកណ្តាល ក្រវាញខាងត្បូង និង ពាមក្រសោប	- អាចនឹងមានការប៉ះពាល់ដល់តំបន់អភិរក្សធនធានធម្មជាតិភ្នំក្រវាញកណ្តាលចំនួន ៤.៣៨២ ហ.ត (ប៉ះក្នុងអាង និងខ្សែចម្ងួង ៥៦ហ.ត) ក្រវាញខាងត្បូង ចំនួន ១៨៦ហ.ត (ប៉ះខ្សែចម្ងួង) និងពាមក្រសោបចំនួន ០.៦ហ.ត (ប៉ះខ្សែចម្ងួង) ដោយសារគំរោងសាងសង់ទំនប់វារីអគ្គីសនីស្ថិតនៅក្នុងទឹកដីនៃតំបន់អភិរក្សនេះ ដែលនឹងបង្កឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ក្នុងតំបន់នេះ ។ - ការបំពុលបរិស្ថាននឹងអាចមាននៅក្នុងតំបន់អភិរក្ស និងការពារធនធានធម្មជាតិទាំងនេះ ដូចជា ការបំពុលខ្យល់ បំពុលទឹក ដោយសារសំណល់បញ្ចេញចោលពីកន្លែងសាងសង់ និងចេញពីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ កន្លែងស្តុកគ្រឿង និងសំភារៈសំណង់ និងពីគ្រឿងចក្រ ។ - អាចមានការទន្ទ្រានចូលក្នុងព្រៃនៃតំបន់ទាំងនេះពីសំណាក់ក្រុមកម្មករក្រោយពីការងារដើម្បីរកអនុផលព្រៃឈើឬចាប់សត្វធ្វើម្ហូប ឬធ្វើអាជីវកម្ម ។ - អាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃ ដីតំបន់អភិរក្សទាំងនេះ ពីសំណាក់ជនឆ្លៀតឱកាសដោយសារគំរោងធ្វើផ្លូវនៃគន្លងខ្សែចម្ងួងនិងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគំរោង ។	- ក្រុមហ៊ុននឹងត្រៀមមូលនិធិបំរុងសំរាប់ការ ការពារបរិស្ថាន ដូចជា ការធ្វើទីជំរកសត្វក្រពើ បង្កើនការទប់ស្កាត់ ការពារ និង ថែរក្សាសត្វព្រៃ ។ - ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្ដើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ក្បែរខាង ។ ដូច្នោះក្រុមហ៊ុននឹងកំណត់ការិតរញួយ កំលាំងបំផុះ និងប្រើប្រាស់ម៉ាស៊ីនដែលមានសំលេងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ ។ - ក្រុមហ៊ុននឹងសាងសង់បង្គន់អនាម័យសំរាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់គំរោង ។ ក្រុមហ៊ុននឹងដាក់វិធានការក្នុងការរៀបចំការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវមានសុវត្ថិភាព ជាពិសេសមិនឱ្យបំពុលបរិស្ថានក្នុង និងក្បែរតំបន់អភិរក្សទាំងនោះ ។ - ក្រុមហ៊ុននឹងធ្វើការអប់រំ និងដាក់វិន័យដល់កម្មករគំរោងរូបណាដែលធ្វើការទន្ទ្រានព្រៃក្នុងតំបន់អភិរក្សទាំងនោះ ដើម្បីចាប់ ឬបរបាញ់ ចរាចរឈើ និង				✓	

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ពាន	តិច	មធ្យម	ខ្លាំង	
		សត្វព្រៃដោយសហការជាមួយរដ្ឋបាលព្រៃឈើ អ្នកតំណាងពីក្រសួងបរិស្ថាន ។ - ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរំលោភ កាន់កាប់ដីនៅតំបន់អភិរក្សទាំងនោះ ។ - ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំ និងដាក់វិន័យដល់កម្មករគំរោង មិនឱ្យធ្វើការទន្ទ្រាន ព្រៃដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ហើយសហការជាមួយតំណាងពីក្រសួងបរិស្ថាន ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរំលោភកាន់កាប់ដីព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។					
បរិស្ថានសង្គម / សេដ្ឋកិច្ច							
ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋាន ឡើងវិញ	- អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋ ដែលរស់នៅខាងលើ និងខាងក្រោមនៃទំនប់ Site A ចំនួន ២.៦២៤ ហ.ត ដែលកាន់កាប់ដោយ ៣៨៩ គ្រួសារ ដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។ - នឹងមានការជំលៀសប្រពលរដ្ឋទៅនៅកន្លែងតាំងទីលំនៅថ្មី ចំនួន ១៨៩ គ្រួសារ ត្រូវជា ៨៩៩ នាក់ ដោយសារនៅពេល	- ក្រុមហ៊ុននឹងរៀបចំផែនការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង រួមទាំងមានសំណងត្រឹមត្រូវ និងយុត្តិធម៌ ។ - ក្រុមហ៊ុននឹងមិនទន្ទ្រានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ដោយសន្តិវិធី (យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង			✓		

Draft

ទងទាងបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
	ដំណើរការគំរោងមានការលិចលង់ដីអាងចំនួន ៩.៤៧៤ ហ.ត ។ - ការតាំងទីលំនៅថ្មីនេះដែរ នឹងមានការកាប់ព្រៃ ឈូសឆាយពង្រាបដីដើម្បីធ្វើផ្ទះ អាចបង្កឱ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិខ្លះ ដូចជាព្រៃឈើ និងសត្វព្រៃ ។	៣០) ឡើយដូចជា: ដីភូមិ ដីចំការ និងដីសហគមន៍ ។ - ក្រុមហ៊ុននឹងរៀបចំកន្លែងតាំងទីលំនៅថ្មី ដែលមានទីតាំងនៅក្បែរគំរោងនេះ ហើយមានស្ថានភាពភូមិសាស្ត្រប្រហាក់ប្រហែលកន្លែងដែលគាត់ធ្លាប់រស់នៅ ។ នៅក្នុងកន្លែងតាំងលំនៅថ្មីនេះក្រុមហ៊ុននឹងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទឱ្យបានប្រសើរ ជាងកន្លែងដែលគាត់ធ្លាប់រស់នៅ ។ - ដើម្បីឱ្យប្រជពលរដ្ឋដែលតាំងទីលំនៅថ្មី និងប្រជាពលរដ្ឋរស់នៅក្បែរតំបន់គំរោងមានការរស់នៅថ្លៃថ្នូរ និងងាយស្រួលក្រុមហ៊ុននឹងធ្វើការផ្តត់ផ្តង់អគ្គិសនីជូនតំបន់នោះ និងភូមិជុំវិញដោយមានតំលៃសមស្របទៅតាមកំរិតជីវភាពរស់នៅ ។ - ចំពោះដីធ្លីរបស់ប្រជាពលរដ្ឋវិញ ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តទៅតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាល និងសម្របសម្រួលនូវទំនាស់ដីធ្លីទាំងឡាយណាដែលកើតមានដោយសារសកម្មភាពសាងសង់គំរោងនេះ ។ ការជ្រើសរើទីតាំងថ្មីនេះ នឹងត្រូវសហការជាមួយរដ្ឋាបាលព្រៃឈើ អាជ្ញាធរដែនដី មន្ទីដែនដី នគរូបនីយកម្ម និងមន្ទីបរិស្ថាន					

Draft

ឥទ្ធពលបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ថ្មាន	តិច	មធ្យម	ខ្លាំង	
		ដើម្បីរកទីតាំងណាដែលសមស្រប។ - ក្រុមហ៊ុននឹងឱ្យអាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោង ដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង។					
ការរស់នៅ និងមុខរបរ របស់សហគមន៍មូលដ្ឋាន	- អាចនឹងមានផលប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយសារក្រុមហ៊ុនជំលៀសប្រជាពលរដ្ឋទៅនៅទីកន្លែងតាំងលំនៅថ្មី ដែលមិនទាន់បានអភិវឌ្ឍន៍សមស្របតាមផែនការនៃការតាំងលំនៅដ្ឋានថ្មី ។ - ប្រជាពលរដ្ឋនៅក្នុងតំបន់នេះនឹងមានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួនផងដែរ នៅពេលមានការតវ៉ាអំពីសិទ្ធរស់នៅ និងកិច្ចសន្យាដែលបានចែងក្នុងផែនការ នៃការតាំងលំនៅដ្ឋានឡើងវិញនេះ ។ រីឯមុខរបរ និងការងារវិញត្រូវបានបាត់បងដោយសារគ្មានដីធ្វើស្រែចំការ និង ចំណាយពេលតែរៀបចំផ្ទះសំបែងនៅទីតាំងថ្មី។	- ក្រុមហ៊ុននឹងសហការជាមួយអង្គការពាក់ព័ន្ធនានា ដូចជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ន ក្រសួងពាក់ព័ន្ធ ដែលតំណាងឱ្យរាជរដ្ឋាភិបាលធ្វើការដោះស្រាយ និងគោរពតាមផែនការតាំងទីលំនៅដ្ឋានថ្មីឡើងវិញ។ - ក្រុមហ៊ុននឹងឱ្យអាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោងដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង ។ - ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដី ផ្សព្វផ្សាយអំពីគោលបំណង និងគោលការណ៍ផ្តល់សំណងនៃការប៉ះពាល់ដោយសារគំរោងនេះ។		✓			
ប្រពៃណី វប្បធម៌ និង សាសនា	- អាចនឹងមានការប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និង សាសនារបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដោយសារក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួនដែលមកពីតំបន់ ឆ្ងាយខុសៗគ្នា ។ - អាចនឹងមានការប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយរបស់ប្រជាពលរដ្ឋ ដូចជា ព្រៃអ្នកតា ឬទីទួល ព្រៃកប់ខ្មោច	- ក្រុមហ៊ុននឹងសិក្សាស្វែងយល់អំពីទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងដោយធ្វើការផ្សព្វផ្សាយហើយនឹងអប់រំណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួន អំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	រូបសំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ល។ ដោយសារក្រុមហ៊ុនធ្វើការកាប់ឆ្ការដីព្រៃឈើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។ - អាចមានការប៉ះពាល់ដល់ប្រពៃណីវប្បធម៌របស់បុគ្គលិកកម្មករគំរោង ដែលមានប្រពៃណី វប្បធម៌ និងភាសាខុសគ្នា ដោយសារក្រុមហ៊ុនមានកម្មករចិន និងខ្មែរធ្វើការនៅពេលសាងសង់នេះអាចកើតមានទំនាស់រវាងជនជាតិទាំងពីរនេះ ។	និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់ ដោយមិនធ្វើការបំពាន និងល្មើសឡើយ ។ - ក្រុមហ៊ុននឹងសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតកន្លែងសក្ការៈបូជាទាំងឡាយនោះឡើងវិញដូចដែលមានកន្លងមកនៅភូមិរបស់គាត់ ។ - ក្រុមហ៊ុននឹងសហការជាមួយរដ្ឋអំណាចមូលដ្ឋានដើម្បីរកដំណោះស្រាយឱ្យបានសមស្រប នៅពេលមានទំនាស់រវាងជន ជាតិទាំងពីរនេះកើតមានឡើង ។					
ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត	- អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកស្ទឹង ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង និងគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អ ធ្វើឱ្យបំពុលដល់ប្រភពទឹកលើដីនិងក្រោមដី ដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកប្រជាពលរដ្ឋក្នុងតំបន់ ។ - បរិមាណធារទឹករបស់ស្ទឹងជាយអារែងអាចនឹងប៉ះពាល់ដោយសារការទប់ទំនប់កាត់ស្ទឹងជាយអារែងដើម្បីធ្វើអាងតំកល់ទឹកដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធទឹកផ្សេងទៀត ដែលបែកចេញពីស្ទឹងនៅក្រោមទំនប់ ។ - គុណភាពទឹកក៏អាចនឹងប៉ះពាល់ផងដែរដោយសារសកម្មភាព	- ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្ហៀងការដ្ឋានដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ ហើយនឹងសាងសង់ទំនប់បណ្តោះអាសន្នព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់ ដើម្បីធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ទឹកខ្លាំង ។ - ក្រុមហ៊ុននឹងសាងសង់នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋាន នៃការងារដីផ្សេងៗដែលអាចហូរចូលស្ទឹង ។ អប់រំដល់បុគ្គលិក-កម្មករ អំពីការទុកដាក់កាកសំណល់រឹង-រាវ ជាពិសេសការពារការកំពុប/ហៀរប្រេងឥន្ធនៈ ប្រេងរំអិលទៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានររិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
	សាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុលជាហេតុបង្កឱ្យប្រជាពលរដ្ឋដែលរស់នៅខាងក្រោមមិនអាចប្រើទឹកនេះបាន - កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃតំរោង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់អាចបង្កឱ្យទឹកស្ទឹងជាយអារែងបាត់បង់គុណភាពដែរ ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងជាយអារែងមានការថយចុះ និងឈានទៅដល់ការបំពុល ។	គំរោង ។ - ក្រុមហ៊ុននឹងឈូសឆាយដីពង្រាបដីសំរាប់ការសាងសង់ដោយធ្វើទៅតាមលក្ខណៈទំរង់/ប្រភេទដីដើម្បីទប់ស្កាត់ឬបន្ថយការហូរច្រោះដីដោយសារសកម្មភាពសាងសង់របស់គំរោង ។ - ក្រុមហ៊ុននឹងសាងសង់បន្ទប់ទឹក និងបង្គន់អនាម័យឱ្យគ្រប់គ្រាន់ទៅតាមចំនួនមនុស្ស ដោយមានអាងសិបទិកត្រឹមត្រូវ ហើយឆ្ងាយពីប្រភពទឹកចំងាយ ១០០ម យ៉ាងតិច ។ - ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់ សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដី ។ ដាំកំរាលរុក្ខជាតិស្មៅ ឬកូនឈើតាមជំរាលជើងទេរ/ជំរាលនៃទំនប់ដីបន្ទាប់ពីបញ្ចប់ការដ្ឋានរបស់គំរោងដើម្បីជួយបន្ថយការហូរច្រោះដី ។ ការសាងសង់ឈូសឆាយដី នឹងធ្វើឡើងនៅរដូវប្រាំងដើម្បីការពារការហូរច្រោះនាំឱ្យខូចគុណភាពទឹក ។					
រមណីយដ្ឋាន/ទឹកន្លែងកំសាន្ត (ចរាចរ)	ការមកលេងកំសាន្តរបស់ភ្សៀវទេសចរ ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងជួបបញ្ហាគ្រោះថ្នាក់ចរាចរតាមដងផ្លូវដ៏តូចចង្អៀត ផ្លូវកោង ជង្ហុក និងមានចំណោត និងទូលជាច្រើនកន្លែង នៅពេលមានរថយន្ត ឬគ្រឿងយន្តរបស់ក្រុមហ៊ុន ធ្វើដំណើរចុះឡើង និង	- ក្រុមហ៊ុននឹងដាក់ផ្លាកចរាចរផ្លាកប្រុងប្រយ័ត្នគ្រោះថ្នាក់នៅការដ្ឋានសាងសង់ ដើម្បីឱ្យអ្នកបើកបរភ្សៀវទេសចរណ៍ងាយឃើញនិងមានការប្រុងប្រយ័ត្នជាពិសេសនៅផ្លូវតូចចង្អៀត ផ្លូវកោង ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នុង	តិច	មធ្យម	ខ្លាំង	
	ធ្វើឱ្យរំខានដល់អ្នកទេសចរណ៍ដោយសារធូលីដី ការរាំងខ្ទប់ដោយការទប់ទំនប់បណ្តោះអាសន្នតាមផ្លូវទឹក នៃដងស្ទឹងជាយអារែងជាដើម ។	- បញ្ហាធ្វើឱ្យរំខានដល់ភ្ញៀវទេសចរណ៍ដោយសារធូលីដីក្រុមហ៊ុននឹងធ្វើការបាញ់ទឹកតាមផ្លូវដែលភ្ញៀវទេសចរណ៍ធ្វើចរាចរ ហើយថែទាំ និងជួសជុលជាប្រចាំនូវផ្លូវសាធារណៈ ដែលខ្លួនបានប្រើប្រាស់ ។ - ក្រុមហ៊ុននឹងមិនទប់ទំនប់បណ្តោះអាសន្នទប់ស្ទឹងជាយអារែងទាំងស្រុងនោះទេ គឺក្រុមហ៊ុនប្រលោះសំរាប់ឱ្យមានការឆ្លងទូកចេញចូលបាន ជាពិសេសទូកភ្ញៀវទេសចរណ៍ដែលមកកំសាន្តតាមដងស្ទឹងជាយអារែងនេះ (ច្រកនេះក៏អាចធ្វើឱ្យត្រីផ្លាស់ទីទៅមកតាមស្ទឹងជាយអារែងបានទៀតផង) ។					
ផ្លូវគមនាគមន៍	សកម្មភាពសាងសង់គំរោង និងការដឹកជញ្ជូនសំភារៈបរិក្ខាគ្រឿងចក្រចេញចូលទីតាំងគំរោង អាចបះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់ ដូចជា ការស្រុតឬ ខូចផ្លូវ ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវដែលមានចំណោត ទួល និងផ្លូវកោង ។	- ក្រុមហ៊ុននឹងធ្វើការកែលំអរផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មីដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង ហើយកន្លែងខ្លះត្រូវពង្រីកផ្លូវអាចឱ្យរថយន្តជ្បៀសគ្នាបាន និងអាចមើលឃើញគ្នាពីចំងាយដើម្បីជ្បៀសវាងគ្រោះថ្នាក់ ។ - ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជារគ្រឿងចក្រនិងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន (មិនលើសទំងន់នាំឱ្យខូចផ្លូវលំរបស់សហគមន៍ ហើយល្បឿនបើកបរមិនឱ្យ			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		លើសពី ៣០ត.ម ក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០ត.មក្នុង១ម៉ោង) និងដើម្បីបញ្ជៀសគ្រោះថ្នាក់ចរាចរនានា។ - ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់ដែលមានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន ដូចជាពង្រីកផ្លូវ ចាស់ឬធ្វើផ្លូវវាងព្រមទាំងមានផ្ទាកសញ្ញាសំគាល់។ - ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវលំ ដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ។					
សុខភាពសាធារណៈ	- អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋក្នុងតំបន់ ដោយសារធូលីដី ធូលីស៊ីម៉ងត៍ ការបំផ្ទុះ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីជាដើម ។ល។ - ដោយសារតំបន់ជាយអារែងសំបូរទៅដោយព្រៃភ្នំ ជ្រោះជ្រលងអូរ និងសារធាតុរ៉ែ ដែលអាចនឹងបង្កឱ្យមានជំងឺគ្រុនចាញ់ និងគ្រុនសន្ទុំ ដល់បុគ្គលិក-កម្មកររបស់គំរោង ។ ផ្ទុយទៅវិញប្រជាពលរដ្ឋនៅតំបន់គំរោងក៏អាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ពីបុគ្គលិក-កម្មករគំរោងដែលក្រុមហ៊ុនជ្រើសរើសយកមកពីតំបន់ឆ្ងាយផងដែរ	- ក្រុមហ៊ុននឹងប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបងក្នុងសកម្មភាពការងារប្រចាំថ្ងៃ ដូចជាធ្វើផ្ទាកសញ្ញាសំគាល់ ជាភាសាខ្មែរ និងភាសាអង់គ្លេសដាក់នៅការដ្ឋានសាងសង់ថា "សុវត្ថិភាពការងារជាចំបង និង Safety first" ។ - ចំពោះការការពារធូលីដីក្រុមហ៊ុននឹងផ្តល់ម៉ាស់ការពារធូលីដីដល់បុគ្គលិក-កម្មករគំរោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គំរោងនេះ។ - ក្រុមហ៊ុននឹងសាងសង់ជំរុំស្នាក់នៅរបស់បុគលិក-		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នាន	តិច	មធ្យម	ខ្លាំង	
	- អាចនឹងមានការប៉ះពាល់ដល់សុខភាពសាធារណៈដោយសារសមាសភាពនៃជនខិលខូច ឬអ្នកចំណូលថ្មី រកស៊ីចរាចរនិងប្រើប្រាស់គ្រឿងញៀននៅក្នុងតំបន់គំរោង (ប្រជាជនក្នុងតំបន់ និងបុគ្គលិក-កម្មករគំរោង) ។ - ការងារសាងសង់ទំនប់វារីអគ្គីសនី ជាការងាររួមមួយមានទំហំធំ ហើយនិងងាយរងគ្រោះថ្នាក់ដល់ប្រជាពលដ្ឋនៅក្បែរតំបន់គំរោង និងបុគ្គលិក-កម្មករគំរោង ដោយសារមិនចាប់អារម្មណ៍ និងយកចិត្តទុកដាក់អំពីសុវត្ថិភាពការងារ ។ - ក្នុងតំបន់គំរោងជាតំបន់ដាច់ស្រយាលពុំសូវមានមនុស្សរស់នៅ ហើយទំលាប់របស់អ្នកស្រុកនិយមប្រើប្រាស់ទឹកស្ទឹងអូរ គឺគ្មានប្រភពទឹកស្អាតសំរាប់បរិភោគទេ ។ ម្យ៉ាងទៀតទីនេះគ្មានទីផ្សារលក់ផលិតផលទឹកស្អាត (ទឹកសុទ្ធ) នោះទេដែលជាហេតុធ្វើឱ្យបុគ្គលិក-កម្មករងាយទទួលនូវជំងឺរាគូរស និងជំងឺផ្សេងៗ ។	កម្មកររបស់គំរោងឱ្យបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាត មានបង្គន់អនាម័យគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គំរោង ។ - ក្រុមហ៊ុននឹងមានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខាគ្រប់គ្រាន់ជាប្រចាំសំរាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គំរោង ហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ ។ - បញ្ហាជំងឺកាមរោគក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មកររបស់ខ្លួន ក្នុងការទប់ស្កាត់ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។ - ពាក់ព័ន្ធទៅនឹងការជួញដូរ ចរាចរ ប្រើប្រាស់គ្រឿងញៀន និងមនុស្ស ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការជួញដូរ ចរាចរគ្រឿងញៀន និងមនុស្សឱ្យបានល្អប្រសើរ ។					

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
		- ក្រុមហ៊ុននឹងបង្កើនការសហការថែមទៀត ជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ ។ - ក្រុមហ៊ុននឹងគោរពនូវច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តន៍គំរោងនេះ ដើម្បីឱ្យមានភាពរលូនដោយសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធ ។					
សោភ័ណ្ឌភាព	- ការសាងសង់បង្គោល និងខ្សែនាំភ្លើង ដែលមានកំលាំងភ្លើងខ្ពស់ ហៅថា High Viltage Transmission Line ពីស្ថានីយ៍ផលិតភ្លើងទៅស្ថានីយ៍រងអូរសោម អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងបីដែលតំបន់នេះ នឹងក្លាយទៅជាតំបន់ទេសចរណ៍ទេសភាពធម្មជាតិនោះដែរ ដោយសារការរៀបចំបង្គោលខ្សែបណ្តាញភ្លើងមិនរត់តាមជួរល្អ និងកាប់ឆ្ការព្រៃឈើក្នុងតំបន់ទាំងនេះ ។	- វិធានការសាងសង់បង្គោល និងខ្សែនាំភ្លើងនេះ ក្រុមហ៊ុននឹងជ្រើសយកទិសតំរង់ឱ្យបានសមស្របហើយធ្វើតន្លងខ្សែនាំអគ្គិសនីឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា ដើម្បីបន្ថយការរំខានដល់ការមើលឃើញទេសភាព តាមដងផ្លូវពីសំណាក់អ្នកធ្វើដំណើរឆ្លងកាត់តំបន់នេះ ។ - ចំពោះការប៉ះពាល់សោភ័ណ្ឌដោយសារធូលីដី ក្រុមហ៊ុននឹងធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុងប្រើប្រាស់សាងសង់គំរោង ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ពាន	តិច	មធ្យម	ខ្លាំង	
	- ការហុយធូលី ដោយសារការឈូសឆាយ ការបំផ្ទុះថ្ម ការដុតព្រៃសំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ។	- ម្យ៉ាងវិញទៀតក្រុមហ៊ុនមិនត្រឹមតែជ្រើសរើសយកគ្រឿង ផ្ទុះ ដែលមានកំលាំងរំញ័រ និងសំឡេងតិចនោះទេថែមទាំងមិនដុតព្រៃសំរាប់សំអាតអាងទៀតផង។ - ក្រុមហ៊ុននឹងសហការជាមួយក្រុមហ៊ុនគ្រឿងសង្ហារឹមដើម្បីប្រើប្រាស់ឈើនោះឱ្យអស់លទ្ធភាព ទាំងដើម និងមែក (មែកឈើតូចៗធ្វើធ្យូង និងឈើធំៗសហការជាមួយរដ្ឋបាលព្រៃឈើប្រមូលទុកដេញថ្លៃបង់ចំណូលជូនរដ្ឋ)។					

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានររិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
ហានិភ័យ (Risk).	- អាចនឹងមានជួបហានិភ័យ ដោយសារគ្រោះធម្មជាតិ ដូចជាការរញ្ជួយដី បន្ទុះភ្នំភ្លើង នៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីខ្យល់ព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ ដែលជាហេតុបង្កឱ្យមានមហន្តរាយធំ៦ ដូចជា ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់៦របស់គំរោង ដែលកំពុងសាងសង់ ការបាត់បង់ឬខូចខាតសំភារៈ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។ - ការធ្វេសប្រហែសអាចនឹងកើតមានការផ្ទុះសំភារៈគ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ឬអំពើភេវរកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់៦របស់គំរោងនិងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។ - សភាពការណ៍នយោបាយប្រែប្រួលអាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជាក៏ជាឧបសគ្គដល់ការងារសាងសង់គំរោង ឬសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងក៏សឹងមាន ។	- ក្រុមហ៊ុនបានធ្វើការសិក្សារចនាប្លង់វិស្វកម្មនិងគុណភាពការសាងសង់ដែលអាចធានាមិនឱ្យមានការបាក់ទំនប់និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនី ជាយអាវែងនេះឡើយ ។ - ក្រុមហ៊ុនគួរតែមានវិធានការសមស្របណាមួយដើម្បីរក្សាសន្តិសុខដោយមានការសហការជាមួយស្ថាបន័ពាក់ព័ន្ធនានាក្នុងការការពារការបំផ្ទុះ.អគ្គិភ័យនិងបញ្ហាភេរវកម្មនៅក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសុវត្ថិភាពចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះ ប្រេងឥន្ធនៈដោយធ្វើការសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់រាល់អំពើភេវរកម្មក្នុងតំបន់គំរោងឱ្យទាន់ ។ - ក្រុមហ៊ុននឹងធ្វើការជូនដំណឹងរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ការបាក់ភ្នំឬការរញ្ជួយដីក្នុងតំបន់គំរោងដល់ប្រជាពលរដ្ឋដែលរស់នៅតាមដងស្ទឹងជាយអាវែងនិងព្រៃកត្រពាំងរូងទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើទាន់ពេល វេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើង ។ - ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមានបញ្ហាគ្រោះថ្នាក់ដោយចៃដន្យដូចជាការរញ្ជួយដី សង្គ្រាមនិងបាតុភូតរុញច្រានមកលើទំនប់ខ្លាំង ។ - ក្រុមហ៊ុននឹងរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសំភារៈ និងថវិកាដើម្បីធានាការសង្គ្រោះជាបន្ទាន់ នូវហេតុការខាងលើនេះទាន់សភាពការណ៍ និងមាន ប្រសិទ្ធិភាពខ្ពស់ ។				✓	ទាមទារការសិក្សា ច្បាស់ លាស់ ដើម្បីធា នាសុវត្ថិ ភាពនា ពេលអនា គត

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអរិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
ជំណាក់កាលប្រតិបត្តិ និងថែទាំគំរោង							
ធនធានរូបសាស្ត្រ							
ប្រព័ន្ធជលសាស្ត្រ (Hydrologycal System)	- អាចនឹងមានផលប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ នៃស្ទឹងជាយអារែង និងខ្សែទឹកខាងក្រោម ដោយសារការបង្ខាំងទឹកដើម្បីស្តុកទឹកទុកសំរាប់បង្កើនកំលាំងឱ្យបានគ្រប់គ្រាន់សំរាប់អូសទូបឹនភ្លើងកំលាំង ១០៨ មេហាវ៉ាត់ និងការបញ្ចេញទឹកពីទំនប់ Site A របស់គំរោងមិនគ្រប់គ្រាន់ ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងជាយអារែង ដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពល ។ - ការតំកល់ទឹកក្នុងអាងដែលមានជំរៅជ្រៅហើយផ្ទៃទឹកធំនឹងធ្វើឱ្យមានការជ្រាបទឹកចូលទៅក្នុងដីច្រើនដែលធ្វើឱ្យកំពស់ទឹកក្រោមដីនៅប៉ែកខាងក្រោមអាងកើនឡើងខ្ពស់ជាងស្ថានភាពដើមរបស់វាអាចនាំឱ្យខូចខាតដល់ដំណាំឬរុក្ខជាតិផ្សេងៗ ព្រមទាំងអាចនឹងធ្វើឱ្យមានការប្រែប្រួលរបបជលសាស្ត្រ របស់ព្រែកត្រពាំងរូង ដោយសារការបង្ហូរទឹក ពីអាងស្តុកទឹកមកខាងក្រោមមិនគ្រប់គ្រាន់ ជាពិសេសនឹងធ្វើឱ្យកំរិតប្រៃនៃទឹកព្រែកត្រពាំងរូងឡើងខ្ពស់ជាងមុនដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់អេកូឡូស៊ីរបស់ព្រែកនោះ ។	- ក្រុមហ៊ុននឹងត្រូវបញ្ចេញទឹកពីអាងស្តុកទឹកមកប៉ែកខាងក្រោមទំនប់ Site A ឱ្យបានតិចបំផុត១.៥ម^{3}/វិនាទី គឺធ្វើយ៉ាងណាដើម្បីរក្សារបបជលសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ីរបស់ស្ទឹងជាយអារែង ដែលស្ថិតនៅចន្លោះទំនប់នោះ និងអគារថាមពល ឱ្យមានការប្រែប្រួលរបបជលសាស្ត្រកំរិតអប្បបរមា ។ - ចំពោះបញ្ហាជំរាបទឹក ក្រុមហ៊ុននឹងសាងសង់គ្រឹះទំនប់ឱ្យបានល្អ មានកំរិតជំរាបទឹកតិច ហើយនឹងមានការសិក្សាស្រាវជ្រាវអំពីលក្ខណៈទឹកក្រោមដីជាប្រចាំ ។ - ក្រុមហ៊ុននឹងធ្វើការប្រតិបត្តិការគំរោងយ៉ាងណាដើម្បីបញ្ចេញទឹកពីអាងស្តុកទឹកឱ្យបានសមស្របទាំងរដូវវស្សា និងរដូវប្រាំង ដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ី និងរបបជលសាស្ត្រនៅប៉ែកខាងក្រោមអគារថាមពលឱ្យមានលំនឹង ជាពិសេស គឺធ្វើយ៉ាងណាឱ្យរក្សាធាទឹកនារដូវប្រាំងនៅស្ទឹងជាយអារែងផ្ទែកខាងក្រោមអគារថាមពលប្រហាក់ប្រហែលឬមានច្រើនជាងបន្តិចបន្តួចធ្យៀបទៅនឹងពេលមិន		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
		ទាន់មានការសាងសង់ទំនប់ ។					
គុណភាពទឹកក្រោមដី និង លើដី	- អាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការតំកល់ទឹកក្នុងអាង ដើម្បីអូសទូបឺន៣ កំលាំងសរុប ១០៨ មេហ្គាវ៉ាត់ ធ្វើឱ្យលិចផ្ទៃដី ៩.៤៧៤ហ.ត ដែលមានព្រៃឈើដំណាំ រុក្ខជាតិស្រទាប់ក្រោមស្អុយរលួយ ហើយក្នុងរុក្ខជាតិទាំងនេះមានសារធាតុសរីរាង្គ និងគីមីផ្សេងៗ ។ - ការលើកទំនប់កំពស់ ៣៦.៦ម. អាចតំកល់ទឹកក្នុងអាងក្នុងកំរិតកំពស់មធ្យមពី១៥ម-២៥ម នឹងធ្វើឱ្យទឹកមានក្លិនស្អុយ ដោយសារការរលាយអុកស៊ីសែនក្នុងទឹកមានកំរិតទាប ។ ម្យ៉ាងទៀត នៅខ្សែទឹកខាងក្រោម នឹងអាចទទួលរងផលប៉ះពាល់នូវប្រភពទឹកស្អុយពីអាងស្តុកទឹកនៅពេលដែលមានការបង្ហូរទឹកមកផ្នែកខាងក្រោម ។ - ការរលាយសារធាតុខនិកក្នុងដីដែលបង្កឱ្យមានការកើនឡើងនៃសារធាតុគីមីទឹកក្រោមដី ដោយសារការតំកល់ទឹកក្នុងអាងហើយនិងការជ្រាបទឹកពីអាងស្តុកទឹកទៅក្រោមដីដែលមានក្លិនស្អុយដោយសារទឹកមានកំរិតអុកស៊ីសែនរលាយទាប នឹងធ្វើឱ្យគុណភាពទឹកក្រោមដីថយចុះ ។ - ចំពោះការបំពុលទឹកដោយសារការលាងបាតអាង ដោយបង្ហូរល្បាប់ភក់ និងខ្សាច់ចេញពីបាតអាងនៅរដូវវស្សា ដែលបង្កឱ្យមានក្លិនស្អុយ និងធ្វើឱ្យទឹកស្ទឹងល្អក់ នឹងធ្វើឱ្យមានការ	- ក្រុមហ៊ុននឹងធ្វើការសំអាតផ្ទៃអាងជាមុនសិន មុននឹងតំកល់ទឹកក្នុងអាង ។ ការសំអាតនេះរួមមានការកាប់សំអាតព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមទាំងនោះចេញ ។ - ក្រុមហ៊ុននឹងសាងសង់ប្រឡាយចំហរនាំទឹកពីទំនប់ Site A មកអគារថាមពល ដែលមានចំងាយ ៤០៣៧ម ។ ការសាងសង់នេះ នឹងធ្វើឱ្យទឹកមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ហើយធ្វើឱ្យទឹកលែងមានក្លិនស្អុយទៀតផង ។ - ក្រុមហ៊ុននឹងធ្វើការសិក្សា និងពិនិត្យតាមដានអំពីគុណភាពទឹកក្រោមដីជាប្រចាំ ជៀសវាងកើតមានការបំពុលទឹកដោយរៀបចំសកម្មភាពធ្វើការលាងសំអាតអាងនៅរដូវវស្សា នៅពេលដែលស្ទឹងជាយអាវែងមានធារទឹកអតិបរមា ហើយនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជូនដំណឹងអំពីការលាងសំអាតនេះឱ្យបានមួយសប្តាហ៍មុនពេលលាងអាងនេះ ។ - ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍និងសំភារៈ និងអ្នកឯកទេសសំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិត			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	ប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹកនៅផ្នែកខាងក្រោមជាពិសេសប្រជាពលរដ្ឋ សត្វពាហនៈ សត្វស្លាប និងពពួកសត្វព្រៃជុំវិញតំបន់គំរោងនេះ។ - ការស្តុកទឹកធ្វើជាអាងដ៏ធំនេះ នឹងអាចកើតមានរុក្ខជាតិទឹកដូចជា ពើក ចក កំពោក និងសត្វល្អិតចង្រៃ ដូចជា មូសបាក់តើរ ដែលបង្កឱ្យមានរំហួតខ្លាំង ការបំពុល គុណភាពទឹកអាងនិងការចម្លងជំងឺផ្សេងៗដែលកើតចេញពីប្រភពទឹកនេះ។	ចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គំរោង។ - ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយក្រសួងធនធានទឹក (ផ្នែកជលសាស្ត្រ) និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ ដោយសារគុណភាពទឹក បើសិនជាមានការបំពុលធ្ងន់ធ្ងរ។					
ធនធានព្រៃឈើ និងជំរកសត្វព្រៃ	- អាចនឹងប៉ះពាល់ដល់ជំរកសត្វព្រៃ ដោយសារ សកម្មភាពរបស់បុគ្គលិក-កម្មករ ទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃ ធ្វើឱ្យឈើ និងសត្វព្រៃ ទាំងនោះថយចុះ ឈានទៅរកការបាត់បង់ពូជមួយចំនួន។ - ជាមួយគ្នានេះដែរ ការទន្ទ្រានកាន់កាប់ដីនៅក្នុងឬក្បែរតំបន់គំរោង(ដែលជាតំបន់អភិរក្សព្រៃឈើ និងជំរកសត្វ នៃតំបន់អភិរក្សភ្នំក្រវាញ) ពីសំណាក់បុគ្គលិក-កម្មករ និងជនឆ្លៀតឱកាសនិយមមកពីខាងក្រៅនឹងធ្វើឱ្យបាត់បង់សម្បត្តិធនធានធម្មជាតិនៅតំបន់នោះ ហើយអាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារ បុគ្គលិក-កម្មករ គំរោងផងដែរ។ - ចំពោះការតំកល់ទឹកក្នុងអាង អាចនឹងធ្វើឱ្យខូចខាតជំរក	- ក្រុមហ៊ុននឹងមានវិធានការហាមឃាត់ដល់បុគ្គលិក-កម្មកររបស់គំរោងមិនឱ្យទន្ទ្រានកាន់កាប់ដីឬរុករានព្រៃ និងបំផ្លាញជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងនោះហើយនឹងធ្វើការអប់រំដល់បុគ្គលិក-កម្មកររបស់គំរោង មិនឱ្យទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ ដែលអាចបង្កការឆេះព្រៃឈើព្រមទាំងដាក់ពិន័យយ៉ាងតឹងរ៉ឹងដល់បុគ្គលិក-កម្មករណា ដែលប្រព្រឹត្តិល្មើសនឹងការហាមឃាត់ខាងលើនេះ។ - ក្រុមហ៊ុននឹងធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ អង្គការ CI និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងជាយថាហេតុនៅក្នុងតំបន់គំរោង ហើយនឹង		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	ក្រពើ ដូចជា នៅត្រពាំងបបុស្សធំ និងបបុស្សតូចព្រមទាំងជំរកសត្វព្រៃ និងបក្សីផ្សេងៗទៀត ដែលធ្លាប់រស់នៅក្នុងតំបន់អាងស្តុកទឹកនេះ។	ត្រូវមបំពាក់នូវឧបករណ៍ សំភារៈ សំរាប់ពន្លត់អគ្គីភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលផ្តល់សញ្ញា ពេលមានអគ្គីភ័យកើតមានឡើង ។ - ដើម្បីធ្វើឱ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ក្រុមហ៊ុននឹងត្រូវមមូលនិធិគ្រប់គ្រាន់ ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរ និង ធ្វើជំរកក្រពើនៅកន្លែងថ្មី)។					
ជីវសាស្ត្រ សត្វព្រៃ	- ការបាត់បង់ជំរកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹកទំហំ ៩៤៧៤ហ.ត នៃគំរោងសាងសង់រោងចក្រអគ្គិសនីនេះ នឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួន នៅក្នុងតំបន់អភិរក្សធនធានធម្មជាតិភ្នំក្រវាញ ហើយការតំកល់ទឹកក្នុងអាងដែលមានផ្ទៃទឹកដ៏ធំធេងនេះ មិនអាចឱ្យសត្វព្រៃមួយចំនួនធំឆ្លងកាត់បាន ជាពិសេសការធ្វើចរាចររបស់ជីរ៉ នៅតំបន់គំរោង និងការប្រែប្រួលនៃការធ្វើចរាចរ និង ទីជំរករបស់ត្រីនាគ និងក្រពើភ្នំ ក្នុងការឆ្លងកាត់ទំនប់ស្តុកទឹកនេះ ។ - ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និង ថែទាំគំរោង ក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់	- វិធានការដ៏លំបាកនេះ ក្រុមហ៊ុននឹងត្រូវមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជំរកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរ និង ធ្វើជំរកក្រពើនៅកន្លែងថ្មី)។ ជាងនេះទៅទៀតក្រុមហ៊ុននឹងហាមឃាត់ដាច់ខាត ដល់បុគ្គលិក-កម្មករបស់ខ្លួនក្នុងការប្រមាញ់សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ហើយនិងធ្វើការអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករគំរោងមិនឱ្យធ្វើការចាប់ឬបរបាញ់សត្វព្រៃនិងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។		✓			

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពុងធ្វើការអភិរក្ស ដោយអង្គការ CI ។ - ក្រោយពីមានការសាងសង់អាចនឹងមានការអភិវឌ្ឍន៍ផ្សេងៗនៅជុំវិញតំបន់គំរោងនឹងធ្វើឱ្យមានការហូរចូលនៃជនចំណូលថ្មីមកពីតំបន់ផ្សេងៗដើម្បីទន្ទ្រានកាន់កាប់ដីនិងរស់នៅតំបន់នេះ ដែលជាហេតុធ្វើឱ្យមានការបាត់បង់ធនធានធម្មជាតិ និងមានការប៉ះពាល់ដល់កត្តាជីវសាស្ត្រសត្វព្រៃយ៉ាងច្រើនដូចជា ការប្រែប្រួលនៃការបន្តពូជ ការស្វែងរកចំណី និងការបំលាស់ទីរបស់វាជាដើម ។	- ដើម្បីចូលរួមឱ្យការគ្រប់គ្រងធនធានធម្មជាតិកាន់ល្អប្រសើរ ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ច និង CI ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងអ្នកចំណូលថ្មីទប់ស្កាត់ការកាន់កាប់រុករានទន្ទ្រានដីថ្មី ពីជនចំណូលថ្មីទាំងនោះ ។					
ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ចជាតិ	- នៅស្ទឹងជាយអាវែងតំបន់គំរោងមានត្រីប្រមាណ៤៣ប្រភេទរស់នៅ ក្នុងនោះត្រីនាគ និងក្រពើភ្នំ ជាប្រភេទសត្វកំរ ដែលមានការយកចិត្តទុកដាក់ និងអភិរក្សដោយគំរោងអភិរក្សធនធានធម្មជាតិភ្នំក្រវាញកណ្តាលរបស់អង្គការ CI ។ ដូចនេះការបិទទ្វារទឹកដើម្បីតំកល់ទឹកក្នុងអាងរបស់គំរោងសាងសង់វារីអគ្គិសនីជាយអាវែង អាចនឹងប៉ះពាល់ដល់ជីវសាស្ត្ររបស់ត្រីនាគ និងក្រពើភ្នំ និងវារីសត្វមួយចំនួនទៀត ។ កត្តាជីវសាស្ត្រ ដែលនឹងត្រូវប៉ះពាល់សំខាន់របស់ត្រីនាគ និងវារីសត្វមួយចំនួនទៀតគឺការធ្វើចរាចរចុះឡើងឆ្លងកាត់ទំនប់វារីអគ្គសនី និងជំរកពងកូនរបស់ក្រពើភ្នំ ។ - ចំពោះការបង្ហូរទឹកចេញពីអាង (តាមទូប៊ីន) ដែលមាន	- បើមានការរកឃើញថាត្រីទាំងនោះជាប្រភពសេដ្ឋកិច្ចអាចរកចំណូលជូនជាតិនិងប្រជាពលរដ្ឋបានច្រើននោះក្រុមហ៊ុននឹងពិចារណារកវិធានការដើម្បីដោះស្រាយ។ ដោយរៀបចំធ្វើអាងចិញ្ចឹមត្រីនៅក្នុងអាងស្តុកទឹកនៃវារីអគ្គិសនី ហើយនឹងបង្កើនការគ្រប់គ្រងជលផល។ ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដល់វារីសាស្ត្រនោះ ពពួកពូជត្រីក្រៅ ស្រុកមិនត្រូវបានអនុញ្ញាតឱ្យកចូលតំបន់នេះទេ។ - ក្រុមហ៊ុននឹងរក្សាគុណភាពទឹកនៅក្នុងតំបន់គំរោង ដែលផ្តល់លក្ខខណ្ឌល្អនិងជំរកសំរាប់ការរស់នៅរបស់ត្រី។ រីឯបញ្ហាប៉ះពាល់ដល់ទីជំរកសត្វក្រពើភ្នំវិញ(*Crocodylus Siamesse*) ក្រុមហ៊ុននឹងសហការជាមួយអង្គការ និង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទីជំរកថ្មីសំរាប់សត្វក្រពើភ្នំ អាចរស់នៅបាន។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ថាន	តិច	មធ្យម	ខ្លាំង	
	បរិមាណអុកស៊ីសែនរលាយក្នុងទឹកតិច ធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្ររបស់ភាវីសត្វដែលរស់នៅក្នុងទឹកឬមច្ឆជាតិ។ - ការតំកល់ទឹកក្នុងអាងរបស់តំរោងភាវីអគ្គិសនីអាចនឹងកើតមានរុក្ខជាតិទឹក ដូចជា ពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ដែលបង្កឱ្យខ្វះអុកស៊ីសែនរលាយក្នុងទឹក ធ្វើឱ្យភាវីសត្វថយចុះ ឬបាត់បង់ ឬកើនឡើង នៃប្រភេទភាវីសត្វថ្មីទៀត ដែលមិនធ្លាប់មានក្នុងតំបន់។ - រឯការបំពុលទឹកដោយសំណល់ភាវ-រឹង ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ ពីឃ្លាំងស្តុកសំភារៈ និងពីរោងជាង នឹងធ្វើឱ្យមានការប៉ះពាល់ដល់ភាវីសត្វផងដែរ។	- ក្រុមហ៊ុននឹងផ្តល់មូលនិធិគ្រប់គ្រាន់សំរាប់ធ្វើដំរកក្រពើភ្នំនៅកន្លែងថ្មីឡើងវិញដោយសហការជាមួយអង្គការFFIនិងCI។ - ដើម្បីដោះស្រាយបញ្ហានៃការបង្ហូរទឹកចេញពីអាង (តាមទូប៊ីន) ដែលមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកតិចធ្វើឱ្យមានការប៉ះពាល់ដល់កត្តាជីវសាស្ត្រនោះ ក្រុមហ៊ុននឹងសាងសង់ប្រឡាយចំហរនាំទឹកមកអគារថាមពលដែលមានចំងាយ ៤០៣៧ម ដែលធ្វើឱ្យទឹកមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ហើយធ្វើឱ្យទឹកមានអុក ស៊ីសែនឡើងវិញ។ - ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ សំភារៈ និង អ្នកឯកទេសសំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹក របស់តំរោង។ - ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់ភាវ (អាងសិបទឹកទំនើប) ដោយគោរពតាមស្តង់ដា គុណភាពទឹករបស់ក្រសួងបរិស្ថាន ដែលមាននៅក្នុងអនុក្រឹត ២៧ សំរាប់សំអាតទឹកក្រខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ដែលស្នាក់នៅក្នុងដំណាក់កាលសាងសង់ និងធ្វើប្រតិបត្តិការ និងថែទាំតំរោង។					
បរិស្ថានសេដ្ឋកិច្ច-សង្គម							
ប្រពៃណី វប្បធម៌ និង សាសនា	តំរោងអាចនឹងមានផលប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ផងដែរ ដោយសារក្រុមហ៊ុននាំយកបុគ្គលិក-កម្មករតំរោងមកពីតំបន់ផ្សេងទៀត ឬ	- ក្រុមហ៊ុននឹងធ្វើការណែនាអប់រំដល់បុគ្គលិក-កម្មករបស់តំរោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃ		✓			

ឧបទាននបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	ជនបរទេស ដែលមានជំនឿ និងទំនៀមទំលាប់ផ្សេងៗគ្នា ធ្វើឱ្យមានការប៉ះពាល់ដល់ពួកគាត់ដែលមានជំនឿលើអារក្សអ្នកតាព្រៃភ្នំ ដូចជាពួកគាត់នាំគ្នាបង្កើតជាព្រៃអ្នកតា ដើម្បីធ្វើជាទីកន្លែងសក្ការៈបូជា។ មិនតែប៉ុណ្ណោះពួកគាត់មានការគោរពសត្វព្រៃមួយចំនួន ដូចជាការគោរពក្រពើភ្នំជាដើម ។	ភ្នំ ស្ថិតនៅជុំវិញទីតាំងគំរោងវារីអគ្គីសនីជាយអារែងនេះ ។ - ក្រុមហ៊ុននឹងដាក់វិន័យដល់បុគ្គលិក-កម្មករណាដែលបំពានលើទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងជំនឿសាសនារបស់ ប្រជាពលរដ្ឋក្នុងតំបន់ ។ - ក្រុមហ៊ុននឹងសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយទំនាស់ដែលកើតឡើងជាយថាហេតុឱ្យបានសមស្រប និងយុត្តិធម៌ ។					
ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត	- អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅតំបន់ផ្នែកខាងក្រោម ដោយសារ ទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ និងមានកិនស្មុយមកពីការរលួយពីរុក្ខជាតិ ដែលិចទឹក និងការខ្វះអុកស៊ីសែនរបស់ទឹក។ - ការគ្រប់គ្រងកាកសំណល់រឹង-រាវ បង្គន់ ដែលចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ឃ្លាំងស្តុកសំភារៈរោងជាងជាដើម អាចធ្វើឱ្យខូចដល់ប្រភពទឹកសំរាប់ផ្គត់ផ្គង់ក្នុងតំបន់គំរោង ។ - គំរោងវារីអគ្គីសនីជាយអារែងស្ថិតនៅខេត្តកោះកុង ដែលជាតំបន់ទេសចរណ៍តំបន់ឆ្នេរ នៃប្រទេសកម្ពុជា អាចនឹងទទួលឥទ្ធិពលនៃការកើនឡើងនៃភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលចង់ទៅទស្សនាកំសាន្តនៅតំបន់ទំនប់វារីអគ្គីសនីជាយ	- បញ្ហាប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ ដែលរស់នៅបែកខាងក្រោមទំនប់ Site A ក្រុមហ៊ុននឹងមានវិធាន ការសំអាតព្រៃឈើ ដំណាំ រុក្ខជាតិស្រទាប់ក្រោមជាមុនសិន មុននឹងទប់ទំនប់ឬទ្វារទឹក ដើម្បីបំពេញទឹកក្នុងអាង។ - ការគ្រប់គ្រងកាកសំណល់រាវ ក្រុមហ៊ុននឹងសាងសង់ប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ដល់បុគ្គលិក-កម្មករគំរោង និងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវ(អាងសិបទិកទំនើប) ពីការិយាល័យផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ ក្នុងការធ្វើប្រតិបត្តិ និងថែទាំគំរោង។ - ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការ			✓		

Draft

ឥតទាសបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ថាន	តិច	មធ្យម	ខ្លាំង	
	អារែងនេះ ក្រោយពីមានការសាងសង់រួច ពីព្រោះមានផ្លូវចេញ-ចូលស្រួល ។ - ការកើនឡើងនៃភ្ញៀវទេសចរនៅជាយអារែងនេះអាចធ្វើឱ្យកើតមានការបំពុលទឹកស្ទឹងជាយអារែង ដោយសារកាកសំណល់រឹង-រាវរបស់ភ្ញៀវទេសចរណ៍ទាំងនោះ ។ - តំរោងនេះនឹងអាចប៉ះពាល់ដល់ការប្រើប្រាស់ទឹកនៅរដូវប្រាំង របស់អ្នកភូមិព្រៃស្វាយ ដែលសៀនៅប៉ែកខាងក្រោមទំនប់ ក្នុងករណីក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកនៅក្នុងប្រឡាយ ដោយមូលហេតុការពារសុវត្ថិភាពមនុស្ស និង សត្វ ។	គ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យត្រឹមត្រូវតាមបច្ចេកទេស ដោយមានអាងសិបទឹក ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព ។ - ក្រុមហ៊ុននឹងរកប្រភពទឹកថ្មីផ្តល់ជូនប្រជាពលរដ្ឋ ដូចជាឥការតបណ្តាញផ្គត់ផ្គង់ទឹកពីអាង ឬជីកអណ្តូង និងស្រះ ។					
ផ្លូវគមនាគមន៍	- អាចនឹងបង្កឱ្យប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពលរដ្ឋក្នុងតំបន់ដូចជាការបិទផ្លូវមិនឱ្យប្រជាពលរដ្ឋ ចេញចូលក្នុងតំបន់ដែលធ្លាប់បានប្រើប្រាស់ ។ - ចំពោះស្ថានភាពផ្លូវតូចចង្អៀតហើយជួបបញ្ហាកកស្ទះលើដងផ្លូវ និងបញ្ហាមានចំណោតជាច្រើនកន្លែង នឹងបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកទេសចរណ៍ ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គំរោងដែលនឹងមានការកើនឡើង ។	- ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋក្នុងការបិទផ្លូវដែលធ្លាប់ចេញ-ចូលនោះ ក្រុមហ៊ុននឹងដោះស្រាយដោយមិនបិទផ្លូវដែល ប្រជាពលរដ្ឋធ្លាប់ចេញ-ចូលនោះទេ ។ ប្រសិនបើក្រុមហ៊ុនចង់បិទផ្លូវណាមួយដើម្បីសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ក្រុមហ៊ុននឹងធ្វើផ្លូវវាងជំនួសវិញ ។ - ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយចំពោះបញ្ហាផ្លូវ ដូចជា ការដាក់ផ្លាកសញ្ញាចរាចរ ធ្វើរបាំងការពារត្រង់ផ្លូវកោង និងមាន			✓		

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ស្ពាន	តិច	មធ្យម	ខ្លាំង	
		ចំណោទជាដើម ។ - ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោង និងធ្វើការថែរក្សាផ្លូវលំដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ដើម្បីធានាសុវត្ថិភាពនិងសំរួលចរាចរឱ្យបានល្អប្រសើរ					
សុខភាពសាធារណៈ:	- ការតំកល់ទឹកក្នុងអាងអាចនឹងកើតមានរុក្ខជាតិទឹក ដូចជា ពើក ចក កំប្លោក សារាយ និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ឬសត្វល្អិត ដែលអាចបង្កជំងឺ និងចម្លងជំងឺទៅសត្វ និងមនុស្សបាន ជាពិសេស ជំងឺកើតឡើងពីប្រភពទឹក (Waterborn diseases) ។ - តំបន់ជួរភ្នំក្រវាញសំបូរដោយព្រៃឈើជ្រលងដងអូរ អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គំរោង ដោយសារតំបន់នេះជាតំបន់ដែលកើតជំងឺគ្រុនចាញ់ និងគ្រុនសន្ទុំ ។ ផ្ទុយទៅវិញប្រជាពលរដ្ឋនៅតំបន់គំរោងក៏អាចឆ្លងជំងឺ អេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ពីបុគ្គលិក-កម្មករគំរោងដែលក្រុមហ៊ុនជ្រើសរើសយកមកពីតំបន់ឆ្ងាយផងដែរ ។ - ការបង្ហូរកាកសំណល់រាវ និងការបោះចោលនូវកាកសំណល់រឹងអាចមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារការគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អ ។ - អាចមានចរាចរជួញដូរគ្រឿងញៀនពីសំណាក់បុគ្គលិកកម្មករ	- ក្រុមហ៊ុននឹងធ្វើការពិនិត្យតាមដានគុណភាពទឹកក្នុងអាង និងក្រៅអាងឱ្យទៀងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកក្នុង ឬក្រៅអាងមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយ ដើម្បីធ្វើការកាត់បន្ថយ ។ - ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍-សំភារៈ និងអ្នកឯកទេសសំរាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃដែលនឹងអាចកើតមាននៅក្នុងអាងស្តុករបស់គំរោង ។ - ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នេះ ។ - ក្រុមហ៊ុននឹងធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ ។ - ក្រុមហ៊ុនសាងសង់និងថែទាំអាងប្រព្រឹត្តិកម្មកាកសំណល់រាវសំរាប់សំអាតទឹកក្រខ្វក់ ហើយទឹកដែល			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នុង	តិច	មធ្យម	ខ្លាំង	
	គំរោងធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈនៅតំបន់នោះ ។	បង្ហូរចេញពីអាងសំអាតនេះ នឹងមានកិរិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧ អនក្រ.បក របស់រាជរដ្ឋាភិបាល ។ - ក្រុមហ៊ុននឹងផ្តល់គ្រឿងបរិក្ខាពេទ្យ ថ្នាំព្យាបាល និងគ្រូពេទ្យសំរាប់ថែរក្សាសុខភាពបុគ្គលិកគំរោង ។ - ក្រុមហ៊ុននឹងសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅក្នុងតំបន់គំរោង ។					
សោភ័ណ្ឌភាព	អាចនឹងមានការកើនឡើងនូវភ្ញៀវទេសចរណ៍មកកំសាន្ត ចំនួនប្រជាពលរដ្ឋមករស់នៅតំបន់គំរោងដែលជាហេតុធ្វើឱ្យមានការចោលសំរាមដោយគ្មានសណ្តាប់ធ្នាប់ពីសំណាក់ភ្ញៀវទេសចរណ៍មកកំសាន្តប្រជាពលរដ្ឋរួមទាំងបុគ្គលិក-កម្មករបស់គំរោងផង នឹងធ្វើឱ្យបាត់សោភ័ណ្ឌភាពនៅតំបន់គំរោងនេះ	ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធរៀបចំការសំអាតអនាម័យនៅតំបន់ជុំវិញគំរោងឱ្យបានល្អប្រសើរ ។		✓			

Draft

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
ហានិភ័យ (Risk)	- ហានិភ័យដោយសារគ្រោះធម្មជាតិដូចជាការកើតមានការរញ្ជួយដី ឬបន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ អាចនឹងបង្កឱ្យមានមហន្តរាយធំៗ ដូចជាការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ជាពិសេសការធ្វើឱ្យរងរបួសនិងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករនិងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។ - ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និងសំពាធទឹកក្នុងអាងស្តុកទឹកដែលមានចំណុះ ៩២១លានម៉ែត្រគូប = ៩២១លានតោន ។ - ការឆេះព្រៃក្នុងតំបន់គំរោងដែលបណ្តាលមកពីការធ្វេសប្រហែសឬអំពើភេរវកម្មក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។ - ការកើតមានសង្គ្រាមឈានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជានិងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគំរោង ជួនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង។	- បញ្ហាហានិភ័យដោយគ្រោះធម្មជាតិ ក្រុមហ៊ុននឹងធ្វើការសិក្សាតាមដានបន្ថែមទៀត នៅក្នុងតំណាក់កាលនេះលើហេតុការណ៍ប្រែប្រួលលើកត្តាធម្មជាតិ និងអត្ថសញ្ញាណនានាដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីស្ទឹងជាយអារែងនេះ ។ - បញ្ហាដែលកើតឡើងពីការធ្វេសប្រហែសផ្នែកសន្តិសុខ ឬភេរវកម្ម ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិធានទីក្នុងការការពារ សន្តិសុខចំពោះគ្រឿងផ្ទុះនានា អគ្គីភ័យនានា និង ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោង ដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគំរោងនេះទាំងអស់ ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលា តាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះកើតឡើង ។ - ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមាន			✓		

ឥទ្ធិពលបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	ទំហំនៃហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
		បញ្ហា គ្រោះថ្នាក់ដោយចៃដន្យ ដូចជាការរញ្ជួយដី ឬសង្គ្រាមហើយនិងរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសំភារៈនិងថវិកាដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។					
ដំណាក់កាលបញ្ចប់គំរោង							
ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុននៃប្រទេសចិននេះ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្តកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសំរេចខ្លួនឯង ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ ដែលគួរឱ្យកត់សំគាល់ឡើយ ។					

៥.៤ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ (Positive Environmental Impacts)

៥.៤.១ ធនធានរូបសាស្ត្រ និងបរិស្ថាន (Physical and Ecological Resources)

- **ជលសាស្ត្រ**

ការទប់ទំនប់ Site A កាត់ស្ទឹងជាយអារែង របស់គំរោងវារីអគ្គិសនីជាយអារែង ខេត្តកោះកុងនេះ អាចជួយបន្ថយជំនន់ធំៗដោយសារ ព្យុះភ្លៀងទីហ្គុងក្នុងតំបន់ភ្នំក្រវ៉ាញនេះបានមួយផ្នែក ស្ទើរតែជារៀងរាល់ឆ្នាំនៅតំបន់ព្រែកត្រពាំងរូង តែងតែទទួលនូវទឹកជំនន់នៃស្ទឹងជាយអារែងនេះ ។ ហេតុដូចនេះហើយ បើជំនន់ដើមរដូវវស្សា អាចទប់បានមួយផ្នែកធំ តែបើជំនន់ចុងរដូវវស្សា នោះអាចទប់បានមួយផ្នែកតូចប៉ុណ្ណោះ ។

ការប្រលែងបញ្ចេញទឹកពីទំនប់ Site A មកខាងក្រោម ១.៥ម^3/វិនាទី នៅរដូវប្រាំងធ្វើឱ្យកំណាត់ស្ទឹងជាយអារែងពីទំនប់មកដល់អគារថាមពលមានទឹកគ្រប់គ្រាន់សំរាប់រក្សាជីវៈចំរុះរបស់កំណាត់នៃស្ទឹងនេះ ។ បន្ថែមពីនេះ នារដូវប្រាំងធ្វើឱ្យព្រែកត្រពាំងរូងមានទឹកសាបគ្រប់គ្រាន់ ដោយសារការបង្ហូរទឹកចេញតាមទូប៊ីនពីរ ដែលមានចាទឹកសរុបប្រមាណ ៥២ ម^3/វិនាទី ដែលព្រែកនេះពីមុនមានចាទឹកជាមធ្យមខែមិនាប្រមាណ ១៥.៥៤ ម^3/វិនាទី មានលំនឹងបរិស្ថានល្អប្រសើរ និង ទប់ស្កាត់ការជ្រាបចូលជ្រៅនៃទឹកប្រៃពីសមុទ្រមកតំបន់ក្បាលឆាយទៀតផង ។

- **មច្ឆជាតិ**

បរិមាណដ៏ធំធេងនៃអាងទឹកនេះអាចបង្កលក្ខខ័ណ្ឌសមស្របសម្រាប់ការអភិរក្ស និងការកើនឡើងនៃប្រភេទត្រីមួយចំនួនធំក្នុងតំបន់ស្ទឹងជាយអារែងនេះ ។

៥.៤.២ ធនធានសេដ្ឋកិច្ច និងសង្គម

- **ថាមពលអគ្គិសនី**

គំរោងវារីអគ្គិសនីជាយអារែងនេះ នឹងអាចផលិតកំលាងថាមពលបានប្រមាណ ១០៨ មេហ្គាវ៉ាត់ (MW) ហើយការផ្តល់ថាមពលក្នុង១ឆ្នាំអាចស្មើនឹង ៦១៨ ជីហ្គាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា ៨២% នៃថាមពលអគ្គិសនីដែលប្រទេសកម្ពុជាផលិតបានសរុបនៅឆ្នាំ ២០០៥ (៧៥៣ លានគីឡូវ៉ាត់ម៉ោង (mKWh) រាប់បញ្ចូលទាំងថាមពលនាំចូលពីប្រទេសជិតខាង គឺប្រទេសថៃ និងវៀតណាម) ។ ដោយសារគំរោង វារីអគ្គិសនីនេះនឹងផ្តល់ថាមពលអគ្គិសនីយ៉ាងចំបងដូចមានបង្ហាញជូនខាងលើនេះវាអាចឆ្លើយតបដ៏មានប្រសិទ្ធិភាពចំពោះដំណោះស្រាយប្រភពអគ្គិសនីសម្រាប់តំបន់នីរតី និងពាយ័ព្យនៃប្រទេសកម្ពុជា ក្នុងរយៈពេលមធ្យម ឬអាចនិយាយបានថា ប្រទេសកម្ពុជានឹងមានថាមពលអគ្គិសនីជាងទ្វេរដង នៃកំលាងថាមពលអគ្គិសនីផលិតសរុបក្នុងឆ្នាំ ២០០៥ (នេះគិតតែចំពោះគំរោងនេះតែប៉ុណ្ណោះ មិនបានរួមបញ្ចូលនៃគំរោងផ្សេងទៀតទេ) ។

គំរោងវារីអគ្គិសនីនេះនឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដល់អ្នកប្រើប្រាស់តាមរោងចក្រ ឧស្សាហកម្មនានា លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ដើម្បីរំដោះភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់គំរោង និងទូទាំងប្រទេស ព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ។

Draft

- **<u>ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់</u>**

គំរោងនេះនឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះដូចជា កែលំអរផ្លូវចេញចូលពីទីរួមស្រុកថ្មបាំង ទៅឃុំថ្ម ដូនពៅឱ្យមានលក្ខណៈល្អប្រសើរ សាងសង់ផ្លូវ និងស្ពានចេញចូលទៅកន្លែងទាំងទីលំនៅថ្មី ផ្លូវទៅអគារថមពល ផ្លូវតាមប្រឡាយ ។ល។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធបំរើឱ្យសាធារណៈជន គំរោងមានសាងសង់អគារស្នាក់នៅឱ្យបុគ្គលិកកម្មករ ការិយាល័យ សួនច្បារ និងអាងសំអាតទឹកស្អុយ សម្រាប់ការប្រើប្រាស់របស់បុគ្គលិកគំរោង និងធ្វើឱ្យមានសោភ័ណ្ឌភាពដល់តំបន់គំរោងទាំងមូលទៀតផង ។

- **<u>ការប្រើប្រាស់ដី/តំលៃដី និងទេសចរណ៍</u>**

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យដីក្នុងតំបន់កើនតំលៃខ្ពស់ជាងបច្ចុប្បន្ននេះ (២០០៧) ជាពិសេសការប្រើប្រាស់ដីសម្រាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍ ។ ដោយសារហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចទាក់ទាញអ្នកទេសចរជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់គំរោង តំបន់ជាយអារែង និងតំបន់ក្បែរខាងទៅថ្ងៃអនាគតយ៉ាងសន្ធឹកសន្ធាប់ទៀតផង ហើយនឹងធ្វើឱ្យខេត្តកោះកុងទាំងមូលក្លាយជាប៉ូលទេសចរណ៍យ៉ាងសំខាន់មួយសម្រាប់ប្រទេសកម្ពុជាយើងផងដែរ ។

- **<u>ផ្តល់ការងារ និងលើស្ទួយជីវភាព</u>** (Employment and increase living standard)

គំរោងនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងពេលសាងសង់ ក្នុងគំរោងនេះនឹងគ្រោងជ្រើសបុគ្គលិក-កម្មករចំនួន ១២០០នាក់ ដោយគិតទាំងកម្មកររងកទេសចិនផងដែរ ។

គំរោងនឹងមានការជ្រើសរើសអ្នកឯកទេស និងកម្មករ ជនជាតិខ្មែរមួយចំនួនទៀតនៅពេលប្រតិបត្តិការនិងថែទាំថែមទៀតផង ។

គំរោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈចូលបំរើការងារ ជាបុគ្គលិកកម្មករ ទាំងពេលសាងសង់ និងពេលប្រតិបត្តិការថែទាំ ។ ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន តាមរយៈទេសចរណ៍ជាតិ និងអន្តរជាតិមកកាន់តំបន់ជាយអារែងនិងការទស្សនាទំនប់វារីអគ្គិសនីនេះទៀតផង ។

- **<u>ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ</u>**

គំរោងវារីអគ្គិសនីជាយអារែងនឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដល់ការអភិវឌ្ឍន៍លើគ្រប់វិស័យ រាប់តាំងពីការប្រើប្រាស់សម្រាប់បំភ្លឺតាមលំនៅដ្ឋាន ទីក្រុង ការបំរើឱ្យវិស័យកសិកម្ម វិស័យទេសចរណ៍ ជាពិសេសវិស័យសិប្បកម្ម និងឧស្សាហកម្ម ដែលជាគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ជាពិសេសធ្វើឱ្យធានាបាននូវតំលៃភ្លើងថោកក្នុងការប្រើប្រាស់ទៀតផង ។

ម្យ៉ាងវិញទៀតគំរោងមានការបង់ផ្តាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករ លើការនាំចូលប្រេងឥន្ធនៈសម្រាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិការនិងថែទាំគំរោង ទៅតាមកិច្ចសន្យារវាងក្រុមហ៊ុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

- **<u>ការកាត់បន្ថយឧស្ម័នកាបូនិកដែលឱ្យផែនដីកើនកំដៅ</u>**

ទោះបីជាវារីអគ្គិសនីនេះប៉ះពាល់ដល់ព្រៃឈើ សត្វព្រៃ មច្ឆជាតិ និងប្រជាជនមួយចំនួនក៏ដោយ ប៉ុន្តែក្រុមហ៊ុនគ្រោងនឹងផ្តល់មូលនិធិសំរាប់ការពារបរិស្ថាន និងសំរាប់បំលាស់ប្តូរលំនៅដ្ឋានផងដែរ ។ នាពេលបច្ចុប្បន្ននេះ ការប្រើប្រេងឥន្ធនៈសំរាប់ដំណើរការម៉ាស៊ីនក្នុងការផលិតថាមពលអគ្គិសនីនេះ EDC គឺប្រើប្រេងម៉ាស៊ូត ១៣៧ លាន KWh ត្រូវជា ៨១.៣ % និងប្រេងឥន្ធនៈធ្ងន់ ៣១ លាន KWh ។ បើគិតតាមតួរលេខនេះ គឺអាចកាត់បន្ថយការប្រើប្រេងចំនួន ៣.៦ ដង នៃការប្រើប្រាស់ប្រេងឥន្ធនៈសំរាប់ផលិតអគ្គិសនីនៃឆ្នាំ ២០០៥ ដោយ EDC (នេះគិតតែចំពោះគំរោងនេះតែប៉ុណ្ណោះ មិនបានរួមបញ្ចូលនៃគំរោងផ្សេងទៀតទេ) ។

Draft